# រូបភាពនៃការកើតជាថ្មី



**លោកដុកទ័រ អេ អែល ហ្គីល** គឺជាកំពូលអ្នកនិពន្ធសៀវភៅជិត២០លានក្បាល ដែលបានបោះពុម្ពហើយ ។ ការងារជាសាវ័កផ្នែកអន្តរជាតិរបស់គាត់នេះគឺបានឈោងចាប់មនុស្សជាង៨០ជនជាតិ ។ គាត់បានអធិប្បាយទៅដល់ហ្វូងមនុស្សជាងម្ភៃម៉ឺននាក់ ដោយមានការបញ្ជាក់មកពីព្រះ និងព្រះបន្ទូលរបស់ព្រះអង្គ ជាមួយនឹងទីសម្គាល់នៃការប្រោសឱ្យជា និងការអស្ចារ្យផ្សេងៗ ។ ការអនុវត្តន៍ដែលមានពេញដោយអំណាចចេស្តារបស់គាត់ សេចក្តីបង្រៀនដែលមានពេញដោយជីវិតផ្លាស់ប្រែ និងដែលមានលទ្ធភាព នោះគឺតាមរយៈវីឌីអូ អូឌីយ៉ូ និងសៀវភៅជាច្រើនភាសា នោះសូមមើលទៅក្នុងវិបសាយ: www.gillministries.com


*១. ការបង្កើតឱ្យមានរូបដូចព្រះអង្គ......................... ០០១*
*២. យើងមានរូបភាពរបស់ព្រះវរបិតា..................... ០០៩*
*៣. រូបភាពនៃការកើតជាថ្មី .................................. ០១៩*
*៤. ការផ្លាស់ប្រែរូបភាពចាស់របស់យើង.................. ០២៩*
*៥. រូបភាពរបស់យើងនៅក្នុងព្រះគ្រីស្ទ.................... ០៤១*
*៦. ប្រយោជន៍នៃការកើតជាថ្មី .............................. ០៥៥*


# រូបភាពនៃការកើតជាថ្មី

## *មេរៀនទី ១: ការបង្កើតឱ្យមានរូបដូចព្រះអង្គ*

### I. តើយើងរាល់គ្នាជាអ្នកណា

### ក. ការកើតជាថ្មី

ការសិក្សាពីមេរៀនរូបភាពនៃការកើតជាថ្មី គឺនឹងនាំមកនូវការបើកសម្តែងដែលមានពេញដោយអំណាចចេស្តា ចំពោះយើងរាល់គ្នាដែលនៅក្នុងព្រះគ្រីស្ទ គឺជាអ្វីដែលមានន័យទៅលើការកើតជាថ្មីនោះ ។ វានឹងនាំមកនូវសេរីភាពពីអារម្មណ៍ថា ជាប់មានទោសការផ្តន្ទាទោស ភាពមិនពេញលេញ និងភាពថោកទាបជាដើម ។ វានឹងបញ្ចេញយើងយ៉ាងអង់អាចឱ្យចូលទៅក្នុងសេចក្តីរំជួយ ការបើកសម្តែងដែលមានការបំផ្លាស់បំប្រែជីវិត ចំពោះអ្វីដែលមានន័យថា នឹងបានជាម្នាក់ដែលនៅជាមួយនឹងព្រះយេស៊ូវគ្រីស្ទ ។ យើងនឹងស្រាវជ្រាវរាវរកនូវអ្វីដែលព្រះទ្រង់បានបម្រុងឱ្យយើង តាមរយៈការងារប្រោសលោះដ៏ធំឧត្តមរបស់ទ្រង់ ។ យើងនឹងរកឃើញដោយខ្លួនយើងនូវការបើកសម្តែងដូចជា:

**១. ការកើតជាថ្មី**
**២. វិញ្ញាណដែលត្រូវបានបង្កើតជាថ្មី**
**៣. ការបង្កើតជាថ្មី**

លោកសាវ័កប៉ុល បានសរសេរពាក្យទាំងនេះ:

២កូរិនថូស ៥:១៧

យើងគឺជាអ្នកជឿ យើងគឺជាអ្នក ប្រណាំងថ្មី យើងបានជាមនុស្សនៅក្នុងទីប្រណាំង "កំណើតថ្មី" គឺយើងជីវិតរបស់ព្រះគ្រីស្ទនៅក្នុងយើង។ យើងគឺជាអ្នកបានកើតជាថ្មីនៅក្នុងព្រះគ្រីស្ទ យើងស្ថិតនៅក្នុង

ការសិក្សានេះ គឺជាអ្នកជឿនឹងត្រូវបានបញ្ជូនទៅឱ្យបានជា"អ្នកមានកំណើតថ្មី" ។

ការសិក្សានេះ នឹងនាំមកនូវការបើកសម្តែងដែលមានភាពថ្មីស្រឡាង ជាមនុស្សម្នាក់ដែលព្រះយេស៊ូវទ្រង់គង់នៅជាមួយ ហើយយើងក៏បាននៅក្នុងព្រះអង្គផងដែរ ។

## ខ.យើងបានទទួលនូវការផ្លាស់ប្រែ

ជាមួយនឹងការបើកសម្តែង ដែលមានពេញដោយអំណាចចេស្តានេះ យើងជាអ្នកជឿនឹងចាប់ផ្តើមដើរ នៅក្នុងភាពរំភើបញាប់ញ័រ យើងមានសេរីភាពដ៏សំខាន់ថ្មីមួយ មានសិទ្ធិអំណាច មានភាពអង់អាច អំណាចចេស្តា និងជ័យជម្នះនៅក្នុងជីវិត និងក្នុងការបំពេញការងាររបស់ផងយើង ។

យើងនឹងរកឃើញដោយខ្លួនយើង នូវការប្រកាសដ៏ក្លាហានថា:

**ខ្ញុំបានស្គាល់ម្នាក់ដែលនៅក្នុងព្រះគ្រីស្ទហើយ!**
**ខ្ញុំគឺជាអ្វីដែលទ្រង់មានបន្ទូលថា ខ្ញុំគឺជាខ្ញុំ!**
**ខ្ញុំអាចនិយាយបានថា ខ្ញុំអាចធ្វើបាន!**
**ខ្ញុំអាចមានគ្រប់អ្វីៗទាំងអស់ដែលទ្រង់មាន!**

## II. មនុស្សដែលបានបង្កើតនៅក្នុងរូបភាពរបស់ព្រះ

### ក. កាលដើមដំបូង

ដើម្បីឱ្យបានយល់ពីអ្វី ដែលយើងគឺជាអ្នកដែលបានកើតជាថ្មី យើងត្រូវតែយល់ពីអ្វីដែលមនុស្សប្រុសស្រីត្រូវបានបង្កើតឡើងពីដំបូងមក ហើយមាននៅផង ។ យើងត្រូវតែយល់ថា ព្រះទ្រង់មានគោលបំណង និងមានផែនការ គឺនៅពេលដែលទ្រង់បានបង្កើតមនុស្សប្រុសស្រីមក គឺនៅក្នុងរូបភាពផ្ទាល់របស់ទ្រង់ និងប្រទានពរឱ្យគេមានសិទ្ធិអំណាចពេញលេញ និងឱ្យមានអំណាចគ្រប់គ្រងនៅលើផែនដីនេះ ។ លោកុប្បត្តិ ១:២៦-២៨

### ខ. ឱ្យមានរូបភាព - ព្រះគម្ពីររ៉ូម ៨:២៩

យើងត្រូវបានបង្កើតមកឱ្យមានរូបភាពដូចជាព្រះ ។ យើងត្រូវបានបង្កើតឡើងជាថ្មី គឺយើងត្រូវតែបានសម្របខ្លួនទៅនឹងរូបភាពនៃព្រះរាជបុត្រារបស់ព្រះអង្គ ។ រូបភាពទាំងនោះគឺមានភាពដូចយ៉ាងពិតប្រាកដ ។ តាមរយៈវចនានុក្រមសង្ខេបរបស់លោក វិបស្ទើរ ពាក្យ "រូបភាព" មានន័យថា:

១. ការធ្វើត្រាប់ ឬការធ្វើជាតំណាងរបស់មនុស្សណាម្នាក់ ។
២. ការប្រមើលមើលទៅលើការចាប់អារម្មណ៍ ពីរបស់ខ្លះដែលបានផលិត ដោយការឆ្លុះបញ្ចាំងពីកញ្ចក់ជាដើម ។
៣. មនុស្សម្នាក់ ដែលដូចគ្នាទៅនឹងអ្នកណាម្នាក់ទៀតដូចជាការថ្កិត ការធ្វើជាសំណៅ ឬភាពដូចគ្នា ។
៤. ជាតំណាងដ៏រស់រវើក ព្រះទ្រង់បានបង្កើតលោកអ័ដាម ឱ្យមានរូបភាពដូចទ្រង់ដ៏ពិតប្រាកដ ។ ទ្រង់បានបង្កើតគាត់ឱ្យមានរូបភាពដូចជាទ្រង់បេះបិទ គឺដូចជាកញ្ចក់ឆ្លុះរូបរបស់ព្រះ គឺឱ្យដូចជារូបរាងកាយរបស់គាត់បេះបិទ គឺនៅក្នុងរូបភាពព្រះរបស់គាត់មានដូចជាព្រលឹង និងនៅក្នុងវិញ្ញាណរបស់គាត់ដែលមានជីវិតរស់ និងមានដង្ហើមរបស់ព្រះ ។

មនុស្សជាតិគឺត្រូវបានបង្កើតឡើង ឱ្យមានរូប និងមានសិរីល្អរបស់ព្រះដែលគង់នៅលើផែនដីនេះ ។ ព្រះគម្ពីរ១កូរិនថូស ១១:៧ក

## គ. ព្រះត្រៃឯក

ព្រះទ្រង់មានបន្ទូលថា "ចូរយើងបង្កើតមនុស្សឱ្យដូចជារូបយើង" ទ្រង់មានបន្ទូលថា "យើង" ពីព្រោះសូម្បីតែព្រះអង្គទ្រង់ ដែលមានតែមួយអង្គគត់ក៏ដោយ ក៏បានបញ្ជាក់បង្ហាញថា មានបីអង្គផ្សេងៗពីគ្នាដែរគឺៈ

១. ព្រះដ៏ជាព្រះវរបិតា

២. ព្រះដ៏ជាព្រះរាជបុត្រា

៣. ព្រះដ៏ជាព្រះវិញ្ញាណបរិសុទ្ធ

មនុស្សប្រុស-ស្រី ដែលបានបង្កើតមកនៅក្នុងរូបភាពរបស់ទ្រង់ ក៏មានចែកជាបីដែរ ។ លោកសាវ័កប៉ុលក៏បានផ្ដល់ជូននូវភាពជាត្រៃឯករបស់យើងដែរ គឺគាត់សរសេរថាៈ

១ ថែស្សាឡូនិច ៥ៈ២៣ - ព្រះអង្គទ្រង់ផ្ទាល់ទ្រង់បានសម្រេចនូវកម្មវិធីគឺមិនមែនជាការខឹតខំប្រឹងប្រែងរបស់យើងផ្ទាល់ខ្លួនទេ ។

## ឃ. យើងមានវិញ្ញាណ

វិញ្ញាណរបស់យើង គឺជាផ្នែកមួយដែលមានមនសិក្ការៈរបស់ព្រះចំពោះយើង គឺដែលត្រូវធ្វើការជាមួយនឹងវិញ្ញាណពិតៈ ផ្នែករបស់យើងដែលអាចមានភាពទំនាក់ទំនង និងមានភាពប្រកបគ្នាជាមួយនឹងព្រះ ។ យើងត្រូវការបើកសម្ដែងពីវិញ្ញាណ ដែលបានបង្កើតជាថ្មីបំផុតរបស់យើង ហើយតាមរយៈការបើកសម្ដែងនោះ ព្រះទ្រង់នឹងកែជាថ្មីនូវព្រលឹង និងរូបកាយរបស់យើង ឱ្យបានជាតែមួយម្ដងទៀតពីអ្វីៗទាំងអស់ដែលត្រូវបានបង្កើតមកឱ្យមាននៅនោះ ។ ដោយការធ្វើយ៉ាងដូច្នោះ នោះយើងនឹងបានជា "ការបង្គ្រប់ដ៏ពេញលេញ" ព្រមទាំង "ជាការការពារដោយគ្មានការបន្ទោសបាន នៅពេលដែលព្រះគ្រីស្ទយេស៊ូវជាព្រះអម្ចាស់នៃយើងទ្រង់យាងមក" ។

## ង. យើងមានព្រលឹង

ព្រលឹងរបស់យើងគឺជាផ្នែកមួយ ដែលត្រូវតែធ្វើការជាមួយនឹងតំបន់ខួរក្បាល ។ វាគឺជាការយល់ដឹងរបស់យើង ជាអារម្មណ៍របស់យើង ជាឆន្ទៈរបស់យើង ។ វាគឺជាផ្នែកមួយរបស់យើងដែលមានជាហេតុផល និងជាគំនិតឡើង ។

## ច. យើងរស់នៅក្នុងរូបកាយ

រូបកាយរបស់យើង គឺជាផ្នែកនៃរូបសាច់ឈាមរបស់យើងៈ គឺជាផ្ទះដែលវិញ្ញាណ និងព្រលឹងរបស់យើងរស់នៅ ។ ក៏មានជាតួបុគ្គលបីដែលមានព្រះទ្រង់ជាប្រមុខ ក៏បានចែកដាច់ជាផ្នែកផ្សេងៗពីគ្នា ហើយពួកវាក៏មានព្រះមួយអង្គគង់នៅផងដែរ នៅក្នុងផ្លូវតែមួយដូចគ្នា គឺជាវិញ្ញាណ ព្រលឹង និងរូបកាយរបស់យើង ដែលបានបញ្ចូលគ្នាជាបុគ្គល ដែលព្រះទ្រង់បានបង្កើតមកឱ្យមាននៅ ។

## ឆ. ដែលមានជីវិតរបស់ព្រះ

យើងដឹងថា ព្រះទ្រង់បានសូនលោកអ័ដាមដោយព្រះហស្តទ្រង់ផ្ទាល់ នៅក្នុងរូបភាពរបស់ទ្រង់ ហើយបន្ទាប់មកទ្រង់ក៏បានផ្លុំខ្យល់ដង្ហើមរបស់ទ្រង់ ចូលទៅក្នុងគាត់ឱ្យមានជីវិតរស់ឡើង គឺឱ្យមានដង្ហើមដកចេញចូល ។ ព្រះគម្ពីរលោកុប្បត្តិ ២ៈ៧ ។

ជីវិតរបស់ព្រះគឺបានបន្ថែមឱ្យមានច្រើនជាងការដែលបានសម្ដែងមកថាមនុស្សមានព្រលឹងរស់ ។ វាគឺជាប្រភពនៃជីវិតទាំងអស់ ។

## ជ. ជីវិតហ្សូ(Zoe)

មានពាក្យជាភាសាក្រិកសំខាន់ៗពីរយ៉ាង ដែលបានប្រើសម្រាប់ពាក្យ "ជីវិត" នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ ពាក្យ "ផ្សូជេ"

មានន័យថា ធម្មជាតិ ឬជីវិតមនុស្សជាតិ ។ ពាក្យ "ហ្សូ" មានន័យថា ជីវិត និងធម្មជាតិរបស់ព្រះអង្គទ្រង់ ។ វាគឺជាពាក្យជីវិតហ្សូ គឺជាជីវិតនិងធម្មជាតិរបស់ព្រះ ដែលបានទទួលនូវការចែករំលែក ចូលទៅក្នុងអ្នកជឿគ្រប់រូប ដែលបានកើតជាថ្មី ។

តើការនេះបានជំរុញយើងយ៉ាងដូចម្តេច ដែលយើងរស់នៅជាមួយជីវិត និងធម្មជាតិរបស់ព្រះឬអី! នៅពេលដែលលោកអ័ដាម និងនាងអេវ៉ា បានធ្វើបាបពួកគេបានបាត់បង់នូវជីវិតហ្សូ របស់ព្រះ ប៉ុន្តែ ពេលដែលយើងបានកើតជាថ្មី នោះវិញ្ញាណរបស់យើង គឺត្រូវបានបង្កើតឱ្យមានជីវិតរស់ជាមួយនឹងព្រះវិញ ។ មានតែជីវិតរបស់ព្រះទេ ដែលមានអំណាចក្នុងការបង្កើតនេះ ។ នៅក្នុងការបង្កើតមនុស្សមក ធូលីដីក៏មានព្រលឹងរស់ គឺដោយសារតែជីវិតរបស់ព្រះត្រូវបានបញ្ចូលខ្យល់ចូលទៅក្នុងគេ ។

ព្រះគម្ពីរយ៉ូហាន ១:៣-៤

## ឈ.ពន្លឺរបស់ព្រះ

ជីវិតរបស់ព្រះគឺជាពន្លឺ ហើយពន្លឺនេះ ឬក៏សិរីល្អដ៏ភ្លឺចិញ្ចែងនេះ គឺបានត្រឡប់ជាពន្លឺរបស់លោកអ័ដាម និងនាងអេវ៉ា នៅមុនពេលដែលពួកគេបានធ្វើបាបនោះ ។

ព្រះគម្ពីរ ១យ៉ូហាន ១:៥

វាគឺជាសមត្ថភាពបំផុតមុនពេល ដែលពួកគេបានធ្លាក់ចុះ គឺដែលលោកអ័ដាម និងនាងអេវ៉ា បានទទួលនូវការស្លៀកពាក់ដោយនូវពន្លឺដែលមកពីព្រះនេះ គឺជាសិរីល្អដ៏ភ្លឺចិញ្ចែងរបស់ទ្រង់ ។ ព្រះគម្ពីររ៉ូម ៦:២៣

## ញ. សេចក្តីគ្រប់លក្ខណ៍របស់ព្រះ

យើងស្គាល់រូបកាយរបស់លោកអ័ដាម និងនាងអេវ៉ា ដែលមានសុខភាពគ្រប់លក្ខណៈ មានអំណាច និងមានកម្លាំង ពីព្រោះទាំងអស់នេះគឺជាផ្នែកមួយនៃជីវិតរបស់ព្រះ ។

ដង្ហើមជីវិតរបស់ព្រះ គឺកំពុងតែបង្ហូរមកតាមរយៈឈាមរបស់ពួកគេ ដើម្បីឱ្យគ្រប់ទាំងកោសិកា និងគ្រប់ទាំងអំណោយដល់ពួកគេឱ្យមានសុខភាពគ្រប់គ្រាន់ និងមានជីវិតអស់កល្បជានិច្ច ។ លោកអ័ដាម និងនាងអេវ៉ា គឺត្រូវបានបង្កើតមកឱ្យមានជីវិតអស់កល្បជានិច្ច ។ ពួកគេមិនអាចស្លាប់ គឺដោយរស់នៅជាយូរអង្វែង ដែលពួកគេបានមានជីវិតរបស់ព្រះនៅជាមួយពួកគេវិញ ។

ព្រលឹង (គំនិត អារម្មណ៍ និងឆន្ទៈ) របស់លោកអ័ដាម និងនាងអេវ៉ា គឺបានដូចជាព្រះនៅក្នុងធម្មជាតិរបស់ពួកគេ ។ ព្រលឹងរបស់ពួកគេ គឺមានជីវិតរបស់ព្រះនៅខាងក្នុង ហើយគំនិត ឆន្ទៈ និងអារម្មណ៍របស់ពួកគេ គឺបានមកជាតែមួយជាមួយនឹងព្រះ ។ រីឯវិញ្ញាណរបស់ពួកគេក៏ត្រូវបានគ្រប់លក្ខណ៍ គឺបានមកជាតែមួយជាមួយនឹងព្រះនោះឯង ។

## ដ. ការប្រទានឱ្យនូវអំណាចគ្រប់គ្រង

រឿងមួយដែលព្រះទ្រង់មានបន្ទូល អំពីលោកអ័ដាម និងនាងអេវ៉ា បន្ទាប់ពីទ្រង់បានបង្កើតពួកគេមកឱ្យមាននៅ "ចូរឱ្យពួកគេមានអំណាចគ្រប់គ្រងលើ!"

ព្រះគម្ពីរលោកុប្បត្តិ ១:២៦

ព្រះទ្រង់បានប្រទានឱ្យលោកអ័ដាម និងនាងអេវ៉ា មានសិទ្ធិអំណាចពេញលេញ និងមានអំណាចគ្រប់គ្រង ដើម្បីគ្រប់គ្រងលើចក្រវាឡទាំងមូល លើកលែងតែស្ថានផែនដីនេះ

ចេញ ។ នៅទីនេះ ទ្រង់បានប្រទានសិទ្ធិអំណាចនេះ ដល់អស់អ្នកដែលបានកើតជាថ្មី គឺជាអ្នកដែលទ្រង់បានបង្កើតមកឱ្យបានដូចជាអង្គទ្រង់នោះឯង ។

### ឋ. អំណាចចេស្តាក្នុងការបង្កើត

គ្រាន់តែអំណាចចេស្តារបស់ព្រះ ដែលទ្រង់បានបង្កើតចក្រវាឡនេះមក រីឯលោកអ័ដាម និងនាងអេវ៉ា គឺត្រូវបានប្រទានមកនូវអំណាចចេស្តា ដើម្បីឱ្យស្រមើស្រមៃបានជឿ និងបានបង្កើតមក ។ ចាប់តាំងពីបំណងចិត្តរបស់ពួកគេបានមកជាតែមួយជាមួយនឹងព្រះ នោះគ្មានគ្រោះថ្នាក់អ្វីកើតឡើងដល់ជីវិតនៃការបង្កើតរបស់ព្រះនៅក្នុងពួកគេ ដែលនាំឱ្យមានភាពទារុណ ឬក៏មានគោលបំណងខុសឆ្គងនោះឡើយ ។ គ្រប់ទាំងស្នាព្រះហស្តទាំងអស់នៅលើផែនដីនេះ គឺសុទ្ធតែបានពេញគ្រប់គ្រាន់ទាំងអស់ ហើយពួកគេក៏បានទទួលនូវការបង្ហាត់បង្រៀនឱ្យបានជាបរិបូរ ដែលគ្រប់ទាំងស្នាព្រះហស្តនោះ បានហើយចប់សព្វគ្រប់ ។

ព្រះគម្ពីរលោកុប្បត្តិ ១:២៨

### ឌ. មានការប្រកបជាមួយនឹងព្រះ

ពេលដែលព្រះទ្រង់បានបង្កើតលោកអ័ដាម និងនាងអេវ៉ាមក ពួកគេបានគ្រប់លក្ខណ៏ក្នុងការប្រកបជាមួយនឹងទ្រង់ ទ្រង់បានមានបន្ទូលទៅពួកគេមុខទល់នឹងមុខ ។ ពួកគេអាចចូលទៅដល់ព្រះដោយចិត្តក្លាហាន ។ ពួកគេគ្មានអារម្មណ៏ថាមានទោស ថាមានការផ្តន្ទាទោស ឬក៏ថោកទាបនោះទេ គឺពួកគេមានការប្រកបទាក់ទងជាមួយនឹងព្រះដ៏គ្រប់លក្ខណៈវិញ។

ព្រះទ្រង់បានសម្តែងនូវការជឿជាក់ របស់ទ្រង់ដ៏ពិតប្រាកដដល់លោកអ័ដាម គឺដែលទ្រង់បាននាំពួកសត្វពាហណៈមកឯគាត់ ដើម្បីឱ្យគាត់បានដាក់ឈ្មោះឱ្យពួកវា ។

ព្រះគម្ពីរ លោកុប្បត្តិ ១:២៩

### ឍ. ការមានឆន្ទៈដោយសេរី

ព្រះទ្រង់ក៏ប្រទានពរឱ្យលោកអ័ដាម និងនាងអេវ៉ា មានជម្រើសផងដែរ គឺឱ្យមានឆន្ទៈដោយសេរី ។ ពួកគេមិនមែនត្រូវបានបង្កើតមកឱ្យដូចជារូបតុក្កតា ដែលគ្មានសកម្មភាពគ្មានជម្រើស ឬក៏គ្មានការតបតទៅព្រះនោះទេ ។ ពួកគេមានសមត្ថភាពនឹងធ្វើការជ្រើសរើស ដោយការស្តាប់បង្គាប់ ឬមិនស្តាប់បង្គាប់បាន ។ ជម្រើសនេះគឺត្រូវបានដាក់ឱ្យនៅជុំវិញសេចក្តីបង្រៀនរបស់ព្រះ ចំពោះដើមឈើដ៏វិសេសមួយ ដែលនៅក្នុងសួនច្បារអេដែននោះ គឺរវាងដើមឈើដឹងខុសត្រូវ និងដើមឈើជីវិតនោះ ។ ព្រះទ្រង់មានបន្ទូលថា ប្រសិនបើពួកគេទទួលទានផលពីដើមឈើនោះ ពួកគេនឹងស្លាប់ជាពិត ។

ព្រះគម្ពីរលោកុប្បត្តិ ២:១៦-១៧

## III. ការចូលមកនៃអំពើបាប ការបាត់បង់នៃមនុស្សជាតិ

ព្រះគម្ពីរសម្តែងថា លោកអ័ដាម និងនាងអេវ៉ាជ្រើសរើសនូវការមិនស្តាប់បង្គាប់ដល់ព្រះ ។ នេះគឺជាអំពើបាប ។

ព្រះគម្ពីរលោកុប្បត្តិ ៣:៦

តាមរយៈអំពើបាប មនុស្សជាតិទាំងអស់ត្រូវបានរងទុក្ខដល់ទៅមានការបាត់បង់ដ៏ធំសម្បើម ។

### ក.ការបាត់បង់នូវការប្រកបទាក់ទង

ព្រះទ្រង់បានរស់នៅក្នុងភាពបរិសុទ្ធ និងភាពសុចរិតដ៏គ្រប់លក្ខណ៏របស់ទ្រង់ ដូច្នេះ ទ្រង់មិនអាចនឹងមានការប្រកបទាក់ទងមួយនឹងលោកអ័ដាម និងនាងអេវ៉ាបានយូរអង្វែងតទៅនោះឡើយ ។ អំពើបាបរបស់ពួកគេ ក៏បានចាប់ផ្តើមទៅជាគ្រឿងរារាំងរវាងពួកគេនិងព្រះ ។ ការមានទោស និងការ

ត្រូវទទួលនូវការផ្តន្ទាទោសរបស់ពួកគេ ក៏បានបណ្តាលឱ្យពួកគេបានលាក់ខ្លួននឹងព្រះ ។

ព្រះគម្ពីរលោកុប្បត្តិ ៣:៧-៨

ពួកគេបានបាត់បង់នូវមុខងារដ៏មានតម្លៃបំផុត គឺជាភាពទំនាក់ទំនង ការប្រកបទាក់ទងដ៏គ្រប់លក្ខណ៍របស់ពួកគេជាមួយនឹងព្រះនោះឯង ។

## ខ. ការបាត់បង់ជីវិតរបស់ព្រះ

នៅពេលដែលលោកអ័ដាម និងនាងអេវ៉ាបានទទួលទានផ្លែឈើដឹងខុសត្រូវ ពួកគេបានទទួលនូវសេចក្តីស្លាប់ខាងឯវិញ្ញាណហើយ ។ ពួកគេមិនមានជីវិតរបស់ផងព្រះ នៅក្នុងពួកគេតទៅទៀតឡើយ ។

ព្រះគម្ពីររ៉ូម ៥:១២

វិញ្ញាណរបស់ពួកគេ បានត្រឡប់ទៅជាវិញ្ញាណស្លាប់ ។ វិញ្ញាណរបស់ពួកគេ បានត្រឡប់ទៅជាវិញ្ញាណដែលឥតបានការ ។ ដង្ហើមវិញ្ញាណរបស់ព្រះ ដែលទ្រង់បានផ្លុំបញ្ចូលទៅក្នុងលោកអ័ដាម លែងនៅក្នុងពួកគេតទៅទៀតហើយ ។

## គ. ការបាត់បង់នូវសិរីល្អរបស់ព្រះ

សិរីល្អរបស់ព្រះ ដែលមាននៅក្នុងរូបកាយរបស់លោកអ័ដាម និងនាងអេវ៉ា គឺត្រូវបានបាត់បង់ទៅក្នុងពេលភ្លាមៗនោះដែរ ។ ព្រះគម្ពីររ៉ូម ៣:២៣

ពួកគេបានដឹងដ៏ពិតប្រាកដថាខ្លួនគេនៅជាអាក្រាត ។ ព្រះគម្ពីរលោកុប្បត្តិ ៣:៧ក

## ឃ. ការបាត់បង់ការយល់ដឹងខាងវិញ្ញាណ

នៅពេលដែលលោកអ័ដាម និងនាងអេវ៉ា បានទទួលការស្លាប់ខាងឯវិញ្ញាណ នោះព្រលឹងរបស់ពួកគេក៏មិនរស់នៅចំពោះព្រះតទៅទៀតដែរ ។ គំនិតរបស់ពួកគេក៏លែងមានគំនិតរបស់ព្រះតទៅទៀតដែរ ។ ប្រភពនៃការដឹងដោយវិញ្ញាណរបស់ពួកគេក៏មានការផ្លាស់ប្តូរ ពីវិញ្ញាណរបស់ពួកគេដែលឥឡូវនេះត្រូវបានស្លាប់ទៅហើយនោះ ទៅជាអ្វីដែលពួកគេអាចដឹងបានដោយរូបកាយ ខាងផ្នែកសាច់ឈាមរបស់ពួកគេនោះទៅវិញដែរ ។

ពួកគេបានចាប់ផ្តើមអនុវត្ត ទៅតាមតំបន់ខាងសាច់ឈាមដឹកនាំនូវវិញ្ញាណទាំង៥របស់ពួកគេនោះទៅវិញ ។ ការដឹងពិតនិងសេចក្តីពិត បានត្រឡប់ទៅជាអ្វីដែលពួកគេអាចមើលឃើញ អាចហិតក្លិន អាចដឹងរសជាតិ ឬក៏អាចប៉ះពាល់បានតែប៉ុណ្ណោះ ។

## ង. ការបាត់បង់នូវសុខភាពពេញលេញ

រូបកាយរបស់លោកអ័ដាម និងនាងអេវ៉ា គឺគ្មានជីវិតរបស់ព្រះនៅជាមួយតទៅទៀត ដែលបង្ហូរមកតាមរយៈសរសៃឈាមរបស់ពួកគេតទៅទៀតដែរ ។ ពួកគេឥឡូវនេះគឺមានតែប្រធានបទបញ្ជាក់ពីភាពមានជម្ងឺ ជម្ងឺរោគា និងភាពនៃការខូចបង់តែប៉ុណ្ណោះ ។ ក្នុងមួយរំពេចដែលពួកគេបានធ្វើបាបនោះ ពួកគេក៏បានចាប់ផ្តើមស្លាប់ខាងឯរូបកាយ តាមកំណត់អាយុខាងរូបសាច់ ។

## ច. ការបាត់បង់សិទ្ធិអំណាច

លោកអ័ដាម និងនាងអេវ៉ា បានបាត់បង់នូវសិទ្ធិអំណាចព្រមទាំងអំណាចគ្រប់គ្រងរបស់ពួកគេ នៅលើផែនដីនេះ ។ ពួកគេបានចុះចូលទៅនឹងសាតាំង ។ ឥឡូវនេះ ពួកគេកំពុងតែរស់នៅក្នុងនគររបស់វា ដែលមានពេញដោយភាពអស់សង្ឃឹមជាមួយនឹងអានោះ ដែលវាមកប្រយោជន៍តែនឹង "លួច សម្លាប់ ហើយបំផ្លាញ" ប៉ុណ្ណោះ ។

**ឆ.បានត្រឡប់មកជានៅក្រោមជំនាន់នីមួយៗ**

គំនិតដែលនៅក្រោមជំនាន់និមួយៗ និងគំនិតរបស់អ្នកជឿ ដែលគ្មានការខិតខំប្រឹងធ្វើសារជាថ្មី តាមរយៈព្រះបន្ទូល គឺពួកគេតែងតែមានពេញទៅដោយគំនិតញាណ ដ៏កាចអាក្រក់ទៅវិញ ។ ព្រះគម្ពីរសុភាសិត ៦:១៦-១៨

ពួកគេមានពេញដោយការស្អប់ព្រះ

១. មានអំនួត

២. អណ្តាតភូតភរ

៣. បង្ហូរឈាមដែលគ្មានទោស

៤. រត់ទៅរកសេចក្តីអន្តរាយ

លោកសាវ័កប៉ុល ក៏បានពណ៌នាពីភាពគ្មានព្រះមនុស្សដែលគ្មានភាពសុចរិតនេះផងដែរ ។ ព្រះគម្ពីររ៉ូម ១:១៨-២២

## IV.សេចក្តីសន្យាពីការប្រោសលោះ

### ក. សេចក្តីសន្យាលើកទីមួយ

លោកអ័ដាម និងនាងអេវ៉ាបានឈរនៅក្នុងសួនច្បារអេដែនៈ

១. ការធ្វើឱ្យមានស្លាកស្នាមដ៏គ្មានសេចក្តីសង្ឃឹម ចំពោះភាពទំនាក់ទំនង និងការប្រកបជាមួយនឹងព្រះ ។

២. សិទ្ធិអំណាចរបស់ពួកគេគឺមានស្លាកស្នាម ។

៣. ប្រាជ្ញានិងសុខភាពដ៏គ្រប់លក្ខណ៍របស់ពួកគេ ជាប់មានស្លាកស្នាម ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលព្រះទ្រង់បានមានបន្ទូលទៅសាតាំង គឺទ្រង់បានសន្យាថា នឹងកែប្រែមនុស្សជាតិជាថ្មីឡើងវិញ តាមរយៈការងារជំនួសរបស់ទ្រង់ ជាអ្នកប្រោសលោះ ដែលនឹងយាងមកជាគ្រាប់ពូជរបស់ស្ត្រី ។ ព្រះគម្ពីរលោកុប្បត្តិ ៣:១៥

### ខ. តាមរយៈគ្រាប់ពូជរបស់លោកអ័ប្រាហាំ

គឺជាសេចក្តីសន្យាពីអ្នកប្រោសលោះ ដែលត្រូវបានទទួលនូវការផ្លាស់ប្រែជាថ្មី គឺដែលព្រះទ្រង់មានបន្ទូលថា គ្រប់ជាតិសាសន៍ទាំងអស់នៅលើពិភពលោក នឹងបានពរដោយសារលោកអ័ប្រាហាំ ។

ព្រះគម្ពីរលោកុប្បត្តិ ១៨:១៨

ព្រះទ្រង់មានបន្ទូលម្តងទៀតពីការតាំងសញ្ញា នឹងលោកអ៊ីសាក និងយ៉ាកុប ។ ទ្រង់បានសន្យាថា គ្រប់ជាតិសាសន៍ទាំងអស់នៅលើផែនដី នឹងបានពរតាមរយៈពូជរបស់ពួកគេ ។ គឺជាការយាងមករបស់ព្រះដ៏ប្រោសលោះនោះឯង!

### គ. តាមរយៈពូជរបស់ស្តេចដាវីឌ

ព្រះទ្រង់ក៏បានបង្កើតនូវការតាំងសញ្ញា ចំពោះស្តេចដាវីឌ គឺតាមរយៈព្រះវង្សរបស់ទ្រង់ ។ ក្នុងដំណើររឿងនេះ ក៏មានការធានារ៉ាប់រងក្នុងការយាងមករបស់ព្រះយេស៊ូវគ្រីស្ទ ដ៏ជាព្រះប្រោសលោះ ។

ព្រះគម្ពីរទំនុកដំកើង ៨៩:៣៤-៣៦ក

### ឃ. ការថ្លែងទំនាយដោយហោរាអេសាយ

ហោរាអេសាយបានថ្លែងទំនាយពីការយាងមក របស់ព្រះដ៏ប្រោសលោះ ។

ព្រះគម្ពីរអេសាយ ៩:៦-៧ក

## ង. អ្នកជំនួសរបស់យើង

អំពើបាប និងសេចក្តីស្លាប់ គឺជាលទ្ធផលនៃការទាស់ទទឹងរបស់លោកអ័ដាម និងនាងអេវ៉ា ។ គឺមានតែតាមរយៈការយាងមករបស់លោកអ័ដាមចុងក្រោយ ដ៏ជាអ្នកជំនួសរបស់យើងរាល់គ្នា ដែលយើងអាចនឹងរួចខ្លួនពីភាពមានទាសទាំងនេះ ។ នៅជំពូកជាបន្តបន្ទាប់នឹងផ្តល់ឱ្យយើងនូវរូបភាពដ៏អស្ចារ្យនៃការយាងមករបស់ព្រះដ៏ប្រោសលោះនោះ ។

ព្រះគម្ពីរអេសាយ ៥៣:៤-៥

តាមរយៈការងារប្រោសលោះដែលជាអ្នកជំនួស គឺជាការយាងមករបស់ព្រះមែស៊ី គឺគ្រប់ការទាំងអស់ដែលលោកអ័ដាម និងនាងអេវ៉ាបានបាត់បង់ក្នុងការធ្លាក់ចុះ នោះនឹងត្រូវបានទទួលនូវការកែជាថ្មីឡើងវិញ ។ ម្យ៉ាងទៀត មនុស្សជាតិអាចនឹងបានត្រឡប់មកជាបានកើតជាថ្មីឡើងវិញ ហើយមាននៅផង ។ ការកើតជាថ្មី គឺត្រូវបានទទួលនូវការកែជាថ្មីឡើងវិញ ដែលមានភាពពេញបាន! ព្រះទ្រង់បានគង់នៅក្នុងការជាថ្មីឡើងវិញនោះ ដើម្បីឱ្យយើងទាំងអស់គ្នាដែលបានទទួលការបាត់បង់ទៅនោះ ។

# ក្រុមពិភាក្សា

១. ចូរចែកចាយពីគំនិតរបស់លោកអ្នក ទៅលើជីវិតរបស់ព្រះ និងពីរបៀបបន្ថែមទៀត ដែលសម្តែងពីការមានជីវិតរស់នៅ ។

២. ចូរពិភាក្សាពីការផ្សេងគ្នារវាងពាក្យ "ផ្សូជេ" និង ពាក្យ "ហ្សូ" (ធម្មជាតិ/ជីវិតរបស់មនុស្ស) និង (ជីវិត និងធម្មជាតិរបស់ព្រះអង្គទ្រង់) “Psuche” និង “Zoe” ។

៣. ចូរគិត និងជជែកគ្នាអំពីអ្វីដែលជាការប្រកបដ៏គ្រប់លក្ខណ៍ ជាមួយនឹងព្រះ ឱ្យបានដូចជាពីមុនការធ្លាក់ចុះ ។

# ការសិក្សាដោយខ្លួនឯង

១. បើមិនបានក្រឡេកមើលទៅឯការកត់ត្រារបស់លោកអ្នក អំពីផ្នែកទាំងបី នៃភាពជាត្រែងករបស់លោកអ្នក ដែលមាននៅនោះ:

ក. តើមានអ្វីខ្លះ?

ខ. ចូរពណ៌នាពីផ្នែកនៃមុខងារនីមួយៗរបស់វា ។

គ. តើពួកវាមានការទាក់ទងដូចម្តេចខ្លះដែរ?

២. នៅពេលដែលពួកវា បានទទួលនូវការបង្កើតឡើងជាដំបូង ហេតុអ្វីបានជាលោកអ្នកគិតថា ព្រះទ្រង់បានប្រទានឱ្យលោកអ័ដាម និងនាងអេវ៉ានូវអំណាចគ្រប់គ្រង និងសិទ្ធិអំណាចលើភពផែនដីទាំងមូល?

៣. តើអត្ថន័យនៃការសម្តែងជាបន្តបន្ទាប់ នោះគឺជាអ្វីទៅ: "តើព្រះទ្រង់គង់នៅក្នុងការសម្រេច នូវការកែយើងជាថ្មីគ្រប់ទាំងអស់ដែលយើងមានការបាត់បង់នោះឬ"?

# រូបភាពនៃការកើតជាថ្មី

## មេរៀនទី ២: *យើងមានរូបភាពរបស់ព្រះវរបិតា*

ដើម្បីឱ្យបានយល់ នូវរូបភាពនៃការកើតជាថ្មីរបស់យើង នោះយើងត្រូវតែមានការបើកសម្តែង របស់ព្រះដ៏ជាព្រះវរបិតា ។ ចាប់តាំងពីយើងត្រូវបានបង្កើតនៅក្នុងរូបភាពព្រះអង្គ នោះយើងមិនដែលបានយល់អ្នកដែលបានបង្កើតឱ្យមាននៅ រហូតដល់យើងមានរូបភាពពិតរបស់ព្រះវរបិតានោះទេ ។

លោកសាវ័កប៉ុលបានសរសេរទុកមកថា នៅពេលដែលយើងបានស្ថិតនៅក្នុងសិរីល្អរបស់ព្រះ នោះយើងនឹងត្រូវបានទទួលនូវការកែប្រែរូបភាព ចូលទៅក្នុងរូបភាពដូចនោះឯង ។ គឺជាការបើកសម្តែងដែលនាំមក នូវការកែប្រែរូបភាពនោះឯង ។

ព្រះគម្ពីរ២កូរិនថូស ៣:១៨

នៅក្នុងមេរៀននេះ យើងមានបំណងនឹងស្ថិតនៅក្នុងសិរីល្អរបស់ព្រះវរបិតា ។ យើងមានបំណងបដិសេធនូវរូបភាពដែលខូចនោះទេ គឺយើងអាចមានរូបភាពរបស់ព្រះវរបិតានោះវិញ ។ យើងមានបំណងនឹងបើកឱ្យព្រះវិញ្ញាណបរិសុទ្ធ ដោយការបើកសម្តែងពីព្រះបន្ទូលរបស់ព្រះ ដើម្បីឱ្យទ្រង់បានបើកសម្តែងនូវរូបភាពពិត នៃព្រះដ៏ជាព្រះវរបិតាជាទីស្រឡាញ់របស់យើង ដែលគង់នៅស្ថានសួគ៌ ។

### I. ចលនាទាំងបីនៃព្រះវិញ្ញាណ

### ក. ព្រះយេស៊ូវទ្រង់ជាមនុស្ស

នៅក្នុងសកម្មភាពជាមនុស្សរបស់ព្រះយេស៊ូវ មានមនុស្សជាច្រើនបានទទួលនូវការបើកសម្តែងថ្មីៗ ហើយក៏បានចូលមកក្នុងការទាក់ទង និងការប្រកបស្និទ្ធស្នាលជាមួយនឹងភាពជាមនុស្សរបស់ព្រះយេស៊ូវ ។

### ខ. ផ្នែកការិសម៉ាទិក

នៅក្នុងការផ្លាស់ប្រែជាថ្មីផ្នែកការិសម៉ាទិក គឺមានមនុស្សជាច្រើនបានចូលមកក្នុងការទំនាក់ទំនង និងការប្រកបជាមួយនឹងភាពជាមនុស្សរបស់ព្រះវិញ្ញាណបរិសុទ្ធផងដែរ ។

រីឯមនុស្ស ដែលបានទទួលនូវការដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ ពួកគេតែងតែបានចាប់យកសៀវភៅចម្រៀងទំនុកតម្កើងចាស់ៗ និងត្រូវបានទទួលនូវការស្រាវជ្រាវរកនូវសេចក្តីអំណរដែលចូលមកក្នុងការបង្ហុលបង្ហាញ ពីព្រះគម្ពីរនូវការសរសើរតម្កើងដល់ព្រះយេស៊ូវ ។

ស្តេចដាវីឌ បានចង្អុលបង្ហាញពីការនេះសម្រាប់យើងរាល់គ្នា គឺនៅពេលដែលទ្រង់បានសរសេរ ។

ព្រះគម្ពីរទំនុកដំកើង ១០០:៤

### គ. ការស្គាល់ព្រះវរបិតា

នៅក្នុងចលនាព្រះវត្តមានរបស់ព្រះ មុនពេលដែលព្រះយេស៊ូវទ្រង់យាងមកវិញក្នុងពេលឆាប់ៗនេះ នោះយើងមានបំណងនឹងមកក្នុងការទំនាក់ទំនង និងការប្រកបស្និទ្ធស្នាលជាមួយនឹងព្រះដ៏ជាព្រះវរបិតា ។ យើងមានបំណងនឹងឱ្យបានត្រឡប់មកជាអ្នកថ្វាយបង្គំដល់ព្រះអង្គ ។

យើងបានច្រៀងសរសើរតម្កើង បានលើកដៃឡើង បានទះដៃ បានស្រែក បានលោតរាំ នៅចំពោះព្រះអម្ចាស់ ក្នុងទីលានរបស់ទ្រង់ ។ ទ្រង់ជាយ៉ាងណាក៏ដោយ ឥឡូវនេះ មានការចូលមក ដោយនូវការសម្រេចចិត្តចូលទៅក្នុងព្រះវត្តមាននៃព្រះវរបិតានៅក្នុងទីដ៏បរិសុទ្ធបំផុត គឺចូលទៅខាងក្នុងនៃវាំងននេ ។

មិនយូរប៉ុន្មាន យើងបានចម្អែតនៅក្នុងទីលាននោះ ។ យើងបានចំណាយពេលយូរ ដើម្បីឱ្យបានឃើញព្រះវរបិតាមុខទល់នឹងមុខ ឱ្យបានមើលឃើញព្រះភក្រ្តទ្រង់ គឺឱ្យបានឃើញព្រះហស្តដ៏ជាទីស្រឡាញ់របស់ទ្រង់ ដែលកំពុងតែឱបយើង ហើយដើម្បីឱ្យបានត្រឡប់មកជាអ្នកជិតស្និទ្ធ ជាមួយនឹងព្រះអង្គ ក្នុងការថ្វាយបង្គំទ្រង់នោះ ។

ព្រះគម្ពីរយ៉ូហាន ៤:២៣

ព្រះវរបិតាកំពុងតែស្វែងរកអ្នកថ្វាយបង្គំដ៏ពិតត្រង់ ដែលនឹងចំណាយពេលវេលាក្នុងការថ្វាយបង្គំព្រះអង្គ ដោយវិញ្ញាណ និងសេចក្តីពិត ដែលនឹងចូលទៅក្នុងទីដ៏បរិសុទ្ធនោះ ។

## II. ឪពុករបស់យើងដែលផែនដីនេះ

រូបភាពរបស់យើង គឺជារូបភាពនៃព្រះដ៏ជាព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ គឺតែងតែត្រូវបានសម្រេចដោយនូវបុគ្គលិកលក្ខណៈ នៃឪពុកទាំងឡាយដែលរស់នៅលើផែនដីនេះ ។ ភាពទំនាក់ទំនងរបស់យើងជាមួយនឹងឪពុករបស់យើង ដែលរស់នៅលើផែនដីនេះ គឺជាការខិតខំប្រឹងប្រែងនូវភាពទំនាក់ទំនងរបស់យើង ជាមួយនឹងព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ ។

### ក.មានការរវល់ខ្លាំង

មានឪពុកជាច្រើន គឺមានការជាប់រវល់ខ្លាំង ដើម្បីធ្វើការចំណាយពេលជាមួយនឹងកូនចៅរបស់គេ គឺដែលពួកគេកំពុងតែមានការរីកលូតលាស់ឡើង ។ រឿងនេះក៏អាចមានហេតុផលល្អៗបំផុតដែរ ប៉ុន្តែ ការនេះគឺទុកឱ្យខ្ញុំមានអារម្មណ៍ជាច្រើនថា "ព្រះទ្រង់ក៏មានការរវល់ជាច្រើនសម្រាប់ខ្ញុំដែរ" ។

### ខ. អ្នកដាក់ពិន័យដ៏តឹងរឹង

ឪពុកខ្លះបានធ្វើការទាក់ទងយ៉ាងអាក្រក់យង់ឃ្នង ចំពោះកូនចៅរបស់ពួកគេ ដោយប្រើការដាក់ពិន័យដ៏តឹងរឹងបំផុត ដែលមិនបានបង្ហាញនូវសេចក្តីស្រឡាញ់សោះ ។ ពួកកូនទាំងនេះក៏តែងតែមានអារម្មណ៍ទៅឯព្រះវរបិតារបស់ពួកគេ ដែលគង់នៅស្ថានសួគ៌ ថាមានការឃ្លាំមើលដ៏តឹងរឹងដែរ គឺជាការមិនចូលចិត្តឱ្យយើងមើលចំព្រះភក្រ្តរបស់ទ្រង់នោះដែរ គឺដូចជាទ្រង់កំពុងតែមានព្រនង់នៅជាប់ក្នុងព្រះហស្ត រង់ចាំតែអ្នកណាម្នាក់ដែលចង់ចេញពីជួរដូច្នោះដែរ ។

### គ. ការខ្វះសេចក្តីស្រឡាញ់

មានមនុស្សជាច្រើនដែលបានធំឡើងនៅក្នុងផ្ទះ គឺជាកន្លែងដែលមានសេចក្តីស្រឡាញ់ ឬក៏មានការប្រុងប្រយ័ត្នដ៏តិចតួចណាស់ ដែលពួកគេបានទទួលពីឪពុករបស់ពួកគេនោះមិនជាបញ្ហាអ្វីទេ ដែលពួកគេបានព្យាយាមដោយលំបាកយ៉ាងនោះ គឺវាហាក់ដូចជាពួកគេមិនដែលមានលទ្ធភាពនឹងទទួលបាននូវការឯកភាព ឬការទទួលស្គាល់ពីឪពុករបស់ពួកគេ ទាល់តែសោះនោះអញ្ចឹង ។

ចំពោះរឿងទាំងនេះ គឺជារូបភាពនៃព្រះវរបិតារបស់ពួកគេ ដែលគង់នៅស្ថានសួគ៌ គឺជាម្នាក់ដែលមិនដែលបានមានការឯកភាពអ្វី ឬក៏មានការព្រងើយកន្តើយចំពោះសេចក្តីត្រូវការរបស់ពួកគេ ។ ពួកគេក៏មានអារម្មណ៍ថា ព្រះទ្រង់មិនបានយកព្រះទ័យទុកដាក់ទទួលស្គាល់ ហើយដែលទ្រង់មិនមានសេចក្តីស្រឡាញ់ពិតប្រាកដដល់ពួកគេជាដើម ។

### ឃ. ភាពទ័លក្រ

រឿងដទៃទៀតគឺត្រូវបានលើកឡើង នៅក្នុងក្រុមគ្រួសារ គឺជាកន្លែងដែលឪពុករបស់ពួកគេមិនអាច ឬមិនបានផ្តល់ឱ្យនូវ

ចំណូលឱ្យបានគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ឱ្យបានសមរម្យ ដល់ក្រុមគ្រួសារ តាមសេចក្តីត្រូវការជាមូលដ្ឋាននៃការរស់នៅរបស់ពួកគេជាដើម ។ ពួកគេបានធំឡើងនៅក្នុងភាពទ័លក្រ ។ មនុស្សទាំងនេះគឺតែងតែមាន "រូបភាពនៃការទ័លក្រ" នៅក្នុងព្រះនោះជានិច្ច ។ ពួកគេមានសេចក្តីជំនឿដ៏ស្ងួចស្ដើងថា ព្រះទ្រង់នឹងប្រទានពរដល់សេចក្តីត្រូវការ ក្នុងការរស់នៅរបស់ពួកគេនោះ ។

## ង.ការរំលោភបំពាន

មានកូន១ជាច្រើនបានទទួលនូវការរំលោភបំពាន ពីឪពុករបស់ពួកគេនៅលើផែនដីនេះ ។ មានអ្នកខ្លះបានទទួលនូវការរំលោភបំពានខាងផ្នែកអារម្មណ៍ អ្នកខ្លះទៀតបានទទួលខាងផ្នែករូបកាយ ហើយក៏មានអ្នកខ្លះទៀតបានទទួលនូវការរងទុក្ខចុកចាប់ខាងផ្នែកផ្លូវភេទ ដែលធ្វើឱ្យមានរបួសផងដែរ ។

ការនេះគឺបានធ្វើឱ្យពួកគេមានការការពារ ពីការទាំងអស់នេះ ក្នុងការទុកចិត្តយ៉ាងពេញទីទៅលើព្រះដ៏ជាព្រះវរបិតា ដើម្បីឱ្យបានទទួលនូវសេចក្តីស្រឡាញ់ និងការអត់ឱនដ៏ធំធេងរបស់ទ្រង់ ។ ពួកគេមានអារម្មណ៍ថា នៅជាប់មានទោសចំពោះព្រះ ឬក៏មានសេចក្តីកំហឹងចំពោះព្រះអង្គជាដើម ហើយពួកគេក៏គ្មានលទ្ធភាពនឹងទុកចិត្តលើព្រះអង្គ ឱ្យបានពេញលេញ នៅក្នុងការរស់នៅរបស់ពួកគេ ។

## III. ព្រះវរបិតានៃយើងដែលគង់នៅស្ថានសួគ៌

## ក. សេចក្តីស្រឡាញ់

យ៉ាងហោចណាស់នៅក្នុងការឈឺចាប់ ការបដិសេធនឹ ឬក៏ការរំលោភ ដែលយើងបានទទួលមកពីឪពុករបស់ដែលរស់នៅលើផែនដីនេះ គឺយើងត្រូវតែមានការអត់ទោសដល់ពួកគេ ហើយទទួលយកនូវការប្រោសឱ្យជា ដែលមកពីព្រះដើម្បីឱ្យយើងអាចស្គាល់ អាចទទួលយក និងមានសេចក្តីអំណរ គឺជាសេចក្តីស្រឡាញ់ដ៏លើសលុបរបស់ព្រះវរបិតានៃយើង ដែលគង់នៅស្ថានសួគ៌នោះឯង ។ ព្រះគម្ពីរ១យ៉ូហាន ៣:១ក

លោកសាវ័កប៉ុលបានសរសេរថា គ្មានអ្វីណាមួយអាចបំបែកយើងចេញពីសេចក្តីស្រឡាញ់ របស់ព្រះវរបិតាបានឡើយ ។

ព្រះគម្ពីររ៉ូម ៨:៣៨-៣៩

## ខ. ព្រះវរបិតាប្រទានសេចក្តីអំណរមកយើងរាល់គ្នា

ជំនួសឱ្យឪពុកដែលមានការតឹងរឹង មិនមានការខ្វល់ នោះយើងមានព្រះដ៏ជាព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ដែលទ្រង់ស្រឡាញ់យើងរាល់គ្នាជាច្រើនដល់ម្ល៉េះ គឺដែលទ្រង់បានកំពុងតែប្រទានសេចក្តីអំណរមកយើងរាល់គ្នា គឺដោយមានភាពសប្បាយរីករាយ និងមានជាចម្រៀងវិញ ។

ហោរាសេផានា បានពណ៌នាពីផ្លូវរបស់ព្រះយ៉ាងដូច្នេះ ព្រះគម្ពីរសេផានា ៣:១៧ ។

ពាក្យជាភាសាក្រិក ដែលហោរាសេផានាបានប្រើគឺ "សេចក្តីអំណរ" គឺមានន័យជាចម្បងថា "ការលោត" ឬ "ការលោតផ្លោះ" ។ ព្រះទ្រង់ក៏បានមានព្រះទ័យសប្បាយរីករាយនៅក្នុងយើងរាល់គ្នា ដែលជាកូនរបស់ព្រះអង្គ ទ្រង់ក៏បានលោតឡើង លោតចុះ និងរាំដោយសេចក្តីអំណរ ដែលបង្ហាញពីការគាប់ព្រះហឫទ័យដ៏ក្រៃលែងនោះឯង ។

តើមានរូបភាពផ្លែកអ្វីម្ល៉េះទៅហ្ន៎! ដែលព្រះវរបិតាទ្រង់មានយ៉ាងដូច្នេះនោះ! តើព្រះទ្រង់មិនមែនរវល់សម្រាប់យើងទេឬអី ។ ទ្រង់គឺមិនមែនជាអ្នកតឹងរឹង គ្មានសេចក្តីស្រឡាញ់ និងជាអ្នកដាក់ពិន័យតឹងរឹងនោះទេ ។ ទ្រង់ក៏មិនមែនជាអ្នក

ចាប់អារម្មណ៍ក្នុងការដាក់ទារុណ្ណកម្មដល់យើងនោះទេ ។ ទ្រង់កំពុងតែមានសេចក្តីអំណរចំពោះយើង ដោយមានចម្រៀងនោះទេ គឺទ្រង់កំពុងតែលោតឡើងលោតចុះ ដោយអំណរជាមួយនឹងយើងនោះឯង!

### គ.ការបើកចិត្តទៅឯព្រះវរបិតា

សព្វថ្ងៃនេះ សូម្បីតែនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ព្រះទ្រង់កំពុងតែបានប្រើប្រាស់ពួកហោរា ឱ្យបំបែរចិត្តពួកកូនចៅឱ្យទៅឪពុករបស់ពួកគេវិញដែរ ។

ព្រះគម្ពីរម៉ាឡាគី ៤:៥-៦ក

ព្រះទ្រង់កំពុងតែបានបំបែរចិត្តឪពុកទាំងឡាយ មកឯកូនប្រុស-ស្រីរបស់គេ ដែលនៅលើផែនដី ហើយទ្រង់ក៏បានបង្វែរចិត្តកូនប្រុស-ស្រីខាងឯវិញ្ញាណ មកឯព្រះវរបិតាដែលគង់នៅស្ថានសួគ៌ផងដែរ ។

## IV. ការបង្ហាក់នូវការប្រកបទាក់ទង

### ក. អំពើបាប

លោកអ័ដាម និងនាងអេវ៉ា បានមានការប្រកបទាក់ទងដ៏គ្រប់លក្ខណ៍ជាមួយនឹងព្រះ រហូតដល់ពួកគេបានធ្វើបាប ។ ដោយភាពបរិសុទ្ធ និងសេចក្តីសុចរិតរបស់ព្រះ នោះទ្រង់មិនអាចប្រកបទាក់ទងជាមួយនឹងអំពើបាបបានទេ ។ ដោយសារអំពើបាបរបស់យើង នោះសេចក្តីសង្គ្រោះ និងការអត់ទោសក៏ត្រូវបានរើចេញក្នុងមួយរំពេចនោះឯង ។

ភាពទំនាក់ទំនង និងការប្រកបទាក់ទងរបស់យើងជាមួយនឹងព្រះ ដែលកំពុងតែបានតាំងនៅ ប្រសិនបើយើងបានធ្វើបាប នោះសូម្បីតែភាពទំនាក់ទំនងរបស់យើងជាមួយនឹងព្រះ ដែលកំពុងតែមានជាបន្ត នោះក៏ត្រូវបានទទួលនូវការប្រេះឆាទៅវិញដែរ ។ ការប្រកបទាក់ទងនេះ គឺបានត្រឹមតែទទួលនូវការកែជាថ្មីវិញប៉ុណ្ណោះ ដោយការអត់ទោសនូវអំពើបាបរបស់យើងមកពីទ្រង់នោះឯង ។

ព្រះគម្ពីរ១យ៉ូហាន ១:៩

### ខ. ការបដិសេធន៍

មានមនុស្សជាច្រើនដែលបានទទួលនូវការបដិសេធន៍ ពីឪពុករបស់គេនៅលើផែនដីនេះ ។ ពួកគេបានត្រឹមតែទទួលនូវលទ្ធផល ដែលគ្មានការបម្រុងជាមុន ឬក៏គ្មានចំណង់ចង់បាននោះបានចេញមកជាផ្ទៃឡើង ។ ប្រហែលជាឪពុកគ្រាន់តែចង់បានកូនដែលមានភេទផ្សេងពីនោះ ឬក៏ជាកូនដែលពួកគេមិនបានជាមានវិធានការ ទៅតាមការដែលឪពុករបស់ពួកបានរង់ចាំដោយសង្ឃឹមនោះ ។

ទោះជាយ៉ាងណាក៏ដោយ មនុស្សម្នាក់ដែលកំពុងតែមានការរងទុក្ខពីការបដិសេធន៍ណាមួយ ឬពីអារម្មណ៍ដែលដំណោះស្រាយពីការបដិសេធន៍ នោះគឺជាអារម្មណ៍ដ៏ធំដែលមានទុកជាស្លាកស្នាម ដែលបានទុកនៅក្នុងជីវិតរបស់មនុស្សនោះជាដើម ។

មនុស្សទាំងនេះគឺតែងតែមានអារម្មណ៍ថា ព្រះវរបិតារបស់ពួកគេដែលគង់នៅស្ថានសួគ៌ ក៏កំពុងតែបដិសេធពួកគេផងដែរ ។ ពួកគេមានការលំបាកនឹងទទួលសេចក្តីស្រឡាញ់ និងការទទួលស្គាល់មកពីព្រះអង្គ ។ ជួនកាល ក៏តែងតែហាក់ដូចជាមានការរារាំងដល់ពួកគេ ពីការចូលមកឱ្យបានជិត នៅក្នុងការប្រកបជាលក្ខណៈបុគ្គល ជាមួយនឹងព្រះវរបិតារបស់ពួកគេដែលគង់នៅស្ថានសួគ៌ ព្រមទាំងឱ្យបានត្រឡប់មកជាអ្នកថ្វាយបង្គំទ្រង់ដ៏ពិតនោះដែរ ។

មនុស្សដែលមានអារម្មណ៍បដិសេធ នៅក្នុងជីវិតរបស់ពួកគេ នៅគឺត្រូវតែមានការអត់ទោសដល់អស់អ្នកដែលបានបដិសេធដល់ពួកគេនោះ ហើយបន្ទាប់មកចូរទទួលនូវអំណាចចេស្តានៃការប្រោសឱ្យជារបស់ព្រះ ឱ្យចូលទៅក្នុងព្រលឹងរបស់ពួកគេនោះ ។

## គ. ការកោតខ្លាច

ការកោតខ្លាចគឺបានចូលមកក្នុងព្រះវត្តមាន នៃព្រះដ៏ជាព្រះវរបិតា ដែលបានរក្សាមនុស្សជាច្រើនឱ្យបានត្រឡប់មកជាអ្នកថ្វាយបង្គំព្រះអង្គ ដោយសេចក្តីពិតនោះ ។ ទោះជាយ៉ាងណាក៏ដោយ ជំនួសឱ្យនូវការកោតខ្លាចនេះ ព្រះទ្រង់បានអត់ទោសឱ្យយើង គឺជាព្រះវិញ្ញាណដែលបានប្រទានពរ ឱ្យយើងបានជាកូនចិញ្ចឹម គឺដែលយើងចូលមកឯព្រះអង្គបាន និងអាចហៅព្រះអង្គបានថា "ឱអប្បា ព្រះវរបិតាអើយ!"

ព្រះគម្ពីររ៉ូម ៨:១៥

ពាក្យថា "អប្បា" គឺជាការចង្អុលបង្ហាញទៅលើពាក្យសម្ដីថ្នាក់ថ្នមដែលជិតដឹត ជាភាពទំនាក់ទំនងជាលក្ខណៈបុគ្គលជាមួយនឹងព្រះវរបិតារបស់យើង ។ វាអាចទទួលនូវការបកប្រែថា "លោកឪពុក" “Daddy.” ។

ព្រះគម្ពីរ ២កូរិនថូស ៦:១៨

វាបានត្រឹមតែជាសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅ របស់ព្រះវរបិតាដល់យើងរាល់គ្នា ដែលទ្រង់បានធ្វើជាឪពុកចិញ្ចឹមដល់យើង គឺឱ្យយើងបានធ្វើជាកូនរបស់ព្រះអង្គនោះឯង ។

ព្រះគម្ពីរ១យ៉ូហាន ៣:១ក

ការយល់ពីសេចក្តីស្រឡាញ់ដ៏ធំសម្បើមរបស់ព្រះ ដល់យើង ទើបទ្រង់បានដកនូវសេចក្តីភ័យខ្លាចចេញពីយើង ។ នៅក្នុងព្រះគម្ពីរយ៉ូហាន ជំពូក១៤-១៧ ព្រះយេស៊ូវទ្រង់បានសម្តែងពីពាក្យ ព្រះវរបិតា ចំនួន៥០ដង ។ ទ្រង់មានបន្ទូលថា "ខ្ញុំប្រាប់អ្នករាល់គ្នាអំពីព្រះវរបិតាខ្ញុំ និងអំពីសេចក្តីស្រឡាញ់ដ៏ធំឧត្តមរបស់ទ្រង់" ។ ព្រះយេស៊ូវទ្រង់បានសម្តែងពីសេចក្តីស្រឡាញ់របស់ព្រះវរបិតា គឺដែលទ្រង់បានបីទ្រពួកកូនប្រុសស្រីនៅក្នុងព្រះហស្តរបស់ផងទ្រង់ ។

ព្រះគម្ពីរលូកា ១៨:១៦

រហូតមកដល់សព្វថ្ងៃនេះ ព្រះយេស៊ូវទ្រង់បានត្រាស់ហៅយើងទាំងអស់គ្នា ដោយព្រះអង្គទ្រង់ផ្ទាល់ ។ ទ្រង់មិនបានបដិសេធអ្នកណាម្នាក់ មិនឱ្យចូលមកឯទ្រង់នោះឡើយ ។ ប្រសិនបើយើងស្រឡាញ់ព្រះអង្គ នោះទ្រង់ និងព្រះវរបិតារបស់ព្រះអង្គ នឹងព្រមគង់នៅជាមួយនឹងយើងហើយ ។ ព្រះវរបិតារបស់ព្រះអង្គទ្រង់ក៏ស្រឡាញ់យើងរាល់គ្នាដែរ ។

ព្រះគម្ពីរយ៉ូហាន ១៤:២៣

យើងនឹងនៅជាមួយនឹងព្រះអម្ចាស់ នៅទីកន្លែងដែលព្រះអង្គទ្រង់គង់នៅ មិនមែននៅឆ្ងាយពីព្រះអង្គឡើយ ។

## ឃ. ស្តេចដាវីឌ: គឺជាគំរូដ៏ល្អ

ស្តេចដាវីឌគឺជាមនុស្សម្នាក់ ដែលមានចិត្តដើរតាមព្រះ ។ ទ្រង់បានសម្រេចចិត្ត ឱ្យបានត្រឡប់ទៅជាអ្នកស្និទ្ធស្នាលជាមួយនឹងព្រះវរបិតារបស់ទ្រង់ដែលគង់នៅស្ថានសួគ៌ ក្នុងការថ្វាយបង្គំនោះ ។ ស្តេចដាវីឌបានសម្រេចចិត្តនៅក្នុងព្រះវត្តមានរបស់ព្រះជារៀងរាល់ថ្ងៃ នៅក្នុងជីវិតរបស់ទ្រង់ ។ ទ្រង់បានសម្រេចចិត្ត នឹងចូលទៅក្នុងព្រះវត្តមានរបស់ព្រះវរបិតាហើយនិងរកបាននូវភាពស្រស់ស្អាតរបស់ព្រះអង្គផងដែរ ។

ព្រះគម្ពីរទំនុកដំកើង ២៧:៤

១. **ថ្វាយការសរសើរ និងការថ្វាយបង្គំ:** ព្រះគម្ពីរទំនុកដំកើង ២៧:៦ក

ស្ដេចដាវីឌបានដឹងពីរបៀបច្រៀងសរសើរ និង របៀបរាំសរសើរនៅចំពោះព្រះអម្ចាស់ នៅក្នុង "ទីលាន" ។ ទោះជាយ៉ាងណាក៏ដោយ ទ្រង់ក៏សម្រេចចិត្តបន្ថែមហើយថែមទៀត ។ ទ្រង់បានសម្រេចចិត្តចូលទៅក្នុងព្រះវត្តមាននៃព្រះវរបិតា ក្នុងការស្វែងរកព្រះភក្ត្រព្រះអង្គ ។ ព្រះគម្ពីរទំនុកដំកើង ២៧:៨

**២. ព្រះទ្រង់បំបាត់នូវការភ័យខ្លាច**

សូម្បីតែស្ដេចដាវីឌ បានសម្រេចចិត្តថ្វាយបង្គំដល់ព្រះវរបិតាច្រើនប៉ុណ្ណាក៏ដោយ គឺនៅពេលដែលទ្រង់បានចាប់ផ្ដើម ចូលទៅក្នុងព្រះវត្តមាននៃព្រះវរបិតា នៅក្នុងការថ្វាយបង្គំដ៏ស្និទ្ធស្នាលនោះ ក៏ទ្រង់បានចូលទៅពីខាងក្រោយ ដោយបំបាត់នូវការភ័យខ្លាចក្នុងមួយ រំពេចភ្លាមៗនោះដែរ ។ ព្រះគម្ពីរទំនុកដំកើង ២៧:៩

**៣. ការបំបាត់ដោយនូវព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ ។**

ស្ដេចដាវីឌ បានរងទុក្ខដោយការបដិសេធនឹមកពីឳពុកដែលនៅលើផែនដីនេះ កាលទ្រង់នៅពីក្មេង ហើយឥឡូវនេះ ដែលមានការបំបាត់នូវការភ័យខ្លាចនោះក៏បានការពារអង្គទ្រង់ ពីការចូលទៅក្នុងព្រះវត្តមាននៃព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ ដោយគ្មានការភ័យខ្លាចដែរ ។

ពេលដែលស្ដេចដាវីឌនៅពីក្មេង នោះមានហោរាម្នាក់ឈ្មោះសាំយូអែល បានមកឯក្រុងបេថ្លេហិម ដើម្បីចាក់ប្រេងតាំងឱ្យធ្វើជាស្ដេចបន្ទាប់ ។ ឳពុករបស់ដាវីឌ បានប្រមូលកូនប្រុសរបស់គាត់ទាំងអស់ឱ្យជួបជុំគ្នា ដោយមានសេចក្ដីសង្ឃឹមទៅលើពួកគេណាមួយថា នឹងត្រូវបានទទួលការចាក់ប្រេងតាំងឡើងឱ្យបានធ្វើជាស្ដេច ។ ដាវីឌមិនទាន់ត្រូវបានទទួលនូវការអញ្ជើញ ឱ្យចូលរួមនៅចំពោះមុខហោរាសាំយូអែល នៅក្នុងថ្ងៃដ៏សំខាន់នោះទេ ។

រឿងនេះហើយ ដែលបានជាពេលវេលាមួយដែលដាវីឌបានចាកចេញ ពីការបដិសេធនឹដ៏ជ្រាលជ្រៅពីលោកឳពុករបស់គាត់ដែលនៅលើផែនដីនេះ ។ រឿងនេះហើយ ដែលបានបង្កើតឱ្យមានភ័យនៅក្នុងចិត្តរបស់ដាវីឌ ដែលគាត់ក៏បានក្លាយទៅជាអ្នកបានទទួលនូវការភ័យខ្លាច ពីព្រះវរបិតាដែលគង់នៅស្ថានសួគ៌ដែរ ។

ដែលគាត់បានសម្រេចចិត្តច្រើនប៉ុណ្ណា ក្នុងការចូលមកក្នុងព្រះវត្តមាន នៃព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ដើម្បីស្វែងរកព្រះភក្ត្ររបស់ទ្រង់នោះ ហើយដើម្បីឱ្យបានសម្លឹងមើល នូវភាពស្រស់ស្អាតរបស់ផងទ្រង់នៅឯទីភ្នំ នោះគាត់នឹងបានចូលទៅក្នុងការថ្វាយបង្គំដ៏ជ្រាលជ្រៅនោះ ការបំបាត់នូវការភ័យខ្លាចនឹងបានបាត់ចេញពីព្រលឹងគាត់ទៅ ។

**៤. ការរួចផុតពីការបដិសេធនឹ**

ដាវីឌអាចយល់បានថា គាត់មានការបដិសេធនឹមកពីឳពុកម្ដាយរបស់គាត់ ។ គាត់បានយល់នូវបញ្ហានោះ បន្ទាប់មក គាត់ក៏បានប្រកាស់ដោយមានកម្លាំងឡើងវិញ ប្រឆាំងទៅនឹងអារម្មណ៏នៃការបដិសេធនឹនោះ ។

ព្រះគម្ពីរទំនុកដំកើង ២៧:១០

នៅពេលមួយរំពេចនោះ ដាវីឌក៏បានដើរយ៉ាងមានការស្វាហាប់ចូលទៅក្នុងព្រះវត្តមានរបស់ព្រះ ។ គាត់ក៏បានក្រឡេកមើលទៅខាងក្នុង ក៏បានឃើញព្រះភក្ត្ររបស់ទ្រង់ និងមានការធ្លាក់ចុះទៅក្នុងសេចក្តីស្រឡាញ់ និងការសុខចិត្តទទួលពីព្រះវរបិតារបស់ទ្រង់ ដែលបានជន់ជោរមកក្នុងវិញ្ញាណរបស់គាត់ ។

ដាវីឌបានដឹងថា គាត់បានទទួលស្នួនសំឡាញ់របស់គាត់ហើយ ។

## V. ព្រះយេស៊ូវទ្រង់បើកសម្តែងពីព្រះវរបិតារបស់ទ្រង់

គោលបំណងដ៏ចម្បងមួយ ចំពោះពេលវេលារបស់ព្រះយេស៊ូវនៅលើផែនដីនេះ គឺក្នុងការបើកសម្តែងពីព្រះវរបិតារបស់ព្រះអង្គ ។ នៅពេលព្រះយេស៊ូវទ្រង់បានបំពេញព្រះរាជកិច្ចនៅលើផែនដីនេះ គឺបានចូលមកដល់ថ្ងៃចុងបំផុត ហើយគឺក្នុងពេលមួយរំពេចនោះ ហើយមុនពេលដែលព្រះអង្គត្រូវបានគេចោទប្រកាន់ គេល្បងល និងគេចាប់ចងដល់ទ្រង់ នោះព្រះយេស៊ូវទ្រង់បានសម្តែងពីព្រះវរបិតា ចំនួន៥០ដងនៅ ក្នុងព្រះគម្ពីរ យ៉ូហាន ជំពូកទី១៤-១៧ ។

ទ្រង់មានបន្ទូលទៅកាន់សិស្សព្រះអង្គថា ដល់ពេលហើយៗ "ខ្ញុំចង់ឱ្យអ្នករាល់គ្នាបានស្គាល់ព្រះវរបិតាខ្ញុំ!" ព្រះយេស៊ូវទ្រង់សព្វព្រះហឫទ័យឱ្យយើងបានដឹងថា យើងត្រូវបានទទួលស្នួនសំឡាញ់ហើយ ។ ព្រះគម្ពីរអេភេសូរ ១:៦ ។

## VI. កូនពៅវង្វេង

យើងតែងតែមានការប្រៀបពីកូនពៅដែលវង្វេង គឺដែលត្រូវបានប្រើនៅក្នុងព្រះបន្ទូលដំណឹងល្អ ដែលត្រូវបានហៅថាជាការប្រែចិត្ត ឬជាការកែជាថ្មីឡើងវិញ នៅក្នុងការប្រកប ។ យើងបានយល់ថា យើងអាចចូលមកឯព្រះវរបិតាដោយគ្មានបញ្ហា ដែលបានធ្លាក់ចុះទៅជ្រៅប៉ុណ្ណានោះឡើយ ។ ចំពោះការបះបោរ ដែលកូនពៅវង្វេងបានចាកចេញពីផ្ទះ ហើយបានចាយវាយយ៉ាងខ្ជះខ្ជាយ នូវទ្រព្យសម្បត្តិទាំងអស់របស់គាត់ ដែលគាត់ត្រូវធ្លាក់ចុះទៅក្នុងជីវិតដ៏សែនអាក្រក់នោះ ។ បន្ទាប់មកទៀត នៅពេលដែលគាត់ត្រូវធ្លាក់ចុះទៅជាអ្នកបម្រើ ដែលត្រូវអត់បាយក្រហាយទឹក ហើយចុងក្រោយគាត់ក៏បានក្លាយជាអ្នកឃ្វាលជ្រូក ចិញ្ចឹមជ្រូក ហើយគាត់ក៏ចង់ចម្អែតពោះនឹង ចំណីជ្រូកនោះណាស់ ។

### ក. កូនពៅ

មានស្ទើរតែគ្រប់គ្នាក្នុងចំណោមយើង ដែលអាចមានឈ្មោះថា ជាកូនពៅនោះ ។ យើងបានចាកចេញ ឬក៏អាចមានអារម្មណ៍ថា ធ្វើឱ្យលែងជិតស្និទ្ធពីព្រះវរបិតានៃយើងដែលគង់នៅស្ថានសួគ៌ ដែលមានពេញទៅដោយការភ័យខ្លាចមានការបដិសេធនឹ ឬក៏មានពេញទៅដោយអារម្មណ៍ថា គ្មានតម្លៃមានវិប្បដិសារី និងមានការជាប់ទោសជាដើម ។

ព្រះគម្ពីរលូកា ១៥:១៧-២០ក

គាត់បានពោលថា "ខ្ញុំគ្មានតម្លៃតទៅទៀតទេ" ។ អ្នកកម្លោះនេះ សូម្បីតែមានអ្នកជឿជាច្រើននៅសម័យសព្វថ្ងៃនេះក៏ដោយ ក៏មានការធ្លាក់ចុះទៅក្នុងភាពគ្មានតម្លៃនេះដែរ ។ គាត់មានរូបភាពដែលគ្មានតៃម្លដោយខ្លួនគាត់ផ្ទាល់ ។ ប៉ុន្តែសូម្បីតែជាមួយនឹងរូបភាពអាត្មានិយមនោះ ក៏ធ្វើឱ្យគាត់បានវិលត្រឡប់មកផ្ទះវិញដែរ ។

### ខ. លោកឪពុក

ការប្រៀបធៀបនេះគឺជាការបើកសម្តែង ដែលមានពេញ

ដោយការឆ្លល់ដែរ អំពីព្រះវរបិតានៃយើងដែលគង់នៅស្ថានសួគ៌នោះ ។

**១. ព្រះទ្រង់មិនមែនជាអ្នកជំនុំជម្រះទេ ។**

**២. ទ្រង់មិនមែនជាអ្នកកំណាចឃោរឃៅនោះទេ ។**

**៣. ទ្រង់មិនមែនរង់ចាំឱ្យកូនប្រុស-ស្រី ទៅជាអ្នកសុំទាន ហើយបានអត់ទោសឱ្យនោះដែរ ។**

តើអ្វីខ្លះដែលព្រះយេស៊ូវទ្រង់មានបន្ទូលថា ទ្រង់បានធ្វើ?

ព្រះគម្ពីរលូកា ១៥:២០ខ

ជំនួសឱ្យនូវការវិលត្រឡប់វិញរបស់វរបិតានៃយើង នោះទ្រង់បានបែរព្រះភក្ត្រចេញពីពួកយើង ដោយមានការបដិសេធនីវិញ នោះគឺទ្រង់កំពុងតែរង់ចាំយើងឱ្យវិលត្រឡប់មករកព្រះអង្គវិញនោះឯង ។ ទ្រង់សព្វព្រះហឫទ័យនឹងដាក់ព្រះហស្តមកឱបយើង ហើយនិងថើបយើងដែលបង្ហាញពីសេចក្តីស្រឡាញ់ដ៏ធំឧត្តម និងដ៏លើសលុបរបស់ទ្រង់នោះឯង ។

ព្រះគម្ពីរលូកា ១៥:២១

ចំពោះលោកឪពុកមិនបានសូម្បីតែពិភាក្សាគ្នា ពីអ្វីដែលនាំឱ្យមានបញ្ហានេះជាមុនសិននោះទេ ឬក៏ពិភាក្សាពីអ្វីដែលកូនប្រុសបាននិយាយនោះទេ ។

ព្រះគម្ពីរលូកា ១៥:២២-២៤

## គ.រូបភាពរបស់កូនពៅ

លោកឪពុកបានដឹងថា គាត់បានធ្វើការផ្លាស់ប្រែពីរូបភាពផ្ទាល់ខ្លួននៃកូនប្រុសរបស់គាត់នោះហើយ ។ គាត់បានធ្វើការបំពាក់សម្លៀកបំពាក់ដ៏ប្រណីត ឱ្យដល់កូនពៅនោះ ហើយគាត់ក៏បានបំពាក់ចិញ្ចៀន និងស្បែកជើងថ្មីមួយគូបំពាក់លើជើងរបស់គាត់ ។

ម្យ៉ាងទៀត យើងបានទទួលព្រះយេស៊ូវធ្វើជាព្រះអង្គសង្គ្រោះរបស់យើង នោះព្រះវរបិតានៃយើងដែលគង់នៅស្ថានសួគ៌ ទ្រង់បានថែរក្សាយើងដែលជាកូនប្រុសកូនស្រីនោះឯង ។ យើងរាល់គ្នាត្រូវបានទទួលការស្លៀកពាក់ឱ្យ ដោយសម្លៀកបំពាក់នៃសេចក្តីសុចរិតរបស់ផងទ្រង់ ។ យើងក៏មានចិញ្ចៀននៃសិទ្ធិអំណាចរបស់ផងទ្រង់ ដែលបានបំពាក់លើដៃរបស់យើងផងដែរ ។

ដោយនូវសេចក្តីស្រឡាញ់ ទ្រង់បានមានបន្ទូលថា "ឱតើអញចង់ឱ្យពួកគេស្គាល់អ្នក ដែលពួកគេត្រូវនៅក្នុងព្រះយេស៊ូវគ្រីស្ទយ៉ាងណាទៅហ្ន៎! ពួកគេគឺបានមកជាតែមួយនៅក្នុងព្រះរាជបុត្រារបស់អញហើយ! ពួកគេបានរាប់ជាសុចរិតរបស់ព្រះ ដែលនៅក្នុងព្រះយេស៊ូវគ្រីស្ទទៅអេះ!"

លោកសាវ័កប៉ុលបានសរសេរពីរឿងនេះ ។

ព្រះគម្ពីរ ២កូរិនថូស ៥:២១

## VII. ការបំផ្លាស់បំប្រែ

## ក. រូបភាពនៃការកើតជាថ្មីរបស់យើង

នៅពេលដែលយើងបានយាងព្រះយេស៊ូវ ឱ្យទ្រង់បានបើកសម្តែងពីព្រះវរបិតារបស់ទ្រង់មកឯយើង នោះគឺជាការដែលធ្វើឱ្យមានការរមូលគ្រេចណាមួយ ឬក៏ជារូបភាពនៃការកំណត់ដែលយើងមានព្រះវរបិតានៃយើង ដែលគង់នៅស្ថានសួគ៌ទ្រង់នឹងរធ្វើការបំផ្លាស់បំប្រែ ។

យើនឹងបានដូចជាស្តេចដាវីឌ ដែលបានសម្លឹងមើលនូវភាពស្រស់ស្អាតរបស់ព្រះអម្ចាស់ ។ យើងនឹងស្វែងរកព្រះភក្ត្រទ្រង់ ។ យើងនឹងបានត្រឡប់មកជាអ្នកថ្វាយបង្គំដល់ទ្រង់ ហើយយើងនឹងមានអារម្មណ៍ថា ទ្រង់ព្រមទទួលយើងទាំង

អស់គ្នា ។ នៅពេលដែលយើងសម្លឹងមើលទៅសិរីល្អរបស់ព្រះអម្ចាស់ នោះរូបភាពរបស់យើង ព្រះទ្រង់នឹងបានបំផ្លាស់បំប្រែ ហើយនៅពេលដដែលនោះ រូបភាពអាត្មានិយមចាស់របស់យើង នឹងត្រូវបានបំផ្លាស់បំប្រែឱ្យទៅជារូបភាពនៃការកើតជាថ្មីនោះឯង ។ មានមនុស្សជាច្រើនបានធ្វើការស្វែងរកព្រះហស្តរបស់ព្រះ ជំនួសឱ្យការស្វែងរកព្រះភក្ត្ររបស់ទ្រង់វិញ ។ ពួកគេបានចំណាយពេលវេលា ក្នុងការត្រឡប់មកឯព្រះដើម្បីឱ្យបានទទួលនូវសេចក្តីត្រូវការផ្ទាល់របស់គេដែលគេចង់ជួប ។

## ខ. ការបំផ្លាស់បំប្រែ

១. តាមការស្វែងរកព្រះវរបិតា

ជំនួសឱ្យនូវការដែលយើងត្រូវតែចូលមកឯព្រះ និងបានចំណាយពេល ក្នុងការស្វែងរកព្រះភក្ត្ររបស់ទ្រង់ ព្រមទាំងជាការសម្លឹងមើលទៅឯសិរីល្អរបស់ផងទ្រង់ ។ បន្ទាប់មក យើងនឹងបានទទួលនូវការបំផ្លាស់បំប្រែ ចូលទៅក្នុងរូបភាពរបស់ព្រះអង្គ ។

ព្រះគម្ពីរ ២កូរិនថូស ៣:១៨

ស្តេចដាវីឌគឺជាអ្នកនិពន្ធព្រះគម្ពីរទំនុកដំកើង បានបញ្ជាក់បង្ហាញ នូវគំនិតដូចគ្នានឹងលោកសាវ័កប៉ុលដែរ ។ ព្រះគម្ពីរទំនុកដំកើង ១៧:១៥

២. តាមរយៈការថ្វាយបង្គំព្រះវរបិតា

យើងមិនបានទទួលនូវការបំផ្លាស់បំប្រែ ចូលទៅក្នុងភាពដូចរបស់ផងទ្រង់ ដោយការសម្លឹងរកមើលដោយខ្លួនឯង និងការសម្រេចចិត្តដែលជាការបំផ្លាស់បំប្រែ ដើម្បីចាប់យកកន្លែងនៅក្នុងជីវិតរបស់យើងរាល់គ្នា ។ យើងបានទទួលនូវ ការផ្លាស់ប្រែចូលទៅក្នុងភាពដូចរបស់ទ្រង់ ដែលយើងបាន ចំណាយពេលជាមួយនឹងព្រះវរបិតារបស់យើងបាន ដោយនូវសេចក្តីស្រឡាញ់ និងការថ្វាយបង្គំដ៏ស្និទ្ធស្នាលដល់ទ្រង់ សម្រាប់អស់អ្នកណាដែលទ្រង់សព្វព្រះហឫទ័យ ។ យើងនឹងចូលមកឱ្យបានដឹង និងជឿថា យើងត្រូវបានទទួលជាអ្នកដ៏ស្ងួនភ្ងារហើយ ។

ព្រះគម្ពីរអេភេសូរ ១:៦

## ក្រុមពិភាក្សា

១. តើការបើកសម្ដែងនាំមកនូវការបំផ្លាស់បំប្រែ ដោយរបៀបណា?

២. បន្ទាប់ពីការសិក្សានូវអត្ថន័យនៃពាក្យ "សេចក្ដីអំណរ" ដែលហោរាសេផានាបានប្រើ តើព្រះវរបិតាទ្រង់បានបំផ្លាស់បំប្រែរូបភាពរបស់លោកអ្នក ដោយរបៀបណាដែរ?

៣. ចូរធ្វើការពិភាក្សាពីព្រះគម្ពីរ ម៉ាឡាគី ៤:៥-៦ក ឱ្យបានជ្រៅជាងនេះបន្ថែមទៀត ។

   ក. តើព្រះកំពុងតែបង្វែរចិត្តរបស់កូនប្រុស-ស្រី និងឪពុកបានដោយរបៀបណា?

   ខ. តើព្រះកំពុងតែប្រើពួកហោរា ឱ្យប្រតិបត្តិការនេះបានដោយរបៀបណា?

## ការសិក្សាផ្ទាល់ខ្លួន

១. តើលោកអ្នកបានចែកជាក្រុមដោយខ្លួនឯង នៅក្នុងចលនានៃការបើកសម្ដែងមកពីព្រះវិញ្ញាណឬទេ?

   ក. ប្រសិនបើដូច្នោះមែន តើក្រុមណាមួយ?

   ខ. តើលោកអ្នកមានអារម្មណ៍ថា លោកអ្នកមានការស្ទះចលនានៅក្រុមណាមួយឬទេ ឬក៏លោកអ្នក មានលទ្ធភាពនឹងសិក្សាឱ្យបានលូតលាស់ ទៅតាមចលនាជាបន្តបន្ទាប់ទៀត?

២. តើរូបភាពរបស់លោកអ្នក ដែលបានមកពីព្រះវរបិតានៃលោកអ្នកដែលគង់នៅស្ថានសួគ៌ បានឆ្លុះបញ្ចាំងលើគ្រប់ទាំងអស់ ដោយបុគ្គលិកលក្ខណៈរបស់ឪពុកលោកអ្នកដែលនៅលើផែនដីនេះ?

   ក. ប្រសិនបើដូច្នោះមែន ចូរធ្វើការសរសេរចុះនូវមធ្យោបាយ ដែលលោកអ្នកស្គាល់ពីរូបភាពរបស់លោកអ្នក ដែលបានមកពីព្រះវរបិតានៃលោកអ្នកដែលគង់នៅស្ថានសួគ៌ នោះបានធ្វើឱ្យមានការប្រេះឆានោះ ។

   ខ. ប្រសិនបើចាប់តាំពីលោកអ្នកបានទទួល នូវការផ្លាស់ប្រែ នូវរូបភាពរបស់លោកអ្នកដែលមានរូបភាពនៃព្រះវរបិតាលោកអ្នក ដែលគង់នៅស្ថានសួគ៌ តើលោកអ្នកបានទទួលនូវ មតិដែលមានពីអតីតកាលដែរឬទេ?

   គ. ប្រសិនបើលោកអ្នកបានធ្វើឱ្យពិតប្រាកដ នោះគឺជាលទ្ធផលដែលបានមកពីមេរៀននេះ ដែលលោកអ្នកមានការភាន់ច្រឡំ ចំពោះរូបភាពនៃព្រះវរបិតារបស់លោកអ្នកដែលគង់នៅស្ថានសួគ៌នោះឯង ចូរអធិស្ឋានឱ្យបានត្រឹមត្រូវនៅ ពេលឥឡូវនេះ ហើយទូលសូមដល់ព្រះសូម ឱ្យទ្រង់បានប្រោសចិត្តរបស់លោកអ្នក និងធ្វើការបំផ្លាស់បំប្រែលោកអ្នក ពីគ្រប់ទាំងរូបភាពដែលមានកំហុសទាំងនោះ ។

# រូបភាពនៃការកើតជាថ្មី

## *មេរៀនទី ៣: រូបភាពនៃការកើតជាថ្មី*

## I. ព្រះរាជបុត្រានៃព្រះ

ដើម្បីបំពេញនូវការបើកសម្តែង ចំពោះអស់អ្នកដែលយើងបានបង្កើតឡើងជាថ្មី នោះយើងត្រូវតែមានការបើកសម្តែងពីរូបភាពរបស់ព្រះរាជបុត្រានៃព្រះ ។ លោកសាវ័កប៉ុលបានសរសេរថា ព្រះទ្រង់បានសម្រេចទុកជាមុនកំណត់ទុក ឬបំបួសយើងឱ្យបានទៅជាអ្នកដែលស្របទៅនឹងរូបភាពរបស់ព្រះរាជបុត្រានៃព្រះ ។

ព្រះគម្ពីររ៉ូម ៨:២៩ក

នៅពេលដែលយើងត្រូវបានស្របទៅនឹងរូបភាពរបស់ព្រះរាជបុត្រានៃទ្រង់ហើយ នោះយើងនឹងបានចាប់ផ្តើមបានពេញលេញជាសក្តានុពល និងរស់នៅជាអ្នកដែលបានកើតជាថ្មីនោះ។ យើងស្គាល់ព្រះយេស៊ូវថា ទ្រង់ជាមួយអង្គដែលគង់នៅជាមួយព្រះវរបិតា និងជាមួយព្រះវិញ្ញាណបរិសុទ្ធ ហើយដែលគ្រប់ទាំងការកំណត់ដែលពួកគេមាន នោះយើងក៏មានដែរ ។

### ក. ទ្រង់គឺជាព្រះ

លោកសាវ័កយ៉ូហានប្រាប់យើងពីការសំខាន់ៗ ៤យ៉ាងអំពីព្រះរាជបុត្រានៃព្រះ:

១. ទ្រង់មានព្រះវត្តមានជានិច្ច ។

២. ទ្រង់ជាព្រះបន្ទូលដ៏រស់របស់ព្រះ ។

៣. ទ្រង់គឺជាអ្នកបង្កើតគ្រប់របស់ទាំងអស់ ។

៤. ទ្រង់បានត្រឡប់មកជាសាច់ឈាម ហើយបានស្នាក់នៅជាមួយយើងរាល់គ្នា ។

ព្រះគម្ពីរយ៉ូហាន ១:១-៣,១៤

### ខ. ទ្រង់បានបង្កើតលោកអ័ដាម និងនាងអេវ៉ា

លោកយ៉ូហានបានបញ្ជាក់ពីការនេះយ៉ាងច្បាស់ថា គ្រប់ទាំងអស់ គឺរួមទាំងលោកអ័ដាម និងនាងអេវ៉ា ត្រូវបានបង្កើតមកដោយសារទ្រង់ គឺជាព្រះរាជបុត្រានៃព្រះ ។

ព្រះគម្ពីរលោកុប្បត្តិ ១:២៧

## II. ព្រះយេស៊ូវទ្រង់គឺជាអត្តសញ្ញាណរបស់យើង

### ក. តែមួយជាមួយនឹងទ្រង់

តែមួយប៉ព្រិចភ្នែកប៉ុណ្ណោះ យើងបានដាក់សេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវ ធ្វើជាព្រះអង្គសង្គ្រោះរបស់យើង និងមានការអស្ចារ្យបានកើតឡើង ។ ព្រះទ្រង់ដ៏ជាព្រះវិញ្ញាណបរិសុទ្ធ ទ្រង់ក៏បានបង្កើតយើងមកឱ្យបានជាតែមួយជាមួយនឹងព្រះអង្គ ។ យើងបានត្រឡប់មកជារូបកាយរបស់ព្រះអង្គ ។

ព្រះគម្ពីរ ១កូរិនថូស ១២:១៣,១៧

ហេតុផល គឺសម្រាប់ការងារប្រោសលោះរបស់អង្គព្រះយេស៊ូវ គឺមិនមែនសម្រាប់តែមួយគ្រាៗនោះទេ គឺយើងអាចនៅជាមួយនឹងព្រះអង្គនៅឯនគរស្ថានសួគ៌នោះ ។ លោកសាវ័កពេត្រុសក៏បានសរសេរដែរថា ព្រះយេស៊ូវទ្រង់បានប្រទានឱ្យយើងនូវមធ្យោបាយ ដែលយើងអាចរស់នៅដោយមានសេចក្តីសុចរិត ។

ព្រះគម្ពីរ ១ពេត្រុស ២:២២,២៤

### ខ. ទ្រង់បានត្រឡប់មកជាតួបាបជំនួសយើង

នៅក្នុងការងារប្រោសលោះរបស់ព្រះយេស៊ូវ គឺឱ្យបានជាប្រយោជន៍ដល់យើង គឺទ្រង់"បានត្រឡប់មក" ជាតួបាបជំនួស

យើងរាល់គ្នា ។ ទ្រង់មានបំណងនឹងទទួលយកនូវអំពើបាបរបស់យើងដាក់នៅលើរូបអង្គទ្រង់ ជាប់លើឈើឆ្កាង ។

ព្រះគម្ពីរ ២កូរិនថូស ៥:២១

## គ. ទ្រង់បានជាប់ឆ្កាងជំនួសយើង

ព្រះយេស៊ូវទ្រង់បានទទួលយក នូវបណ្តាសាដោយព្រះអង្គ ដែលទ្រង់បានមកជាមនុស្សឈរជាអ្នកមានបាប ។

ព្រះគម្ពីរ កាឡាទី ៣:១៣

## ឃ. ទ្រង់បានដកយកអំពើបាបយើងចេញ

នៅលើឈើឆ្កាង ព្រះយេស៊ូវទ្រង់បានត្រឡប់មកជា "កូនចៀមនៃព្រះដែលដោះបាបមនុស្សលោក" ។ ទ្រង់បានដកយកនូវគ្រប់ទាំងអំពើបាបដ៏សែនក្រាសរបស់យើង ដែលមាននៅលើផែនដីនេះ គឺធ្វើឱ្យយើងបានចងចាំថា យើងគ្មានបាបទៀតឡើយ ជារៀងរហូតតទៅ ។

ព្រះគម្ពីរយ៉ូហាន ១:២៩ និង ព្រះគម្ពីររ៉ូម ៦:៦

## ង. ទ្រង់បានរស់ពីសុគតឡើងវិញ

ទ្រង់បានដកយកអំពើបាបដ៏សែនជ្រៅរបស់យើង នៅលើផែនដីនេះ ទ្រង់បានរស់ពីសុគតឡើងវិញ ទ្រង់ក៏បានឈ្នះលើសេចក្តីស្លាប់ ឈ្នះស្ថាននរក និងចេញពីផ្នូរ ។ ទ្រង់បានត្រឡប់ជាអ្នក "រស់ពីស្លាប់ឡើងវិញជាលើកដំបូងបង្អស់" ។ ព្រះគម្ពីរកូល៉ុស ១:១៨

ទ្រង់ជា "ជីវិតរស់ឡើងវិញ" ដោយព្រះវិញ្ញាណ ។ ព្រះគម្ពីរ ១ពេត្រុស ៣:១៨

នៅពេលដែលព្រះយេស៊ូវ ទ្រង់បានមានជីវិតរស់ឡើងវិញហើយនោះ យើងក៏បានទទួលនូវការបង្កើតឱ្យមានជីវិតឡើងវិញជាមួយនឹងទ្រង់ផងដែរ ពីព្រោះយើងគឺជាតែមួយជាមួយនឹងទ្រង់នោះហើយ ។

## ច.ទ្រង់ធ្វើឱ្យយើងត្រឡប់មកជាសុចរិត

ដោយសារសេចក្តីសង្គ្រោះក្នុងមួយរំពេចនេះហើយ ដែលយើងបានត្រូវទទួលនូវការប្រទានឱ្យ នូវសេចក្តីសុចរិតរបស់ផងព្រះយេស៊ូវនោះឯង ។ យើងត្រូវបានត្រឡប់មកជាសុចរិតដូចជាព្រះយេស៊ូវទ្រង់សុចរិតនោះដែរ ។

ឥឡូវនេះយើងដែលត្រូវបានបង្កើតឱ្យបានជាសុចរិត នោះយើងត្រូវតែ "រស់នៅសម្រាប់សេចក្តីសុចរិត" ។

ព្រះគម្ពីរ ១ពេត្រុស ២:២៤ក

យើងបានទទួលនូវការបង្កើតឡើងជាថ្មី នៅក្នុងព្រះគ្រីស្ទយេស៊ូវហើយ គឺយើងមិននៅជាប់ជាអ្នកមានបាបតទៅទៀតទេ ។ យើងត្រូវបានទទួលនូវការរាប់ជាសុចរិតហើយ!

ព្រះគម្ពីរ ២កូរិនថូស ៥:១៧

យើងមិនត្រូវការរស់នៅ ក្រោមភាពមានទោស និងនៅក្រោមការផ្តន្ទាទោសតទៅទៀតទេ ។ យើងត្រូវបានទទួលនូវការបង្កើតឱ្យបានជាសុចរិតហើយ!

យើងមិនត្រូវបានជីតជាប់នៅក្នុងអារម្មណ៍ថា នៅតែមានបាបតទៅទៀតទេ ។

យើងត្រូវមានអារម្មណ៍ជីតជាថាបានរាប់ជាសិចរិតហើយ ។

យើងមិនត្រូវអនុញ្ញាតឱ្យសាតាំងដាក់យើងនៅក្រោមការបរាជ័យនោះឡើយ ។

យើងដឹងថា "យើងត្រូវបានរាប់ជាសុចរិតនៅចំពោះព្រះក្នុងព្រះយេស៊ូវគ្រីស្ទ" ។

យើងបានរួចខ្លួនពីភាពមានទោស និងការផ្តន្ទាទោសនោះហើយ ។ ព្រះគម្ពីររ៉ូម ៨:១

យើងបានទទួលនូវការកើតជាថ្មី ក្នុងព្រះគ្រីស្ទហើយ!

វិញ្ញាណរបស់យើងគឺបានរាប់ជាសុចរិត ពីព្រោះព្រះទ្រង់សុចរិត ។ ចំពោះមូលដ្ឋានគ្រឹះប្រចាំថ្ងៃ ព្រលឹងនិងរូបកាយរបស់យើង គឺត្រូវបានទទួលនូវការសម្រេចទៅនឹងរូបកាយនៃព្រះរាជបុត្រារបស់ព្រះអង្គហើយ!

## III. ការនៅក្នុងព្រះគ្រីស្ទ

តាមរយៈលោកសាវ័កប៉ុល គឺនៅពេលដែលយើងបានទទួលព្រះយេស៊ូវ ធ្វើជាព្រះអង្គសង្គ្រោះរបស់យើងហើយ នោះយើងគឺបាននៅក្នុងព្រះគ្រីស្ទហើយដែរ ។ យើងបានទទួលនូវកំណើតថ្មីហើយ ។ គ្រប់ទាំងអស់ក៏ត្រូវបានត្រឡប់មកជាថ្មីនៅក្នុងជីវិតរបស់យើងដែរ ។

ព្រះគម្ពីរ ២កូរិនថូស ៥:១៧

នៅពេលដែលយើងទទួលព្រះយេស៊ូវ មកធ្វើជាព្រះអង្គសង្គ្រោះរបស់យើងភ្លាម នោះព្រះវិញ្ញាណបរិសុទ្ធទ្រង់ក៏បានយាងមកប្រកបជាមួយនឹងយើង ក្នុងព្រះយេស៊ូវគ្រីស្ទដែរ ។ យើងក៏បានត្រឡប់មកជាតែមួយជាមួយនឹងទ្រង់ ដើម្បីឱ្យបានគ្រប់របស់ទាំងអស់ដែលនៅអស់កល្បជានិច្ចនោះ ។

### ក. គ្រប់របស់ចាស់ៗទាំងប៉ុន្មានបានកន្លងបាត់ទៅ

នៅពេលដែលយើងបានត្រឡប់មកជាអ្នក "នៅក្នុងព្រះគ្រីស្ទ" គ្រប់របស់ចាស់ៗទាំងប៉ុន្មានក៏បានកន្លងបាត់ទៅ ។ ការនោះគឺមានន័យថា ផ្នែករបស់របស់យើងទាំងអម្បាលមាណដែលមានពីមុនមក គឺគ្មានតទៅទៀតឡើយ ។ ផ្នែកទាំងអស់នោះហើយគឺត្រូវបានបំបាក់បំបែកអស់ទៅ "គ្រប់របស់ចាស់ៗទាំងប៉ុន្មាន" គឺត្រូវស្លាប់អស់ទៅ ។ នៅពេលជាមួយគ្នានោះក៏មានកំណើតថ្មីបានត្រឡប់មកវិញ មនុស្សខាងវិញ្ញាណថ្មីក៏បានកើតឡើងវិញ ។

### ខ. គ្រប់របស់ទាំងអស់បានត្រឡប់ជាថ្មីវិញ

អ្នកជឿថ្មីៗ ក៏លែងមានការដឹកនាំចាស់ៗដែលគាត់ឬនាងធ្លាប់បានទទួលពីលើកមុននោះឡើយ ។ មនុស្សចាស់ទាំងនោះគឺគ្មាននៅតទៅទៀតឡើយ ។ គ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញ ។

តើគួរឱ្យមានការប្លែកយ៉ាងណាទៅហ្ន៎ ដែលនឹងកើតមានឡើងគឺនៅពេលដែលយើងត្រូវបានទទួលជាកូនង៉ែតដែលបានកើតជាថ្មីនោះ មានអ្នកខ្លះបានសួរយ៉ាងដូច្នេះថា "ចុះតើកូនង៉ែតពីមុននោះជាអ្វីទៅ?"

លោកអ្នកត្រូវតែឆ្លើយដូច្នេះថា "កូនង៉ែតនេះគឺទើបតែនឹងកើតទេ ។ ចំណែកកូនង៉ែតមុននោះគឺអត់មានទេ!"

វាដូចជារឿងមុនៗ គឺនៅពេលដែលវិញ្ញាណអាក្រក់បានចូលមករំឭកយើងនូវកំហុស និងអំពើបាបពីអតីតកាលរបស់យើង គឺមុនពេលដែលយើងបានកើតជាថ្មីនោះ ។ ចំណែកនៃជីវិតចាស់របស់យើងនោះ គឺបានកន្លងបាត់ទៅហើយ វាមិនមានជាបន្តទៅទៀតទេ! គឺយើងត្រូវបានកើតជាថ្មីហើយ យើងមិនអាចមានអតីតកាលតទៅទៀតទេ រីឯវិញ្ញាណអាក្រក់វិញ វាចេះតែចោទប្រកាន់ទាស់នឹងយើងហើយ ។ លោកសាវ័កប៉ុលបានសរសេរថា "គ្រប់ទាំងសេចក្តីចាស់បានកន្លងបាត់ទៅហើយ! មើលគ្រប់តាំងអស់បានត្រឡប់ជាថ្មីវិញ"

### គ. ការកើតជាថ្មី

នៅពេលដែលព្រះយេស៊ូវទ្រង់បានមានបន្ទូល ទៅកាន់លោកនីកូដេម នោះទ្រង់មានបន្ទូលថា អ្នកត្រូវតែកើតជាថ្មី ។

ព្រះគម្ពីរយ៉ូហាន ៣:៧

ទីមួយលោកនីកូដេមបានគិតថា ព្រះយេស៊ូវទ្រង់កំពុងតែមានបន្ទូលអំពីសេចក្តីត្រូវការ សម្រាប់រូបកាយរបស់គាត់ ឱ្យបានកើតជាថ្មីនោះវិញ បន្ទាប់មកព្រះយេស៊ូវទ្រង់ក៏បានធ្វើការបញ្ជាក់យ៉ាងច្បាស់លាស់ថា ចំណែកនៃមនុស្សជាតិ ដែលត្រូវតែមានការពិសោធន៍នូវការបានកើតជាថ្មី គឺមិនមែនខាងផ្នែករូបកាយ ឬព្រលឹងនោះទេ ។ នោះគឺគ្រាន់តែជាវិញ្ញាណមនុស្សជាតិតែប៉ុណ្ណោះ ។ រីឯការកើតជាថ្មីនេះ គឺជាវិញ្ញាណរបស់មនុស្សវិញ ។

ព្រះគម្ពីរយ៉ូហាន ៣:៥,៦

## ឃ. វិញ្ញាណថ្មី

នៅពេលដែលយើងបានទទួលសេចក្តីសង្គ្រោះភ្លាម នោះវិញ្ញាណរបស់យើងក៏បានទទួលនូវការកើតជាថ្មីភ្លាមដែរគឺត្រូវបានគ្រប់លក្ខណ៍ ។ វាមិនមែនបានត្រឡប់ទៅជាគ្រប់ ឬទៅជាសុចរិតជាបន្ថែមទៀត ជាជាងមួយរំពេចភ្លាមៗនោះទេ ។

វិញ្ញាណគឺជាផ្នែកមួយរបស់យើង ដែលនឹងរស់នៅជារៀងរហូត ។ វាគឺជាផ្នែកមួយដែលមានមនសិក្ការៈនៃព្រះវត្តមានរបស់ព្រះ ។ វិញ្ញាណរបស់អ្នកជឿគឺជាផ្នែក ដែលអាចប្រកបជាមួយនឹងព្រះ ពីព្រោះវាជាសេចក្តីសុចរិត ដូចជាព្រះទ្រង់ជាសេចក្តីសុចរិតនោះឯង ។

ចំពោះ "ចិត្តដែលរឹងដូចថ្ម" នោះត្រូវកន្លងបាត់ទៅហើយ! ព្រះទ្រង់បានប្រទានឱ្យយើង "មានចិត្តជាសាច់" វិញ ។ ទ្រង់បានប្រទានឱ្យយើងនូវចិត្តដែលទន់ខ្ចី និងមានជាសេចក្តីស្រឡាញ់ ។ ទ្រង់បានប្រទានឱ្យយើងនូវចិត្តដែលមានការសម្រេចចិត្ត ដើម្បីរស់នៅដោយសេចក្តីសុចរិតវិញ ។

ព្រះគម្ពីរអេសេគាល ១១:១៩

វិញ្ញាណរបស់យើងគឺបានគ្រប់លក្ខណ៍នៅក្នុងព្រះយេស៊ូវ ។ ព្រះទ្រង់សព្វព្រះហប្ញទ័យ កែព្រលឹងយើងសារជាថ្មីឡើងវិញតាមរយៈការបង្កើតគំនិតជាថ្មីឡើងវិញនោះឯង ។ ព្រះទ្រង់ក៏សព្វព្រះហប្ញទ័យកែរូបកាយយើងសារជាថ្មីឡើងវិញ ឱ្យមានសុខភាពពេញលេញ ។ ពេលដែលយើងបានទទួលនូវសេចក្តីសង្គ្រោះភ្លាម នោះយើងបានត្រឡប់មកជាមានកំណើតថ្មីភ្លាមដែរ ។ រូបកាយ (ឆ្អឹង សាច់ និងឈាម) និងព្រលឹង (គំនិត បញ្ញា ឆន្ទៈ និងអារម្មណ៍) មិនទាន់បានទទួលនូវការបំផ្លាស់បំប្រែទាំងស្រុងទេ ប៉ុន្តែ វិញ្ញាណគឺបានទទួលនូវការកើតជាថ្មី ក្នុងពេលដែលបានទទួលនូវសេចក្តីសង្គ្រោះភ្លាមៗនោះឯង ។

លោកសាវ័កប៉ុលបានសរសេរ នូវពាក្យដ៏គួរជាទីចាប់អារម្មណ៍ទៅកាន់បងប្អូននៅក្រុងភីលីពថា "ចូរបង្ហើយសេចក្តីសង្គ្រោះរបស់អ្នករាល់គ្នា" (ភីលីព ២:១២) ។

យើងដឹងថា សេចក្តីសង្គ្រោះគឺបានមកដោយសេរី ហើយខនេះក៏ហាក់ដូចជាមានការប៉ះទង្គិចគ្នា ជាមួយនឹងអ្នកដទៃទៀត រហូតដល់យើងយល់ថា នៅពេលយើងបានទទួលសេចក្តីសង្គ្រោះភ្លាម វិញ្ញាណរបស់យើងគឺបានគ្រប់លក្ខណ៍ដោយសារព្រះគ្រីស្ទ ដែលបានលាក់ទុកនៅក្នុងចិត្តរបស់មនុស្ស ។ ចាប់តាំងពីពេលនោះមក វិញ្ញាណរបស់យើងគឺបានធ្វើការជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធ ដែលអនុលោមទៅតាមគំនិត និងរូបកាយរបស់យើង នៅក្នុងរូបភាពរបស់ព្រះគ្រីស្ទ ។ ពួកគេត្រូវបានបំផ្លាស់បំប្រែជាប្រចាំថ្ងៃ ។ សេចក្តីសង្គ្រោះរបស់យើង គឺបានធ្វើការតាមរយៈគំនិតនិងរូបកាយរបស់យើងដោយការអនុវត្តន៍ជាមួយនឹងព្រះវិញ្ញាណ ។

ព្រះគម្ពីរភីលីព ២:១៣

## ង. ភាពរុងរឿងថ្កុំថ្កើងរបស់ព្រលឹង និងរូបកាយ

វាគឺជាការសំខាន់ដែលយើងមានការបើកសម្ដែង ចំពោះអ្នកណាដែលវិញ្ញាណរបស់យើងជាតួបុគ្គលដ៏ពិត គឺដែលមាននៅក្នុងព្រះគ្រីស្ទយេស៊ូវ ។ យើងត្រូវតែយល់ថា វិញ្ញាណរបស់យើងដែលត្រូវបានបង្កើតឡើងជាថ្មី នោះគឺត្រូវតែបានគ្រប់លក្ខណ៍ និងសុចរិតដោយឥតមានការបន្ទោសបាន នៅក្នុងព្រះនេត្ររបស់ព្រះ ។

ចំពោះការបើកសម្ដែង និងការយល់ដឹងរបស់ការងារនៃការប្រោសលោះរបស់ព្រះយេស៊ូវនេះ គឺដើម្បីជាប្រយោជន៍របស់យើង នោះយើងនឹងចាប់ផ្ដើមដើរដោយមានសុខភាពនៅក្នុងព្រលឹង និងរូបកាយរបស់យើង ។

ព្រលឹងរបស់យើងនឹងបានលូតលាស់ដូចជាគំនិតក៏ត្រូវបានបង្កើតឡើងជាថ្មី ដោយការអាន ការស្ដាប់ ការពិចារណា ការជឿ ការនិយាយប្រាប់ និងការធ្វើសកម្មភាពផ្សេងៗតាមព្រះបន្ទូលរបស់ព្រះ ។

ព្រះគម្ពីររ៉ូម ១២:២

ពេលដែលព្រលឹងរបស់យើង ត្រូវបានទទួលនូវការបំផ្លាស់បំប្រែការសម្របទៅតាមរូបភាពរបស់ទ្រង់នោះយើងនឹង បានចម្រុងចម្រើន ហើយរូបកាយរបស់យើងនឹងមានសុខភាពល្អ។ លោកសាវ័កយ៉ូហានបានសរសេរអំពីការនេះ នៅក្នុងព្រះគម្ពីរ ៣យ៉ូហាន ខ.២ ។

ព្រះទ្រង់កំពុងធ្វើការនៅក្នុងយើង ដែលបានទទួលស្គាល់នូវគោលបំណងរបស់ទ្រង់ នៅក្នុងនិងតាមរយៈយើង ។ ការបើកសម្ដែង និងការកែជាថ្មីឡើងវិញនោះ គឺមាននៅក្នុងបំណងព្រះហឫទ័យរបស់ទ្រង់សម្រាប់យើងរាល់គ្នា ។

## IV. សេចក្ដីសុចរិតរបស់ព្រះ

### ក. តើព្រះទ្រង់មានសេចក្ដីសុចរិតយ៉ាងដូចម្ដេច?

១. ទ្រង់គឺជាសេចក្ដីសុចរិតដ៏ពេញលេញ នៅក្នុងទ្រង់ និងក្នុងផ្លូវទាំងអស់របស់ទ្រង់ ។

២. សេចក្ដីសុចរិតរបស់ទ្រង់ គឺមានច្រើនជាងការអសកម្មនៃអំពើបាប ឬគ្មានលទ្ធភាពនឹងធ្វើបាបទៅទៀត ។

៣. វាគឺជាភាពសប្បុរសដ៏ពេញលេញ និងគ្មានព្រំដែន ដែលមិនអាចមើលអំពើបាបឃើញ ឬក៏មិនអាចភប់ប្រសព្វនឹងអំពើបាបបាន ។

៤. ទ្រង់មិនអាចធ្វើបាបបានឡើយ ។

៥. ព្រះទ្រង់គង់នៅក្នុងសេចក្ដីសុចរិត គឺទ្រង់មិនអាចមើលរំលងអំពើបាបរបស់លោកអ័ដាម និងនាងអេវ៉ា ព្រមទាំងកូនចៅរបស់ពួកគេបានឡើយ គឺសូម្បីតែតាមរយៈសេចក្ដីស្រឡាញ់របស់ទ្រង់ក៏ដោយ ក៏ទ្រង់មិនសព្វព្រះហឫទ័យធ្វើដូច្នោះដែរ ។

ព្រះគម្ពីររ៉ូម ៣:២៥-២៦

សេចក្ដីសុចរិតរបស់ផងព្រះ គឺត្រូវបានទទួលនូវការបើកសម្ដែងដោយសេចក្ដីជំនឿតែប៉ុណ្ណោះ (រ៉ូម ១:១៧) ។

### ខ. សេចក្ដីសុចរិតរបស់យើង

យើងមិនអាចរាប់ជាសុចរិត ដោយការប្រព្រឹត្តដោយខ្លួនឯងបានឡើយ ។ ហោរាអេសាយបានគូសបញ្ជាក់ពីរូបភាពនៃសេចក្ដីសុចរិតទាំងបួនយ៉ាង (អេសាយ ៦៤:៦ក) ។

យើងអាចធ្វើគ្រប់យ៉ាងបាន ចំពោះការងារលបាកៗដែលយើងអាចព្យាយាមនឹងធ្វើ ក៏អាចស្ថិតនៅក្នុងព្រះនេត្ររបស់ព្រះ ទោះជាការអាក្រក់ដ៏តូចមួយក៏ដោយ ។ គ្រប់ការល្អទាំង

អស់ដែលយើងបានធ្វើ មុនពេលដែលយើងបានត្រឡប់មកជាមានកំណើតថ្មី គឺត្រូវបានបន្ថែមទៅលើគំនរអាក្រក់បន្តិចបន្តួច គឺនៅពេលដែលយើងបានប្រៀបធៀប ទៅនឹងសេចក្ដីសុចរិតដ៏ពេញលេញរបស់ផងព្រះនោះ ។

## គ. ភាពសុចរិតដែលត្រូវបានទម្លាក់ទោស

នៅពេលដែលព្រះយេស៊ូវ ទ្រង់បានសុគតនៅលើឈើឆ្កាងនោះទ្រង់បានផ្ទុកនូវអំពើបាបទាំងអស់របស់យើង ដាក់នៅលើរូបអង្គទ្រង់ សេចក្ដីសុចរិតរបស់យើងក៏នៅក្នុងព្រះអង្គទ្រង់ ។ ទ្រង់បានប្រទានឱ្យយើងនូវសេចក្ដីសុចរិតរបស់ទ្រង់ ដោយការបង់ថ្លៃជួស ។ តើគួរឱ្យអស្ចារ្យអ្វីម្ល៉េះហ្ន៎ចំពោះការបង់ថ្លៃជួសនេះ!

- អំពើបាបរបស់យើងត្រូវបានទម្លាក់ទោស ទៅលើអង្គទ្រង់ ។ សេចក្ដីសុចរិតដ៏ពេញលេញរបស់ទ្រង់គឺត្រូវបានទម្លាក់មកលើយើង ។

ក្នុងពេលភ្លាមៗ ដែលយើងបានដាក់សេចក្ដីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទ ធ្វើជាព្រះអង្គសង្គ្រោះរបស់យើង នោះវិញ្ញាណរបស់យើងបានត្រឡប់មកជា "សេចក្ដីសុចរិតរបស់ផងព្រះ" ។

លោកសាវ័កប៉ុលបានសម្ដែងថា យើងត្រូវបានកើតជាថ្មី និងបានត្រឡប់មកជាសេចក្ដីសុចរិតរបស់ផងព្រះ នៅក្នុងព្រះយេស៊ូវ ។

ព្រះគម្ពីរ ២កូរិនថូស ៥:២១

នៅពេលដែលយើងបានត្រឡប់ មកជាសេចក្ដីសុចរិតរបស់ព្រះ គឺមិនមែនគ្រាន់តែមានន័យថា យើងមិនមានបាបតទៅទៀតនោះឡើយ ។ វាក៏មិនមែនមានន័យថា គ្រប់អំពើបាបទាំងអស់របស់យើង សុទ្ធតែបានអត់ទោសបាបនោះទេ គឺគ្រាន់តែមានការអស្ចារ្យយ៉ាងដូច្នោះនោះទៅវិញ ។ នៅពេលដែលយើង បានត្រឡប់មកជាសេចក្ដីសុចរិតរបស់ព្រះនោះគឺមានន័យថា វិញ្ញាណរបស់យើងគឺបានរាប់ជាសុចរិតដូចជាព្រះអង្គទ្រង់សុចរិតដែរ ។

១. យើងប្រកាសថា យើងបានរាប់ជាសុចរិត ។

២. យើងបានទទួលនូវសេចក្ដីសុចរិតរបស់ផងព្រះ ។

## ឃ. រូបភាពនៃសេចក្ដីទុច្ចរិតចាស់

ដែលយើងបានរាប់ជាសុចរិត ដូចជាព្រះទ្រង់សុចរិតដែរនោះគឺជាការលំបាកក្នុងការទទួលចំពោះអ្នកខ្លះនោះណាស់ ។ យើងបានទទួលនូវការបង្រៀនយ៉ាងលំបាក ពីគ្រូបង្រៀនដែលមានន័យត្រឹមត្រូវល្អនោះណាស់ ។ មានគ្រីស្ទានជាច្រើនរស់នៅអស់មួយជីវិតរបស់ពួកគេ គឺត្រូវបានទម្លាក់ចុះទៅនឹងភាពមានទោស និងការផ្ដន្ទាទោស គឺមិនមែនជាការដឹងពីអ្នកណាថា ពួកគេបាននៅក្នុងព្រះយេស៊ូវគ្រីស្ទនោះទេ ។

ដោយសេចក្ដីជំនឿ នោះយើងត្រូវតែទទួលជឿថា យើងត្រូវបានទទួលនូវការទម្លាក់ទោស ទៅជាមួយនឹងសេចក្ដីសុចរិតរបស់ផងព្រះ ។ នៅពេលដែលយើងបានត្រឡប់មកជាមានការដឹងខ្លួនរបស់ព្រះបន្ថែមទៀត នោះយើងក៏បានត្រឡប់មកជាមានការដឹងខ្លួនពីសេចក្ដីសុចរិតជំនួសឱ្យ នូវការដឹងខ្លួនខាងឯអំពើបាប ។

## ង.រូបភាពនៃសេចក្ដីសុចរិតជាថ្មី

យើងមិនត្រូវក្រឡេកមើលទៅខ្លួនយើងថា "ជាអ្នកមានបាប ដែលបានសង្គ្រោះដោយសារព្រះគុណ" នោះនៅបានយូរអង្វែងនោះឡើយ ។ យើងក៏មិនមែនជាអ្នកមានបាបតទៅទៀតដែរ! យើងត្រូវបានកើតជាថ្មីហើយ! មានគ្រីស្ទានជា

ច្រើនបានរកឃើញ នូវអំពើបាបដោយខ្លួនពួកគេ ពីព្រោះពួកគេបាននៅតែបន្តនិយាយថា ពួកគេជាអ្នកមានបាប ។

ពួកគេបានឮនូវសេចក្តីបង្រៀន បន្ទាប់ពីការបង្រៀនពីអំពើបាប ។ គំនិតរបស់ពួកគេបាននៅតែបន្តនៅក្នុងអំពើបាប ។ ពួកគេមិនបានទទួលនូវការបើកសម្តែងពីសេចក្តីសុចរិត ដូច្នេះ អំពើគឺនៅតែគ្រប់គ្រងលើជីវិតរបស់ពួកគេ នៅជាដដែល ។ តាមរយៈការបើកសម្តែងពីសេចក្តីសុចរិតរបស់ព្រះ នោះយើងត្រូវបានត្រឡប់មកជាការដឹងខ្លួន ដោយសេចក្តីសុចរិត ។ យើងមើលឃើញដោយខ្លួនឯង ដូចជាព្រះទ្រង់មើលឃើញយើងដូច្នោះដែរ ។ យើងមើលឃើញដោយខ្លួនឯងនូវសេចក្តីសុចរិត ដូចជាព្រះទ្រង់សុចរិត ។ ដូច្នេះ អំពើបាបគឺមិនត្រូវគ្រប់គ្រងលើរូបកាយរបស់យើងតទៅទៀតឡើយ ។ យើងមិនត្រូវធ្វើឱ្យមានទម្លាប់ថាមានបាបតទៅទៀតឡើយ ។

យើងមើលឃើញអំពើបាប ដូចជាព្រះទ្រង់មើលឃើញអំពើបាបនោះដែរ ។ វាត្រូវតែបានបាត់បង់ទៅនូវការបញ្ឆោតចិត្តរបស់វា ពីព្រោះយើងបានទទួលនូវការបើកសម្តែងពីសេចក្តីសុចរិតរបស់ព្រះ ។

## V. ការអនុលោមទៅតាមរូបភាពរបស់ទ្រង់

នៅពេលដែលយើងបន្ត នូវការដើរជាមួយនឹងការបើកសម្តែងពីសេចក្តីសុចរិតរបស់ព្រះ គឺដែលយើងបានទទួលនូវការកើតជាថ្មីនៅក្នុងព្រះយេស៊ូវគ្រីស្ទ នោះយើងក៏បានត្រូវទទួលនូវការបំផ្លាស់បំប្រែ ដោយនូវការបន្តបំពេញបន្ថែមពីគំនិតរបស់យើងផងដែរ ។ វាត្រូវតែបានសម្រេចការនោះ ។ គឺដែលយើងត្រូវបានអនុលោមជាប្រចាំថ្ងៃ ទៅនឹងរូបភាពនៃព្រះរាជបុត្រារបស់ផងព្រះអង្គ ។ ខ្ញុំគឺជាតែមួយជាមួយនឹងព្រះគ្រីស្ទយេស៊ូវ ។ ខ្ញុំបានកើតជាថ្មីហើយ ។

ព្រះគម្ពីររ៉ូម ៨:២៩

## ក. ការសារភាពនូវអំពើបាប

ប្រសិនបើយើងជាអ្នកជឿ ហើយបានចុះចូលនឹងអំពើបាប នោះយើងមិនត្រូវរស់នៅដោយមានការបរាជ័យ ការជាប់មានទោស និងការផ្តន្ទាទោស នូវសំណល់ជីវិតរបស់យើងនោះទេ ។ ភ្លាមៗនេះ យើងត្រូវតែបញ្ជាក់ឱ្យច្បាស់ថា យើងបានធ្វើបាប ហើយយើងត្រូវតែសារភាពថា យើងបានធ្វើបាបចំពោះព្រះ ដោយនូវសេចក្តីជំនឿ នោះយើងនឹងបានទទួលនូវការអត់ទោសបាបមកពីព្រះហើយ ។ បន្ទាប់មក យើងអាចកាន់ខ្ជាប់នូវការដើរតាមសេចក្តីសុចរិត នោះយើងនឹងបានរួចពីភាពមានទោស និងរួចពីការផ្តន្ទាទោសនោះហើយ ។

ព្រះគម្ពីរ ១យ៉ូហាន ១:៩

ដើម្បីធ្វើការសារភាពនូវអំពើបាប នោះមានន័យថា បានឯកភាពជាមួយនឹងព្រះពីអំពើបាបរបស់យើងនោះហើយ ។ ដើម្បីឱ្យបានរឹតតែជិតស្និទ្ធ ក្នុងការដើរជាមួយនឹងព្រះបន្ថែមទៀត នូវការបើកសម្តែងពីសេចក្តីសុចរិត ហើយយ៉ាងហោចណាស់ក៏យើងនឹងបានទទួលនូវការល្បួងលៃ ចំពោះអំពើបាបនោះដែរ ។ ការតាំងចិត្តចំពោះស្ថានភាព ដែលវាកើតមានពិតប្រាកដមកហើយនោះការតាំងចិត្តក្នុងការពិសោធន៍ក៏ត្រូវ បានសម្រេចដែរ ។

## ខ. ការសិក្សារៀនសូត្រក្នុងការលោតឡើង

នៅពេលដែលយើងធ្លាក់ចុះទៅក្នុងតំបន់ខ្លះៗ នៃការរស់នៅរបស់យើង នោះយើងត្រូវតែសិក្សារៀនសូទ្រឱ្យបានលឿននូវការលោតឡើងនោះ ។ ដូចជាអ្នកប្រដាល់ម្នាក់ដែលបានធ្វើការគោះកន្ទេលមួយ នោះយើងមិនត្រូវផ្តេកខ្លួនទៅទីនោះ

ដោយមានអារម្មណ៍សោកស្តាយ ដោយខ្លួនយើងនោះឡើយ ។ ជំនួសឱ្យនូវការនេះ យើងត្រូវធ្វើការហ្វឹកហ្វឺនដោយខ្លួនឯង ដើម្បីឱ្យបានលោតចេញពីកន្ទេល និងពីលោតចេញដោយជើងរបស់យើង ។ យើងត្រូវតែលោតឡើង និងរក្សានូវចលនានោះឱ្យបាន ។

នៅពេលដែលយើងបានធ្វើបាប យើងមិនត្រូវគិតថាយើងជាអ្នកមានកំហុស មានការផ្តន្ទាទោស និងមានការបរាជ័យនោះឡើយ ។ ជំនួសឱ្យនូវការនេះ យើងត្រូវតែប្រញាប់ប្រញាល់លន់តួបាបរបស់យើង ព្រមទាំងទទួលនូវការធានារ៉ាប់រងដ៏ពេញលេញ ពីការអត់ទោសរបស់ព្រះ ។ ដូចជាអ្នកប្រដាល់ដែលមានជ័យជម្នះ យើងត្រូវតែលោតឡើង និងរក្សានូវចលនាទៅចំពោះជ័យជម្នះនោះ ។

## គ. ការបំផ្លាស់បំប្រែ

វិញ្ញាណរបស់យើងមានសេចក្តីសុចរិតរបស់ព្រះ ប៉ុន្តែយើងត្រូវតែមានវត្តមានរបស់យើងខាងរូបកាយ ដែលរស់នៅធ្វើជាយញ្ញបូជារស់ថ្វាយដល់ព្រះជារៀងរាល់ថ្ងៃ ។

ព្រះគម្ពីររ៉ូម ១២:១

វិញ្ញាណរបស់យើងមានសេចក្តីសុចរិតរបស់ព្រះ ប៉ុន្តែ រីឯព្រលឹងរបស់យើងវិញ គឺត្រូវតែមានការបំផ្លាស់បំប្រែ ដោយការបង្កើតគំនិតសារជាថ្មី តាមរយៈការបើកសម្តែងពីព្រះបន្ទូលរបស់ព្រះ ។

ព្រះគម្ពីររ៉ូម ១២:២

## ឃ. ការពិចារណាជាប្រចាំថ្ងៃ

ការអនុវត្តន៍នូវការយល់ឃើញនូវសេចក្តីសុចរិតរបស់ព្រះដោយខ្លួនឯង ឱ្យបានយល់ដឹងស្គាល់ដល់ព្រះ ។ បើយើងបានមើលឃើញព្រះដូចជាព្រះទ្រង់បានមើលយើងឃើញដែរ នោះយើងនឹងបានត្រឡប់មកជាមានការអនុលោមទៅតាមរូបភាពនៃព្រះរាជបុត្រារបស់ព្រះនោះហើយ ។

## ង. ការមានចិត្តអង់អាច

តាមរយៈការបើកសម្តែងពីសេចក្តីសុចរិតរបស់ព្រះ នៅក្នុងការបង្កើតជាថ្មី នោះយើងនឹងអាចចូលទៅដល់បល្ល័ង្កនៃព្រះដ៏ក្លាហាន ។ យើងអាចដឹងថា ព្រះទ្រង់នឹងស្តាប់យើងឮហើយ (ហេព្រើរ ៤:១៦) ។

យើងមានចិត្តអង់អាច និងមានការអាថិកំបាំងនឹងចូលមកឯព្រះ ពីព្រោះយើងបានស្គាល់យល់ពីព្រះគុណរបស់ទ្រង់ ។ យើងដឹងពីអ្វីដែលព្រះយេស៊ូវទ្រង់បានធ្វើ ជាប្រយោជន៏ដល់យើងរាល់គ្នា ។ យើងដឹងថា យើងបានទទួលនូវការអត់ទោសហើយ ។ យើងដឹងថា យើងបានទទួលនូវកំណើតថ្មីនៅក្នុងព្រះយេស៊ូវគ្រីស្ទ ។ យើងដឹងថា យើងមានសេចក្តីសុចរិតរបស់ព្រះហើយដែរ ។

## ច. ការមានជីវិតរស់

យើងជាអ្នកត្រូវបានបង្កើតជាថ្មី គឺយើងមានជីវិតថ្មីនៅនឹងយើងហើយ ។ ជីវិតថ្មីនេះគឺជាជីវិតរបស់ព្រះគ្រីស្ទអង្គទ្រង់ ។

ព្រះគម្ពីរអេភេសូរ ២:៤,៥ក

អាត្មានិយមចាស់ដែលបានដើរតាមយើង គឺជាមូលហេតុនៃលោកិយនេះ នឹងមិនមានតទៅទៀតឡើយ ។ មនុស្សដែលចូលមកក្នុងចិត្តជាថ្មីរបស់យើង គឺបានបង្កើតឱ្យមានជីវិតរស់ឡើងវិញ ។

ព្រះគម្ពីរអេភេសូរ ២:១-៣

## ឆ.ការបំពេញ

នៅពេលដែលយើងបានកើតជាថ្មី នោះវិញ្ញាណរបស់យើងត្រូវបានបំពេញដោយភាពពោរពេញរបស់ផងព្រះ គ្រប់យ៉ាងដែលទ្រង់មានគឺទ្រង់បានបំពេញឱ្យយើង ។ រង្វាស់ដ៏សែនមានពេញពោរដែលទ្រង់មានទាំងអស់នោះ គឺបានត្រឡប់មកជារបស់យើងវិញ ។

អេភេសូរ ៣:១៩

ព្រះគម្ពីរដ៏បញ្ជាក់ច្បាស់នោះបានចែងមកថាអ្នកអាចបានទទួលនូវការបំពេញ (តាមរយៈគ្រប់ទាំងអស់របស់អ្នក) ចូលទៅក្នុងភាពពោរពេញរបស់ផងព្រះ (នោះហើយ) ដែលអាចធ្វើឱ្យយើងមានខ្នាតរង្វាស់មកពីព្រះវត្តមានរបស់ព្រះ ហើយក៏បានត្រឡប់មកជារូបកាយ ដែលទ្រង់បានបំពេញយ៉ាងពេញគ្រប់គ្រាន់ ហើយដែលបានបង្ហូរមកដោយព្រះអង្គទ្រង់ផ្ទាល់នោះឯង!

ពេលដែលបានកើតជាថ្មីហើយ នោះយើងមិនមែននៅជាទទេទៀតទេ ។ ជំនួសឱ្យនូវការនេះ យើងត្រូវបានបំពេញមកពីព្រះ! យើងបានទទួលនូវការជន់ជោរ ដោយការបំពេញមកពីអង្គទ្រង់ផ្ទាល់នោះឯង!

នៅពេលបានបន្តនូវការស្រេកឃ្លានជាបន្តទៅទៀត នោះបន្ទាប់ពីយើងមានការស្រេកនូវសេចក្តីសុចរិតរបស់ព្រះ យើងនឹងរកឃើញនូវការបំពេញ ដោយខ្លួនឯងជាមួយនឹងសេចក្តីសុចរិតរបស់ព្រះ ទាំងខាងព្រលឹងនិងខាងរូបកាយរបស់យើងទៀតដែរ ។

ព្រះគម្ពីរម៉ាថាយ ៥:៦

ព្រះគម្ពីរអេភេសូរ ២:១-៥

## ជ. ការទទួលនូវសេចក្តីស្រឡាញ់របស់ទ្រង់

អ្វីទៅជាការបើកសម្តែងដ៏ធំឧត្តម ដើម្បីឱ្យបានដឹងថាព្រះទ្រង់មិនបានបង្កើតយើងទេនោះ! ទ្រង់ស្រឡាញ់យើងរាល់គ្នា! សូម្បីតែនៅពេលដែលយើងនៅជាខ្មាំងសត្រូវរបស់ទ្រង់ នោះទ្រង់នៅតែស្រឡាញ់យើងដដែល ។

ព្រះគម្ពីរយ៉ូហាន ១៥:១២-១៤

យើងបានកើតជាថ្មី គឺដោយមានចិត្តជាសាច់ថ្មីយើងក៏បានធ្វើអ្វីភ្លាមៗតាមការដែលទ្រង់បានបញ្ជាឱ្យយើងធ្វើការនោះ ។

## ឈ. យើងបានត្រឡប់ជាមិត្តភក្រ្តជាមួយនឹងទ្រង់

តើវាជាការសំខាន់អស្ចារ្យប៉ុណ្ណាទៅ ដែលយើងដឹងថាព្រះទ្រង់មិនបានបង្កើតយើងមកទេនោះ ។ ឥឡូវនេះ ទ្រង់កំពុងតែមានបន្ទូលមកកាន់យើងថា "អ្នកគឺជាមិត្តភក្រ្តរបស់ខ្ញុំហើយ!" យើងដែលពីដើមជាខ្មាំងសត្រូវរបស់ទ្រង់រួចម្តងទៅហើយ គឺបានត្រូវទទួលនូវការផ្សះផ្សាដល់ទ្រង់វិញ តាមរយៈអង្គព្រះយេស៊ូវគ្រីស្ទ ។ ឥឡូវនេះ យើងគឺជាមិត្តភក្រ្តរបស់ទ្រង់ ហើយទ្រង់ក៏ជាមិត្តភក្រ្តរបស់យើងវិញដែរ ។ ក្នុងនាមយើងជាមិត្តភក្រ្តរបស់ព្រះ នោះយើងត្រូវតែបំពេញការងារពីការផ្សះផ្សានោះ ។ យើងចង់បានឱ្យអ្នកដទៃទៀតបានធ្វើជាមិត្តរបស់យើង ហើយឱ្យបានដូចជាយើង ដើម្បីឱ្យបានត្រឡប់មកជាមិត្តភក្រ្តរបស់ផងព្រះដែរ ។

## ញ. ឱ្យបានទទួលការផ្សះផ្សាដល់ទ្រង់

ក្នុងនាមយើងបានកើតជាថ្មី គឺយើងបានទទួលនូវការផ្សះផ្សាជាមួយនឹងទ្រង់ហើយ ។

ព្រះគម្ពីរ ២កូរិនថូស ៥:១៧-១៨

យើងបានកើតជាថ្មីនៅក្នុងព្រះគ្រីស្ទហើយ នោះយើងមានការបំពេញការងារ ក្នុងការប្រាប់ដល់អ្នកដទៃទៀតអំពីសេចក្ដីស្រឡាញ់របស់ផងព្រះគ្រីស្ទ ។ យើងមានផ្លូវថ្មីក្នុងការរស់នៅទាំងស្រុង ។

## ក្រុមពិភាក្សា

១. បន្ទាប់ពីបានស្ដាប់ឮមេរៀននេះហើយ តើលោកអ្នកបានទទួលនូវការបើកសម្ដែងណាខ្លះអំពីព្រះគម្ពីរ ២កូរិនថូស ៥:១៧ដែលបានចែងមកថា "គ្រប់ទាំងសេចក្ដីចាស់បានកន្លងបាត់ទៅ មើល គ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញ" នោះ?

២. តើព្រះទ្រង់បានប្រទានឱ្យយើងមានចិត្តជាសាច់ នៅក្នុងចិត្តរបស់យើង ដែលធ្លាប់មានចិត្តជាថ្មដោយរបៀបណា?

៣. តើលោកអ្នកធ្លាប់បានទទួលអ្វីពីខាងក្នុង បន្ទាប់ពីបានទទួលនូវគំរូពីការធ្វើបាប និងពីការប្រដាល់? តើលោកអ្នកអាចផ្សះផ្សាបានដោយរបៀបណា បន្ទាប់ពីបានធ្វើបាបមកនោះ?

## ការសិក្សាដោយខ្លួនឯង

១. តើលោកអ្នកធ្លាប់បានសិក្សារៀនសូត្រ ពីការជាប់មានទោស និងពីការផ្ដន្ទាទោសពីគ្រូបង្រៀនគ្រីស្ទាន ដែលមានន័យត្រឹមត្រូវល្អឬទេ?

ក. ប្រសិនបើមាន តើលោកអ្នកបានរួចខ្លួនហើយនៅក្នុងពេលឥឡូវនេះ?

ខ. ប្រសិនបើលោកអ្នករកឃើញថា ជាការលំបាកក្នុងការរើយកការជាប់មានទោសចេញ ឬការផ្ដន្ទាទោសពីចិត្តគំនិតរបស់លោកអ្នក ចូរធ្វើការអធិស្ឋានទូលសូមដល់ព្រះ ឱ្យទ្រង់បានជួយដល់លោកអ្នក ឱ្យអាចធ្វើការផ្សះផ្សា ដែលមកពីព្រះបន្ថែមទៀត ។

២. តើលោកអ្នកទទួលនូវការបំផ្លាស់បំប្រែ និងការបង្កើតគំនិតជាថ្មីដោយរបៀបណា? តើព្រះគម្ពីរចែងមកឱ្យយើងធ្វើយ៉ាងដូចម្ដេចដែរ?

៣. តើជំហររបស់លោកអ្នកយ៉ាងដូចម្ដេចដែរ មុនពេលដែលបានសិក្សាមេរៀននេះ យ៉ាងហោចណាស់ក៏ចំពោះការផ្សះផ្សាដោយសុចរិតនោះ?

ក. តើលោកអ្នកបានឃើញដោយខ្លួនឯង នូវសង្គ្រោះដល់អ្នកមានបាប ដោយព្រះគុណនោះ?

ខ. តើលោកអ្នកបានទទួលនូវការផ្សះផ្សាអំពើបាប នៅទីណា?

គ. តើលោកអ្នកបានទទួលនូវការផ្សះផ្សាហើយឬនៅ?

ឃ. តើលោកអ្នកបានបញ្ជាក់ពិតប្រាកដនូវលទ្ធផល នៃមេរៀននេះ ដែលលោកអ្នកត្រូវការការបំផ្លាស់បំប្រែនូវគោលជំហររបស់លោកអ្នកនោះ? ប្រសិនបើមែន តើលោកអ្នកមានផែនការយ៉ាងណា ដើម្បីអនុវត្តធ្វើយ៉ាងដូច្នោះនោះ?

# រូបភាពនៃការកើតជាថ្មី

## *មេរៀនទី ៤: ការផ្លាស់ប្រែរូបភាពចាស់របស់យើង*

### I. ការជ្រើសរើសរបស់យើង

នៅពេលដែលយើងបានសិក្សាវគ្គនៃមេរៀននេះ យើងមានបំណងនឹងចូលមកកាន់កន្លែង ដែលយើងត្រូវតែធ្វើការជ្រើសរើស ។ តើយើងនឹងជឿនូវការបើកសម្តែងពីព្រះបន្ទូលរបស់ព្រះ ឬតើយើងនឹងប្រកាន់ខ្ជាប់នូវសេចក្តីបង្រៀនចាស់ៗតាមទម្លាប់បុរាណ ដែលយើងធ្លាប់បានទទួលជាច្រើនឆ្នាំមកហើយនោះឬទេ? តើយើងត្រូវតែមានការឯកភាពជាមួយនឹងលោកសាវ័កប៉ុល ពេលដែលគាត់បានសរសេរគម្ពីរ ២កូរិនថូស ៥:១៧ នោះឬទេ?

យើងបានសិក្សាអំពីអ្នកដែលយើងបានបង្កើតមក គឺអំពីសេចក្តីស្រឡាញ់របស់យើង អំពីព្រះវរបិតានៃយើងដែលគង់នៅស្ថានសួគ៌ ព្រមទាំងអំពីអ្នកជួយជំនួសដ៏អស្ចារ្យ គឺជាអ្នកធ្វើការងារប្រោសលោះរបស់ព្រះយេស៊ូវគ្រីស្ទ ឱ្យបានសម្រាប់ជាប្រយោជន៍ដល់យើងរាល់គ្នា ។ ឥឡូវនេះ គឺជាពេលវេលាក្នុងការសម្រេចចិត្តធ្វើការងារផ្សះផ្សា ដើម្បីរើចូលទៅក្នុងគ្រប់ទាំងអស់ ដែលព្រះទ្រង់បានធ្វើសម្រាប់យើង ។ ព្រះទ្រង់បានប្រទានឱ្យយើង នូវប្រព័ន្ធរូបភាពដែលមានពេញដោយអំណាចចេស្តា ។ ចិត្តគំនិតនិងការស្រមើស្រមៃរបស់យើង ក៏មានអំណាចចេស្តាលើយើង ព្រមទាំងសម្រាប់ការល្អ និងការអាក្រក់ ក៏សម្រាប់ធ្វើឱ្យមានការភ័យស្លន់ស្លោផងដែរ ។

### ក. ការដោះចេញនូវរូបភាពចាស់របស់យើង

វាគឺជាការសំខាន់ ក្នុងការមានរូបភាពខ្លួនយើងបានល្អ នោះយើងមិនត្រូវអនុញ្ញាតឱ្យវិញ្ញាណអាក្រក់ បានទទួលនូវជ័យជម្នះលើយើងនោះទេ គឺយើងគ្មានតម្លៃនឹងទទួលព្រះពររបស់ព្រះនោះទេ បើមានលក្ខណៈបែបនេះនោះ ។ ប្រសិនបើយើងធ្វើការ យើងត្រូវតែឆ្លងកាត់ជីវិតដែលបរាជ័យ ។ ប្រសិនបើយើងរស់នៅដោយមានជីវិតបរាជ័យ នោះយើងនឹងមិនមានលទ្ធភាពនឹងទទួលជ័យជម្នះនៅក្នុងសមរភូមិ ដែលត្រូវវាយខ្ទាំងសត្រូវនោះទេ ។ យើងនឹងគ្មានលទ្ធភាពក្នុងការរស់នៅ ជាជីវិតគ្រីស្ទានដែលមានជ័យជម្នះ និងការខិតខំប្រឹងប្រែងបំពេញការងារទៅចំពោះអ្នកដទៃទៀតនោះទេ ។

មានពួកយើងជាច្រើន ដែលមានសេចក្តីត្រូវការចំណាយពេលវេលាចាប់យកការងាររបស់មនុស្សចាស់ ដោយមិនសូញសាញនោះគឺ:

ទម្លាប់ដែលចេញជាគំនិត ឬជាសកម្មភាពពីអតីតកាល និងមិនបានដាក់ចូលទៅក្នុងរូបភាពនៃការកើតជាថ្មី ដោយការបង្កើតគំនិតរបស់យើងសារជាថ្មីនោះ ។ លោកសាវ័កប៉ុលបានសរសេរអំពីការដោះមនុស្សចាស់ចេញ ។ វាគឺជាសកម្មភាពនៃឆន្ទៈរបស់យើង ។

ព្រះគម្ពីរអេភេសូរ ៤:២២-២៣

### ខ. ការដាក់មនុស្សថ្មីមកវិញ

នៅពេលដែលយើងបានដោះមនុស្សចាស់ចេញ នោះយើងត្រូវតែបានទទួលនូវការបង្កើតគំនិតរបស់យើងជាថ្មី ។ ការដោះជាថ្មីនេះ គឺបានមកតែត្រឹមគំនិតរបស់យើងដែលត្រូវបានបង្កើតសារជាថ្មី នូវសេចក្តីជំនឿដោយការបើកសម្តែងពីព្រះបន្ទូលរបស់ព្រះ ។

លោកសាវ័កប៉ុលបានបន្តនិយាយ នៅក្នុងខជាបន្តបន្ទាប់ ។

ព្រះគម្ពីរអេភេសូរ ៤:២៤

នៅពេលដែលយើងបានដោះមនុស្សចាស់ចេញ គឺជាបុគ្គលចាស់ ជារូបភាពអាត្មានិយមចាស់ ហើយបង្កើតគំនិតរបស់យើងសារជាថ្មី ទៅតាមការបើកសម្តែងមកពីព្រះបន្ទូលរបស់ព្រះ នោះយើងត្រូវតែដាក់នូវមនុស្សថ្មី គឺជាការកើតជាថ្មីនោះឯង ។ ការកើតជាថ្មីគឺមិនមែនជាការកំណត់ឱ្យបានយូរ ចំពោះការដែលគាត់ ឬនាងឱ្យបានដឹងដោយវិញ្ញាណទាំង៥នោះទេ ។ ជីវិតនៃការកើតឡើងជាថ្មី គឺនៅក្នុងតំបន់នៃសេចក្តីជំនឿ ។ ការកើតជាថ្មីគឺបានដឹងថា គាត់ឬនាងបានកើតជាថ្មីហើយ ការកើតជាថ្មីគឺទៅតាមព្រះ ដោយនូវភាពសុចរិត និងភាពបរិសុទ្ធនោះឯង ។

ការកើតជាថ្មី គឺមិនមែនដូចជាការដែលយើងបានមើលឃើញ ដោយខ្លួនឯងថាយើងជាអ្នកមានបាបជារហូតនោះទេ។ ពួកគេបានដឹងថាវិញ្ញាណរបស់ពួកគេ គឺបានរាប់ជាសុចរិតនិងបរិសុទ្ធដូចជាព្រះដែរ ។ ពួកគេដឹងថា ព្រលឹងនិងរូបកាយរបស់ពួកគេ គឺត្រូវបានរាប់ទៅជាការស្របទៅនឹងរូបភាពនៃព្រះរាជបុត្រា ទៅនឹងសេចក្តីសុចរិតនិងភាពបរិសុទ្ធ ដែលមានការពិសោធន៍និងមានការអនុវត្តន៍ នៅក្នុងដំណើរប្រចាំថ្ងៃជារបស់ពួកគេនោះឯង ។

## II. ជ័យជម្នះលើទីមាំមួន

នៅពេលដែលយើងមានការលូតលាស់ឡើង នោះសាតាំងក៏បានសម្រេចនូវទីមាំមួនខុស១គ្នា មកលើគំនិតរបស់យើងផងដែរ ។ ឥឡូវនេះ សូម្បីតែមនុស្សចាស់១ដែលយើងគិតថាមិនអាចធ្វើការជាពិសេសនោះបាន ពីព្រោះយើងបានប្រាប់ថាមិនអាចធ្វើបានដូចជាកូនក្មេងនោះ ។ ពាក្យសម្តីដែលប្រកបដោយគ្រោះថ្នាក់ ដែលបាននិយាយ នៅក្នុងកំឡុងពេលដែលបានត្រឡប់មកជាទីមាំមួន ដែលត្រូវការនូវការបំបាក់បំបែកនោះ ។

ព្រះគម្ពីរ ២កូរិនថូស ១០:៤-៥

ព្រះបន្ទូលរបស់ព្រះគឺជាសេចក្តីពិត និងជាចំណេះដឹងដ៏ពិតនោះនឹងដោះលោកអ្នកឱ្យមានសេរី ។ សេចក្តីជំនឿអាចរើយើងចេញពីរូបភាពចាស់ ឱ្យចូលមកឯតំបន់នៃការកើតជាថ្មី។ ការស្រមើស្រមៃថា នឹងកើតឡើងពីរបៀបដែលយើងមើលឃើញនូវរឿងរ៉ាវទាំងឡាយទៀត ។

### ក. ភាពមិនពេញលេញ

ប្រហែលជាលោកអ្នកបាននិយាយថា "ឱ កុំព្យាយាមធ្វើយ៉ាងដូច្នោះអី បងប្រុសរបស់អ្នកអាចថែរក្សាវាបាន" ។ លោកអ្នកអាចចាប់ផ្តើមគិតថា "ខ្ញុំមិនអង់អាចដូចជាប្អូនប្រុសខ្ញុំទេ" ជាដើម ។

### ខ. ភាពថោកទាប

គ្រូបង្រៀនអាចនិយាយបានថា "ខ្ញុំមិនយល់ពីមូលហេតុអ្វីដែលនាំឱ្យមានបញ្ហាយ៉ាងនេះចំពោះលោកអ្នកនោះទេ សិស្សដទៃទៀតនៅក្នុងថ្នាក់ គឺគ្មានបញ្ហាអ្វីឡើយ" ។ លោកអ្នកនឹងមានគំនិតភ្លាម១យ៉ាងដូច្នេះ "ខ្ញុំមិនទៅឈឺចាប់ចំពោះសិស្សខ្លះទៀតដែលនៅក្នុងថ្នាក់នោះទេ ។ ខ្ញុំមិនជាគិតថ្លឹងថ្លែងចំពោះបញ្ហានោះឡើយ" ។

### គ.ការចាត់ទុកជាតួយ៉ាង

ប្រហែលជាយើងជឿទៅលើអ្វី ដែលអ្នកដទៃទៀតបាននិយាយអំពីចំណងជើងនៃការនិពន្ធ ឬអំពីក្រុមមនុស្សសំខាន់១ដែលយើងធ្វើការបញ្ជាក់នោះ ។ នៅជំនាន់ទាំងនេះហើយ

ដែលអាចបានត្រឡប់មកជាការចាត់ទុកជាតួយ៉ាង ដែលមានការកំណត់ទុកនៅក្នុងជីវិតរបស់យើងនោះ ។

ប្រសិនបើលោកអ្នកមានសក់ពណ៌ក្រហម ប្រហែលជាលោកអ្នកបានស្តាប់ឮថា "មនុស្សដែលមានក្បាលក្រហម គឺច្បាស់ជាបានលត់សក់ឱ្យក្តៅហើយ" ជាដើម ។

ការចាត់ទុកជាតួយ៉ាងដទៃទៀត គឺអាចនឹងបាននិយាយថា "ម្តាយរបស់ខ្ញុំគឺតែងតែមានការព្រួយបារម្ភ ដូច្នេះ ខ្ញុំត្រូវតែមានមធ្យោបាយមួយហើយ" ។

## ឃ. ការប្រកាន់ពូជសាសន៍

យើងអាចបានឮនិងបានជឿថា មានមនុស្សជាច្រើនបានគិតអំពីការប្រណាំង ឬការដាក់ចំណងជើងនៃការនិពន្ធរបស់យើង ដែលបានបង្កើតយើងឡើងឱ្យមានសេចក្តីជំនឿជឿថា យើងមិនបារម្ភខ្វល់ឬក៏មានការប្រៀបធៀបដោយអនុគ្រោះទៅដល់អ្នកដទៃទៀត ដែលនៅជុំវិញយើង ។ "អ្នកប្រទេសអៀរឡង់តែងតែ... ឬ អ្នកប្រទេសអាឡឺម៉ង់តែងតែ ..." ជាដើម ។

## ង.សេចក្តីពិតពីសាច់រឿងទាំងឡាយនេះ

ការបើកសម្តែងពីការកើតឡើងជាថ្មី គឺនឹងធ្វើការកែច្នៃលោកអ្នកឱ្យបានរួចខ្លួនពីការប្រកាន់ ខាងផ្នែកពូជសាសន៍ និងការទទួលអារម្មណ៍ថាខ្លួនមានភាពថោកទាបជាដើមនោះ ។ យើងនឹងចាប់ផ្តើមឃើញពួកអ្នកជឿគ្រប់រូបជាបន្តបន្ទាប់ បានធ្វើការប្រណាំងជាអ្នកបានបង្កើតឡើងជាថ្មី នៅក្នុងព្រះគ្រីស្ទ។ នៅក្នុងខ.គម្ពីរមុនៗ ដែលលោកប៉ុលបានទទួលនូវការបើកសម្តែងពីការកើតជាថ្មី គឺគាត់បានសរសេរថែងទុកមកនៅក្នុងព្រះគម្ពីរ ២កូរិនថូស ៥:៦ក រួចមកហើយ ។

លោកសាវ័កប៉ុលក៏បានសរសេរ ទៅកាន់ពួកកាឡាទីផងដែរនៅក្នុងព្រះគម្ពីតកាឡាទី ៣:២៦-២៨ ។

នៅពេលដែលយើងបានទទួលព្រះយេស៊ូវ ធ្វើជាព្រះអង្គសង្គ្រោះផ្ទាល់ខ្លួន នោះយើងបានទទួលនូវការកើតជាថ្មី ចូលទៅក្នុងក្រុមគ្រួសារថ្មី គឺជាក្រុមគ្រួសាររបស់ព្រះអង្គទ្រង់ផ្ទាល់នោះឯង ។ យើងមិនត្រូវបើកឱកាសឱ្យទីមាំមួននៃការប្រកាន់ពូជសាសន៍ ចូលមករំព្វកបាននៅក្នុងជីវិតរបស់យើងឡើយ ។ យើងត្រូវតែមើលឃើញអ្នកជឿគ្រប់រូប ជាអ្នកដែលបានទទួលនូវការកើតជាថ្មី ហើយអ្នកមិនជឿគ្រប់រូបគឺនឹងមានលទ្ធភាពបានកើតជាថ្មីផងដែរ ។ យើងត្រូវតែមើលឃើញដោយខ្លួនយើងផ្ទាល់ ព្រមទាំងអ្នកជឿដទៃទៀតទាំងអស់ ដូចជាព្រះទ្រង់បានមើលឃើញយើងដូច្នោះដែរ ។ នៅពេលដែលវិញ្ញាណបានទទួលនូវការង្កើតឡើងជាថ្មីហើយ នោះយើងនឹងមិនបាត់នូវទម្រង់នៃការប្រណាំង ឬក្រុមនៃការនិពន្ធរបស់យើងនោះបានឡើយ ។ យើងត្រូវបានកើតជាថ្មីនៅក្នុងក្រុមគ្រួសាររបស់ព្រះហើយ ។ យើងនឹងមិនបានត្រូវទទួលនូវការគូរផាត់ពណ៌ខាងសាច់ឈាមតាមគាត់ ឬនាងដទៃទៀតណានោះបានតទៅទៀតឡើយ ។ យើងនឹងត្រូវតែបានទទួលដោយខ្លួនឯងព្រមទាំងអ្នកដទៃទៀត ឱ្យមានការកើតជាថ្មីនៅក្នុងព្រះយេស៊ូវគ្រីស្ទហើយ ។

## III. ការទាញចកហូតចេញនូវទីមាំមួន

សាតាំងចង់ប្រើប្រាស់នូវអារម្មណ៍ចាស់ៗ ដែលយើងគិតថាខ្លួននៅមានភាពថោកទាប ភាពគ្មានតម្លៃ និងនៅមានការប្រកាន់ពូជសាសន៍ជាដើម ដែលធ្វើឱ្យយើងនៅជាប់ចំណងនេះ

នោះឯង ។ ឥឡូវនេះគឺជាពេលវេលាត្រូវកំចាត់កំចាយនូវទីមាំមួនទាំងឡាយនេះ ។

## ក. ត្រូវកំចាត់កំចាយពួកវា

ប្រសិនបើព្រះទ្រង់បានបើកសំដែង នូវទីមាំមួនមកលើគំនិតរបស់លោកអ្នកកំឡុងពេលសិក្សានេះ លោកអ្នកអាចបំបែកបំបាក់ពួកវាឥឡូវនេះបាន។ យើងត្រូវតែនិយាយខ្លាំងៗថា :

***នែ៎ សាតាំង អញចងឯងដោយនូវព្រះនាមព្រះយេស៊ូវ ។ អញបដិសេធឯងនូវទីមាំមួននៃ (បញ្ចូលឈ្មោះទីមាំមួន) នេះនៅពេលឥឡូវនេះក្នុងព្រះនាមព្រះយេស៊ូវ ។ អញលែងបើកឱកាសឱ្យឯងចូលមករំខានអញទៀតឡើយ ។ អញបណ្តេញ នូវគ្រប់អស់ទាំងគំនិតនិងការស្រមើស្រមៃដែលជាហេតុនាំឱ្យមានការផ្ទុយជំទាស់ទៅនឹងការបើកសំដែងដែលមកពីព្រះបន្ទូលរបស់ព្រះ ចំពោះអស់អ្នកណាដែលអញនៅជាមួយ ឬចំពោះអ្វីដែលអញអាចធ្វើបាន ឬចំពោះអ្វីដែលអញបានទទួល នូវការកើតជាថ្មីនៅក្នុងព្រះយេស៊ូវគ្រីស្ទហើយនោះ!***

វាអាចចាប់យកពេលវេលាដើម្បីបំបាក់បំបែក នូវទម្លាប់គំនិត ឬទម្លាប់ការនិយាយ ទៅតាមគំនិតអវិជ្ជមានចាស់ៗ ។ ទោះជាយ៉ាងណាក៏ដោយ ពេលវេលានៃការគិតនីមួយៗនេះបានចូលមកក្នុងគំនិតរបស់យើងហើយ នោះយើងត្រូវតែប្រញាប់ប្រញាល់បដិសេធពួកភ្លាមៗ បណ្តេញពួកវាភ្លាមៗ ហើយធ្វើការបន្តប្រកាសពីអ្វី ដែលព្រះបន្ទូលព្រះទ្រង់បានបើកសំដែងអំពីការបង្កើតឡើងជាថ្មីនោះ ។ ដោយការធ្វើបានយ៉ាងដូច្នោះ នោះទម្លាប់នឹងត្រូវតែបានទទួលនូវការបំបាក់បំបែកភ្លាមៗ ហើយលោកអ្នកនឹងបានរួចខ្លួន ។ ចូរចាប់គិតហើយនិយាយយ៉ាងដូច្នេះថា :

***ព្រះបន្ទូលរបស់ព្រះបានថែងមកថា ខ្ញុំត្រូវបានបង្កើតជាថ្មីហើយ ។ ខ្ញុំគឺជាសមាជិកនៅក្នុងក្រុមគ្រួសាររបស់ព្រះ និងគ្មាន ...........នៅក្នុងក្រុមគ្រួសាររបស់ព្រះឡើយ ។ សេចក្តីចាស់បានកន្លងបាត់ទៅហើយ មើលខ្ញុំបានត្រូវបង្កើត ជាមនុស្សថ្មីនៅក្នុងព្រះគ្រីស្ទហើយ ។***

## ខ. ត្រូវកំចាត់កំចាយនូវបណ្តាសា

សាតាំងអាចត្រូវបានទទួលនូវជ័យជម្នះ នៅក្នុងការដាក់បណ្តាសានេះ ទៅលើក្រុមគ្រួសារមួយតាមរយៈការធ្វើបាបពីជំនាន់មុនមក ។ ឧទាហរណ៍ នៅពេលដែលមនុស្សម្នាក់បានចុះចូលនឹងការធ្វើអត្តឃាត នោះវិញ្ញាណអត្តឃាតក៏និយាយជាមួយនឹងក្រុមគ្រួសារនោះ រហូតដល់វាអាចទទួលនូវការបំបាក់បំបែក តាមរយៈអំណាចចេស្តានៃព្រះនាមព្រះយេស៊ូវ ។

នៅពេលដែលមនុស្សម្នាក់ បានចុះចូលនឹងអំពើឃាតកម្ម នោះនឹងមានវិញ្ញាណឃាតកម្ម ដែលបណ្តាលឱ្យមានឧបទ្រព្យចង្រៃនៅក្នុងគ្រួសារនោះ ពីមួយជំនាន់ទៅមួយជំនាន់ទៀត ។

មានបណ្តាសាតត្រកូល ឬក៏មានវិញ្ញាណជីដូនភូតដែលតែងតែបើកទ្វារឱ្យជម្ងឺរោគាបានចូលមកដោយឯកឯង នៅក្នុងរូបរាង្គកាយរបស់យើង "ឱមែនហើយចិត្តដែលមានបញ្ហាបានរត់មករកក្រុមគ្រួសាររបស់យើងហើយ" ឬក៏ "ស្ត្រីទាំងអស់គ្នានៅក្នុងក្រុមគ្រួសាររបស់យើង គឺតែងតែមានជម្ងឺខាន់ស្លាក់ជានិច្ច" ។

បណ្តាសាតត្រកូលគឺជាការងាយស្រួល នឹងធ្វើការបំបែកបំបាក់ដូចជាទីមាំមួនដែលមាននៅក្នុងគំនិតរបស់យើង នោះយើងត្រូវនិយាយថា :

***ណែ៎ សាតាំង អញចងឯងក្នុងព្រះនាមព្រះយេស៊ូវ!***
***អញបំបាក់បំបែកនូវបណ្តាសានៃ .....................***
***និង............. !***
***អញបញ្ជានូវបណ្តាសាតត្រកូល***
***និងគ្រប់ទាំងវិញ្ញាណអាក្រក់ផ្នែកខាងជីដូនភូត***
***ឱ្យទទួលនូវការបាក់បែកចេញពីជីវិតរបស់អញ***
***នៅពេលឥឡូវនេះភ្លាម ។***
***អញបានទទួលនូវការបង្កើតជាថ្មីហើយ!***
***អញបានទទួលនូវចំណែកជាគ្រួសារនៃព្រះ និងគ្មានចំណង***
***គ្មានបណ្តាសា ហើយគ្មានជម្ងឺរោគាព្យាធិ***
***នៅក្នុងគ្រួសារនៃព្រះតទៅទៀតឡើយ!***

នៅពេលដែលគំនិត ឬអាការៈនៃចំណង បណ្តាសា ឬជម្ងឺនោះព្យាយាមចូលមកឯលោកអ្នកវិញទៀត ចូរស្តីបន្ទោសដល់ពួកវា!ប្រសិនបើលោកអ្នកបានត្រៀមខ្លួន នឹងទទួលនូវអាការៈនោះហើយ ចូរធ្វើការស្តីបន្ទោសដល់ពួកវាយ៉ាងឆាប់បំផុត ហើយចាប់ផ្តើមប្រកាសយ៉ាងរឹងប៉ឹងពីអ្វីដែលព្រះបន្ទូលទ្រង់បានចែងមកអំពីសេរីភាពរបស់របស់លោកអ្នកនោះភ្លាម ។

## IV.ការផ្លាស់ប្តូរនូវរូបភាពអាត្មានិយមចាស់

ការគាំទ្រជាបន្តនូវការខ្វះខាតរូបភាពដោយខ្លួនឯង នោះគឺជាអំពើបាបហើយ ។ យើងមិនចង់បានយ៉ាងដូច្នោះទេ ដូចជាលោកសាវ័កប៉ុលបានពណ៌នារួចមកហើយ នៅក្នុងព្រះគម្ពីររ៉ូម ១:២១-២២

យើងគឺជាអ្វីដែលព្រះទ្រង់មានបន្ទូលថា យើងគឺជានោះឯង ។ ចាប់តាំងពីព្រះយេស៊ូវទ្រង់បានសុគតជំនួសយើងរាល់គ្នា ឱ្យបានរួចខ្លួនពីអំពើទាំងនេះមក គឺជាអំពើដែលយើងបានគាំទ្រក្នុងការប្រមាថមើលងាយដល់ព្រះនោះឯង ។ យើងបានឈ្នះ ឬត្រូវបរាជ័យនៅជីវិតរបស់យើង គឺដោយសារគំនិតនោះឯង ។

### ក. ការជំពាក់វាក់វិនទៅនឹងភាពថោកទាប

មានអ្នកជឿជាច្រើនដែលគ្មានសន្តិសុខ នៅក្នុងលទ្ធភាពរបស់ពួកគេ ។ ពួកគេកំពុងតែមានការរងទុក្ខពីសេចក្តីភ័យខ្លាចនូវការធ្លាក់ចុះទៅជាស្លន់ស្លោជាដើម ។ ព្រះបន្ទូលរបស់ព្រះចែងទុកមកនៅក្នុងព្រះគម្ពីរ ភីលីព ៤:១៣ និងព្រះគម្ពីរ ២ធីម៉ូថេ ១:៧ ។

យើងត្រូវតែហ៊ានប្រកាសជាបន្តថា :

***ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន***
***ដោយសារព្រះគ្រីស្ទដែលទ្រង់ចំរើនកំឡាំងដល់ខ្ញុំ ។***
***ខ្ញុំដឹងថាព្រះទ្រង់បានប្រទានឱ្យខ្ញុំ មានវិញ្ញាណដ៏មានអំណាច***
***សេចក្តីស្រឡាញ់ និងប្រាជ្ញានឹងដឹងវិញ ។***

### ខ. ផ្នែកអាការៈខាងក្រៅ

មនុស្សជាច្រើនមានអារម្មណ៍ថា គ្មានសន្តិសុខនៅក្នុងអាការៈរបស់គេ ក្នុងគំនិតរបស់គេ ឬសូម្បីតែក្នុងការនិយាយស្តីថា "ខ្ញុំធាត់ពេក" "ខ្ញុំស្គមពេក" "ខ្ញុំចង់ឱ្យសក់ខ្ញុំមានពណ៌ផ្សេងពីនេះ" "ខ្ញុំចង់ឱ្យវាកុំឱ្យត្រង់ពេក" ពួកគេគឺបានទទួលនូវការស្មុកស្មាញ ឬការដឹងខ្លួនដោយខ្លួនឯងអំពីអាការៈរបស់គេនោះ ។

តាមការស្ទង់មើលបានបើកសម្តែងថា ស្ទើរតែគ្រប់គ្នាទាំងអស់ដែលជាតារាគំរូ និងតារាភាពយន្តដ៏ស្រស់ប្រិមប្រិយ គឺមានអារម្មណ៍ថា ជួនកាលពួកគេហាក់ដូចជាមានការផ្លាស់ប្តូរពីអាការៈរបស់គេ ។

នៅក្នុងសង្គមរបស់យើង មានការបញ្ជាក់ដ៏ធំសម្បើមមួយទៅលើតែអាការៈខាងក្រៅប៉ុណ្ណោះ ។ ប៉ុន្តែព្រះបន្ទូលព្រះវិញទ្រង់បានបើកសម្តែងថា យើងរាល់គ្នាត្រូវបានបង្កើតមកឱ្យមានរូបភាពដូចជាព្រះ ។ យើងត្រូវបានទទួលនូវការបង្កើតមកឱ្យបានដូចជាព្រះ ។ ភាពស្រស់ស្អាតរបស់យើងគឺត្រូវបានបង្កើតឡើងជាបុគ្គលខាងឯវិញ្ញាណ នៅខាងក្នុងចិត្តវិញ្ញាណរបស់យើងរាល់គ្នាផ្នែកខាងក្នុង គឺជាតួបុគ្គលពិតៗ។ យើងត្រូវបានទទួលនូវការងើបឡើង នូវភាពជាប្រមុខរបស់យើង ហើយបើកឱ្យភាពស្រស់ស្អាតរបស់យើង និងភាពភ្លឺចាំងរបស់ព្រះយេស៊ូវបានចាំងជះចេញពីមុខរបស់យើងមក ។

ហោរាសាំយូអែលបានចូលមកឯក្រុងបេថ្លេហិម ដើម្បីធ្វើការចាក់ប្រេងតាំង ឱ្យពួកកូនប្រុសទាំងឡាយរបស់លោកអ៊ីសាយ ឱ្យបានសោយរាជ្យធ្វើជាស្តេចបន្ទាប់ គាត់មិនអាចមើលទៅតាមភាពស្រស់សង្ហានៃកូនប្រុសច្បងបង្អស់ នោះបានទេ ។ ជាធម្មតាគឺត្រូវធ្វើការវិភាគទៅលើកូនច្បងបង្អស់ និងបន្ទាប់មកទៀត នៅក្នុងគំនិតរបស់គាត់គឺត្រូវធ្វើទៅតាមការជ្រើសរើសរបស់ផងព្រះឱ្យឡើងធ្វើជាស្តេចប៉ុណ្ណោះ ។ ប៉ុន្តែព្រះអម្ចាស់ទ្រង់បានបញ្ឈប់គាត់វិញ ។

ព្រះគម្ពីរ ១សាំយូអែល ១៦:៧

## គ. ការខ្វះចំណេះដឹង

អ្នកជាច្រើនទៀតមានអារម្មណ៍ថាគ្មានសន្តិសុខ អំពីការខ្វះខាតនូវចំណេះដឹងរបស់ពួកគេឡើយ ទោះជាយ៉ាងណាក៏ដោយ ព្រះបន្ទូលនៃព្រះក៏បានបើកសម្តែងថា នៅក្នុងព្រះគ្រីស្ទយើងមានគ្រប់ទាំងកំណប់ប្រាជ្ញា និងចំណេះដឹង ។ ចំណេះដឹងដ៏ពិតគឺជាការស្គាល់ព្រះ ។

ព្រះគម្ពីរកូល៉ុស ២:២-៣

## ឃ.ការទទួលអារម្មណ៍ថាមានការបដិសេធន៏

ហេតុអ្វីបានជាថា យើងបានឃើញអ្នកជឿជាច្រើននៅសម័យសព្វថ្ងៃនេះ ដែលមានការរងទុក្ខដោយបានជួបនឹងការបដិសេធន៏ ព្រមទាំងមានអារម្មណ៍ថាមានការបដិសេធន៏ដែលប៉ះពាល់លើអារម្មណ៍ដ៏មានជម្រៅជ្រៅ ដែលមានស្នាមចូលទៅក្នុងព្រលឹងរបស់ពួកគេ ។ ការនេះគឺព្រះទ្រង់មានបន្ទូលនៅក្នុងព្រះគម្ពីរអេភេសូរ ១:៥-៧ ។

ប្រសិនបើ "យើងបានទទួលព្រះដ៏ជាទីស្រឡាញ់ហើយ" នោះយើងមិនត្រូវបើកឱ្យមានអារម្មណ៍នៃការបដិសេធន៏ ចូលមកទាស់ទទឹងនឹងយើងនោះឡើយ ។ យើងត្រូវតែមានសេចក្តីស្ងប់ ដោយនូវចំណេះដឹងនៃការទទួលរបស់យើងនោះនៅក្នុងព្រះគ្រីស្ទហើយ ។

ព្រះវរបិតាទ្រង់បានទទួលយើងរាល់គ្នា ដោយមានសេចក្តីស្រឡាញ់ស្មើៗគ្នា ដូចជាទ្រង់បានទទួលព្រះរាជបុត្រារបស់ទ្រង់ផ្ទាល់ គឺជាអង្គព្រះយេស៊ូវនោះឯង ។ យើងត្រូវតែបណ្តេញនូវគំនិតបដិសេធន៏ និងធ្វើការពិចារណានូវព្រះបន្ទូលរបស់ព្រះ រហូតដល់យើងមានពេញដោយនូវសេចក្តីពិត និងមានការធានារ៉ាប់រងនៃការទទួលរបស់យើងនោះឯង។ ដោយសារតែព្រះទ្រង់បានទទួលយើង នោះយើងក៏អាចទទួលដោយខ្លួនយើងផងដែរ ។

## ង. ការបន្ទាបខ្លួនដែលខុសឆ្គង

ជានិច្ចកាលមានវិញ្ញាណអំនួតមួយ ដែលមានការរីកចម្រើនជាច្រើនឆ្នាំ ដែលចេះតែមានកំហុស នោះយើយដែលហៅថាជាការបន្ទាបខ្លួន ។ យើងច្រៀងនូវចម្រៀងដោយពាក្យយ៉ាងដូច្នេះ "ខ្ញុំជាអ្នកក្រ ជាអ្នកបាត់បង់ ជាអ្នកមានបាប

តែត្រូវបានសង្គ្រោះដោយសារព្រះគុណ" ។ នោះមិនមែនជាការពិតទេ ។ យើងបានទទួលនូវសេចក្ដីសង្គ្រោះម្ដងរួចទៅហើយ គឺយើងគ្មាន "ការក្រ ការបាត់បង់ ជាអ្នកមានបាប" តទៅទៀតនោះឡើយ!

ជាច្រើនឆ្នាំណាស់មកហើយ ដែលយើងបានច្រៀងដោយនូវពាក្យចម្រៀងទំនុកតម្កើងចាស់ៗដ៏ទំនើបៗ ដែលមានឃ្លាថា "ចំពោះខ្ញុំដែលជាជន្លេន" ដូច្នេះ គឺមិនមែនជាពាក្យដែលព្រះទ្រង់មើលឃើញយើងនោះទេ! នេះគឺជាការផ្ទុយជំទាស់ទៅនឹងព្រះបន្ទូលរបស់ព្រះហើយ ។ យើងមិនមែនជាអ្នកក្រជាជន្លេន ឬជាសម្រាមនោះទេ ។ យើងគឺជាអ្នកដែលបានកើតជាថ្មីហើយ! យើងគឺបាននៅក្នុងព្រះគ្រីស្ទហើយ! យើងក៏ត្រូវបានទទួលនូវការអនុលោម ទៅតាមរូបភាពរបស់ព្រះអង្គពិតប្រាកដហើយ ។

រូបភាពខ្លួនឯងដ៏គ្មានតម្លៃនេះ គឺអាចត្រូវបានទទួលនូវការបរាជ័យ ក្នុងជីវិតរបស់យើងដែលមានសេចក្ដីអំនួតនោះហើយ ។ ការគិតអំពីរបៀបគ្មានតម្លៃយ៉ាងណានោះ យើងក៏អាចមើលទៅហាក់ដូចជាបានបង្ហាញ នូវការបន្ទាបខ្លួនហើយ ប៉ុន្តែ វាបានសង់ឡើងនូវទីមាំមួននៃការបរាជ័យលើជីវិតរបស់យើងទៅវិញទេ គឺវាបានទុកយើងឱ្យឃ្លាតពីសេចក្ដីពិត ពីសក្ដានុពលរបស់យើង ដែលមានពេញលេញហើយនៅក្នុងព្រះយេស៊ូវគ្រីស្ទនោះវិញ ។

## ច. ការបន្ទាបខ្លួនដ៏ពិត

ការបន្ទាបខ្លួនដ៏ពិត គឺបានមកពីការទទួលស្គាល់ពីព្រះគុណរបស់ព្រះ ។ ការបន្ទាបខ្លួនគឺជាការទទួលស្គាល់ដែលដែលបានមាននៅគ្រអតីតកាល ដែលយើងធ្លាប់ជាខ្មាំងសត្រូវរបស់ព្រះ គឺមិនមែនជាការបម្រើ ដល់សេចក្ដីស្រឡាញ់ដ៏អស្ចារ្យរបស់ព្រះអង្គ គឺដែលទ្រង់បានប្រោសលោះដល់យើងរាល់គ្នា ដើម្បីឱ្យយើងអាចចូលមកបានទាំងអស់គ្នា ដែលទ្រង់បានបង្កើតយើងរាល់គ្នាឱ្យមាននៅនោះ ។

ការបន្ទាបខ្លួនដ៏ពិតគឺជាគំនិតដ៏ល្អដែលមកពីព្រះ ។ វាជាការដឹងថា គ្រប់ទាំងអស់ដែលយើងមាន ដែលយើងអាចធ្វើបាន គឺដោយសារតែព្រះគុណដ៏ធំលើសលន់ និងសេចក្ដីមេត្តាករុណារបស់ព្រះអង្គចំពោះយើងរាល់គ្នានោះឯង ។

វាគឺជាសេចក្ដីពិតដែលយើងរាល់គ្នា មិនត្រូវ "គិតជាជាងការដែលគួរគិត" នោះទេ គឺយើងមិនត្រូវទាំងមានគំនិតខ្ពី ជាជាងការអ្វីដែលគួរមាននោះដែរ ។

ប្រសិនបើយើងត្រូវតែមើលឃើញដោយខ្លួនយើង ដូចជាព្រះយេស៊ូវ ហើយធ្វើការងារជារបស់ព្រះយេស៊ូវ នោះយើងត្រូវតែបណ្ដេញ នូវការចាស់ៗរបស់យើងជាទីមួយ ដូចជាការគ្មានតម្លៃ "មិនអាចឱ្យកើតមានបាន" ចំពោះរូបភាពនិងការរើពួកវាចេញពីកំណើថ្មីនោះឯង ។

## V. ការបំផ្លាស់ប្ដូរនូវរូបភាពទាសករ

មនុស្សជាច្រើនមានរូបភាពជាអ្នកទាសករ ដោយខ្លួនគេផ្ទាល់ ។ ពួកគេបានមើលឃើញជីវិតរស់នៅដោយខ្លួនគេផ្ទាល់ថា មានការទាបបំផុត ទ័លក្រ និងជាទាសករ ។ ពួកគេគ្មានលទ្ធភាពនឹងបង្ហាញពីរូបភាព ដែលខ្លួនគេបានទទួលមកពីព្រះនូវព្រះពរ និងភ័ព្វប្រេងសំណាងនោះទេ ។ ពួកគេមិនបានមើលឃើញដោយខ្លួនឯងថា ជាកូនរបស់ស្ដេចនោះឡើយ ។

## ក.គំរូរបស់ពួកអ៊ីស្រាអែល

នៅក្នុងប្រទេសអេស៊ីព្ទ ពួកកូនចៅអ៊ីស្រាអែលមិនបានដឹងអ្វីទាំងអស់ គឺគេដឹងតែត្រឹមតែមានភាពជាទាសកររាប់រយ

ឆ្នាំប៉ុណ្ណោះ ។ នៅពេលដែលមានកំណើត គឺជាកូនប្រុស-ស្រី ដែលបានទទួលនូវការប្រោសលោះមកពីព្រះ នោះពួកគេបាន មានសេចក្តីត្រូវការនូវការបើកសម្តែងពីអ្នកណា ដែលពួកគេ ជាមនុស្សដែលបានទទួលការតាំងសញ្ញាមកពីព្រះនោះឯង ។

### ១. មាស ប្រាក់

ព្រះទ្រង់សព្វព្រះហឫទ័យបំផ្លាស់បំប្រែ នូវរូបភាពអាត្មានិយមរបស់ពួកគេ ចេញពីភាពទ័លក្រ ពីទាសភាព ឱ្យមានរូបភាពនៃការកើតជាថ្មី គឺជាកូនដែលបានទទួលនូវការប្រោសលោះមកពីព្រះនោះឯង ។ ទ្រង់បានបង្រៀនដល់ពួកគេឱ្យចេះ សុំមាស ប្រាក់ គ្រឿងអលង្កា ព្រមទាំងសម្លៀកបំពាក់ ដែលមានតម្លៃថ្លៃផងដែរ មកពីពួកបងប្អូនសាសន៍អេស៊ីព្ទ ។ ពួកគេមិនដែលបានយក មាស ប្រាក់ គ្រឿងអលង្កា ចេញពីក្នុងហឹបរបស់ពួកគេនោះឡើយ។ ពួកគេមិនដែលបានតែងកាយ ដោយបំពាក់របស់ទាំងនោះ ធ្វើជាគ្រឿងលម្អនោះដែរ គឺពួកគេបានសន្សំទុក កំឡុងពេលដែលពួកគេបានធ្វើដំណើរតាមផ្លូវ តាមទីរហោស្ថាននោះវិញ ។ ព្រះទ្រង់បានមានបន្ទូលទៅកាន់ពួកគេ ឱ្យទុកដាក់ប្រាក់ មាស និងសម្លៀកបំពាក់ ឱ្យកូនប្រុស-ស្រីរបស់ពួកគេវិញ។

ព្រះគម្ពីរនិក្ខមនំ ៣:២១-២២ក

កូនចៅប្រុស-ស្រីរបស់អ៊ីស្រាអែលៈ ការជ្រើសរើសដល់ពួកបណ្តាជនរបស់ព្រះ គឺមិនបានជ្រើសរើសចេញពីស្រុកដោយនូវភាព ជាទាសករនោះឡើយ ។ រីឯសម្លៀកបំពាក់ និងស្បែកជើង ដែលមិនដែលបានស្លៀកពាក់ក្នុងពេលធ្វើដំណើររបស់ពួកគេ ទៅកាន់ទឹកដីសន្យានោះ គឺជាសម្លៀកបំពាក់ និងគ្រឿងអលង្កាដ៏មានផាសុខភាពនោះឯង ។ ព្រះទ្រង់បានបំផ្លាស់បំប្រែ នូវរូបភាពអាត្មានិយមចាស់ៗរបស់ពួកគេ ។ ទ្រង់ក៏បានបំបាក់បំបែកនូវរូបភាពអាត្មានិយមចាស់របស់ពួកគេ ដោយខ្លួនគេផ្ទាល់ ។

### ២. ការហួសកំណត់

គ្រាក្រោយមកទៀត គឺនៅពេលវេលាសាងសង់រោងឧបោសថមកដល់ គឺពួកគេមានមាស ប្រាក់ ជាច្រើនបំផុតគឺជាភោគទ្រព្យ ដែលមាននៅក្នុងពួកកូនចៅអ៊ីស្រាអែល គឺដែលពួកគេបានផ្តល់ឱ្យជាច្រើនបំផុតផងដែរ ។ ហ្វូងមនុស្សទាំងឡាយបានសុំដល់លោកម៉ូសេ ឱ្យបញ្ឈប់នូវការឱ្យរបស់ពួកគេនោះ កុំឱ្យពួកគេផ្តល់ឱ្យបន្ថែមទៀតឡើយ ។

ព្រះគម្ពីរនិក្ខមនំ ៣៦:៥-៧

ក្នុងមធ្យោបាយដដែលនោះ ព្រះទ្រង់បានបំផ្លាស់បំប្រែនូវរូបភាពរបស់ពួកអ៊ីស្រាអែល ដោយការផ្លាស់ប្រែខ្លួនគេផ្ទាល់តែម្តង គឺទ្រង់សព្វព្រះហឫទ័យបំផ្លាស់បំប្រែ នូវរូបភាពអាត្មានិយមខាងផ្នែកភាពទ័លក្រ និងទាសភាព អំពើបាបនោះវិញ ។ ទ្រង់សព្វព្រះហឫទ័យចង់ឱ្យយើងមានការពិសោធន៍នូវសេចក្តីអំណរ ពីសេចក្តីសង្គ្រោះរបស់យើងនោះឯង ។

## VI. ការបណ្តេញនូវភាពស្រមើស្រមៃ

តើធ្វើដូចម្តេចឱ្យយើងអាចទទួលបាន នូវការកំចាត់រូបភាពអាត្មានិយមចាស់ ដែលបានធ្វើមិនឱ្យគាបដល់ព្រះហឫទ័យនៃព្រះនោះ?

តើយើងអាចទទួលបាន នូវការកំចាត់ចំណងនៃភាពថោកទាប ភាពអសន្តិសុខ ការមានអារម្មណ៍ថាមិនមានភាពពេញលេញ ភាពមានទោស ការផ្តន្ទាទោស និងភាពគ្មានតម្លៃនោះបានដោយរបៀបណា?

តើយើងអាចមានការទាក់ទង ជាមួយនឹងការបរាជ័យទាំងនេះ ដោយនូវគំនិត និងការស្រមើស្រមៃនៅក្នុងជីវិតរបស់យើងដោយរបៀបណា?

ព្រះបន្ទូលរបស់ព្រះទ្រង់បានប្រទានឱ្យយើង នូវចម្លើយដែលមាននៅក្នុងព្រះគម្ពីរ ២កូរិនថូស ១០:៥ ។

ការស្រមើស្រមៃគឺមាននៅក្នុងគំនិត ។ យើងត្រូវតែគ្រប់គ្រងគំនិតរបស់យើង ហើយបណ្តេញចេញនូវគ្រប់ទាំងគំនិតដែលមានការទាស់ទទឹងដល់ព្រះបន្ទូលរបស់ព្រះ ។

សមរភូមិគឺមាននៅក្នុងគំនិតរបស់យើង នៅក្នុងព្រលឹងរបស់យើង ឆន្ទៈរបស់យើង និងអារម្មណ៍របស់យើង ។ វាមាននៅក្នុងតំបន់នេះហើយ ដែលសមរភូមិនឹងបានជាជ័យជម្នះ ឬបានជាការបរាជ័យ ។ គំនិតរបស់យើងគឺត្រូវតែបានទទួលនូវការបើកសម្តែងមកពីព្រះបន្ទូលរបស់ព្រះ ។

យើងត្រូវតែនាំចូលទៅក្នុងភាពមានទោស គ្រប់ទាំងគំនិត និងការបង្កើតនូវការស្តាប់បង្គាប់ដល់ព្រះគ្រីស្ទ ។ យើងត្រូវតែចាប់យកនូវការគ្រប់គ្រង ហើយបង្កើតនូវគំនិតស្តាប់បង្គាប់របស់យើងដើម្បីចែកនូវចំណេះដឹងដល់អស់អ្នកដែលយើងបានបង្កើតនៅក្នុងព្រះគ្រីស្ទ ។

### ក. ឱ្យឆ្លាតដូចជាពស់

ប្រសិនបើមានពស់មានពិសមួយ បានធ្លាក់ចុះមកពីលើដើមឈើ ហើយវាបានមករុំដៃយើង នោះយើងមិនគ្រាន់តែឈរនៅទីនោះនិងមើលវារៀបចំខ្ទាក់ពិសពីចង្កូមរបស់វា មកលើស្បែករបស់យើងប៉ុណ្ណោះទេ ។ គឺយើងមិនមែននៅស្ងៀមឡើយ! យើងត្រូវតែប្រញាប់ប្រញាល់គ្រវាត់វាចោលជាមួយរំពេចភ្លាមៗនោះឯង ហើយក៏ប្រញាប់ប្រញាល់ធ្វើអ្វីៗដែលយើងអាចធ្វើបាន ។ វាត្រូវតែមានការប្រញាប់ប្រញាល់ មានការសម្រេចចិត្ត គឺបញ្ចេញសកម្មភាពទប់ទល់ដោយពេញកម្លាំងភ្លាមៗជាមិនខាន ។ យើងត្រូវតែបណ្តេញពស់នោះចេញ មុនពេលដែលវាអាចចឹកយើងបាន ។

ក្នុងមធ្យោបាយដដែលនេះ យើងត្រូវតែបណ្តេញវាចេញពីចិត្តគំនិតរបស់យើង ដោយការស្អប់ខ្ពើមការនោះជាខ្លាំង និងការស្រមើស្រមៃ ទៅលើរូបភាពអាត្មានិយមចាស់ៗនោះ ។ យើងត្រូវតែស្រែកខ្លាំងៗថា "អញបដិសេធនូវគំនិតនោះហើយដោយនូវព្រះនាមព្រះយេស៊ូវ!" អាមែន ។

***ពេលដែលគំនិតចាស់របស់យើងនិយាយថា***
***"អ្នកមិនអាចធ្វើការនោះបានទេ***
***អ្នកមានសេចក្តីខ្មាសខ្លាំងណាស់" ។***

***យើងនិយាយថា "អញបដិសេធនូវគំនិតនោះហើយ***
***នៅក្នុងព្រះនាមព្រះយេស៊ូវ ។***
***ខ្ញុំអាចធ្វើគ្រប់ទាំងអស់បានដោយ***
***ព្រះគ្រីស្ទដែលទ្រង់ចម្រើនកម្លាំងដល់ខ្ញុំ" ។***

***ពេលដែលគំនិតចាស់របស់យើងនិយាយថា***
***"អ្នកមានជម្ងឺមហារីក" ។***

***យើងត្រូវនិយាយថា "អញបដិសេធគំនិតនោះ***
***ហើយក្នុងព្រះនាមព្រះយេស៊ូវ ។ ព្រះបន្ទូលរបស់ព្រះចែងថា***

***គ្មានឧបទ្រព្យចង្រៃណា នឹងមកនៅជិតអញបានឡើយ ។ អញដឹងថាដោយនូវស្នាមជាំរបស់ព្រះយេស៊ូវ នោះអញត្រូវបានទទួលនូវការប្រោសឱ្យជាហើយ" ។***

### ខ. សាស្ត្រាវុធដែលមានឫទ្ធិអំណាច

យើងមានសាស្ត្រាវុធដែលមានឫទ្ធិអំណាចដើម្បីធ្វើការបំបែកបំបាក់នូវទីមាំមួន នៅលើជីវិតរបស់យើង ។

ព្រះគម្ពីរ ២កូរិនថូស ១០:៤ក

## VII. ការដោះចេញនូវភាពអាត្មានិយមចាស់

### ក. ការធ្វើភាពជាម្ចាស់

ភាពជាម្ចាស់នៃការដោះអាត្មានិយមចាស់ចេញ គឺត្រូវបានទទួលនូវការសម្រេចចិត្ត ដោយលោកសាវ័កប៉ុលដែលមាននៅ ក្នុងព្រះគម្ពីរកូល៉ុស ។ ព្រះគម្ពីរកូល៉ុស ៣:៩-១០ ។

បន្ទាប់ពីយើងបានទទួលនូវការបើកសម្តែង មកពីព្រះបន្ទូលរបស់ព្រះថា "ចូរដោះមនុស្សចាស់ចេញ" នោះយើងត្រូវតែ "ដាក់មនុស្សថ្មីចូល" ដែលជាការបង្កើតឡើងជាថ្មីម្តងទៀត ដោយនូវចំណេះដឹងចំពោះរូបភាពរបស់ព្រះដ៏ជាអ្នកបង្កើតវានោះមក ។

### ខ. ការបង្កើតគំនិតរបស់យើងសារជាថ្មី

យើងមិនអាចបំផ្លាស់បំប្រែព្រលឹងរបស់យើង ដោយការអនុវត្តន៍របៀបណា ដោយសកម្មភាពធម្មតាៗតាមឆន្ទៈរបស់យើងក្នុងពេលភ្លាមៗ ដើម្បីឱ្យបានទទួលនូវសេចក្តីសង្គ្រោះនោះទេ ។ នោះគឺគ្រាន់តែជាជំហានទីមួយប៉ុណ្ណោះ ។ យើងកំពុងតែបានបង្កើតឡើងនូវព្រលឹងរបស់សារជាថ្មី និងត្រូវធ្វើឱ្យបានជាការអនុលោមទៅតាម និងការផ្លាស់ប្តូរទៅក្នុងរូបភាពនៃអ្នកបង្កើតរបស់យើង គឺដែលយើងបានពិចារណានៅក្នុងព្រះបន្ទូលរបស់ព្រះនោះឯង ។

ព្រះគម្ពីររ៉ូម ១២:២ ។

លោកសាវ័កប៉ុលបានសរសេរថា មនុស្សគឺជារូបភាព និងជាសិរីល្អរបស់ផងព្រះ ។

ព្រះគម្ពីរ ២កូរិនថូស ៣:១៨

ប្រសិនបើយើងត្រូវបានបង្កើតឡើង នៅក្នុងរូបភាពរបស់ព្រះ ហើយដូចជារូបភាពដែលបានបង្កើតឡើងជាថ្មីគឺដែលបានទទួលនូវការកែជាថ្មីឡើងវិញ ឱ្យបានដូចជារូបភាពរបស់ព្រះបន្ទាប់មក វាត្រូវបានជាអ្នកជេរប្រមាថទៅដល់ព្រះ គឺដែលបាននិយាយជាពាក្យអវិជ្ជមាន ដោយខ្លួនឯងនោះឯង ។

យើងមិនត្រូវនិយាយដោយខ្លួនឯងថា យើងបាននៅក្នុងគ្រាអតីតកាលនោះទេ ។ យើងគឺត្រូវបានបង្កើតឡើងជាថ្មីហើយ ។ យើងត្រូវបានទទួលនូវការបំផ្លាស់បំប្រែជាថ្មីហើយគឺពីសិរីល្អទៅដល់សិរីល្អ ។

## VIII. ការបណ្តេញនូវរូបភាពដែលជាកណ្តួបចេញ

### ក. រូបភាព "ដែលអាចធ្វើបាន"

ប្រសិនបើយើងត្រូវតែរស់នៅជាជីវិត ដែលមានជ័យជម្នះមានជោគជ័យ ជាជីវិតត្រីស្ថាន នោះយើងត្រូវការការរើចេញនូវពាក្យថា "មិនអាចធ្វើ" គឺឱ្យទៅជារូបភាព "ដែលអាចធ្វើ" វិញ ។ យើងត្រូវការយល់ថា យើងអាចធ្វើនូវអ្វីដែលព្រះបន្ទូលថែងថា យើងអាចធ្វើនោះវិញ ។

### ខ. គំរូរបស់អ្នកយកការណ៍ទាំ១២នាក់

ព្រះទ្រង់បានសន្យានឹងប្រទានឱ្យនូវទឹកដីសន្យា គឺជាទឹកដីកាណានទៅដល់ពួកអ៊ីស្រាអែល ។ នៅថ្ងៃបន្ទាប់មក គឺពេល

ដែលព្រះអម្ចាស់ទ្រង់មានបន្ទូលបញ្ជូនមនុស្សម្នាក់ ពីពូជអំបូរនិមួយៗនៃកុលសម្ព័ន្ធទាំង១២ ដើម្បីឱ្យបានចេញទៅដល់ទឹកដីសន្យា និងនាំត្រឡប់មកវិញនូវរបាយការណ៍នោះ ។ នៅចុងនៃថ្ងៃទី៤០ ពួកគេក៏បានវិលត្រឡប់មកវិញ ជាមួយនឹងរបាយការណ៍របស់ពួកគេម្នាក់ៗ ។

ព្រះគម្ពីរជនគណនា ១៣:២៧-២៨ក,៣១-៣៣

១. យើងមានលទ្ធភាព ជនគណនា ១៣:៣០

២. យើងគ្មានលទ្ធភាពទេជនគណនា ១៣:៣១-៣៣

៣. ការផ្សេងពីនេះគឺជាព្រះ

លោកកាលែប និងលោកយ៉ូស្វេបានទទួលនូវការបើកសម្តែងដ៏ពិតមកពីព្រះ ។ គឺពួកគាត់បាននិយាយដូចជាអ្នកដែលបានត្រូវបង្កើតឡើងជាថ្មី ដែលត្រូវតែនិយាយ ។ គឺពួកបាននិយាយថា "សូមឱ្យពួកយើងឡើងទៅតែម្តង នោះនឹងអាចចាប់យកបានហើយ គឺយើងទាំងអស់គ្នានឹងមានលទ្ធភាពទទួលនូវជ័យជម្នះបាន" ។ ពួកគេក៏បានបន្តទៅទៀតនៅក្នុងព្រះគម្ពីរជនគណនា ១៤:៨-៩ ។ រីឯពួកអ្នកទាំង១០នាក់ទៀត បានឃើញពីសភាពការណ៍ដូចៗគ្នា ដែលកាលែប និងយ៉ូស្វេបានឃើញដែរ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ពួកគេមិនមានភ្នែកនឹងមើលឃើញនូវភាពដ៏ធំអស្ចារ្យរបស់ព្រះនោះបានដែរ ។ ពួកគេបានត្រឹមតែក្រឡេកមើលទៅតាមលទ្ធភាព ខាងឯធម្មជាតិរបស់ពួកគេតែប៉ុណ្ណោះ ហើយក៏បានមើលទៅខ្លួនគេដូចជាកណ្តូបទៅវិញ ។ ពួកគេបានមើលទៅខ្លួនពួកគេ "មានរូបភាពជាកណ្តូប" វិញ ។

## គ. ជម្រើសរបស់យើង

នៅសម័យសព្វថ្ងៃនេះ យើងត្រូវការបណ្តេញនូវរូបភាពជាកណ្តូបចេញ ដោយខ្លួនយើងផ្ទាល់ ហើយដាក់រូបភាពនៃការកើតជាថ្មីបញ្ចូលមកវិញ ។ ដូចជាលោកកាឡែប និងលោកយ៉ូស្វេ ដែលយើងគួរតែដាក់សេចក្តីជំនឿរបស់យើង ចូលទៅក្នុងភាពដ៏ធំអស្ចារ្យរបស់ផងព្រះ ហើយចាប់ផ្តើមនិយាយថា "យើងមានលទ្ធភាពគ្រប់គ្រាន់ នឹងចាប់យកទឹកដីរបស់យើងនោះបាន!"

អស់រយៈកាលជាច្រើនមកហើយ ដែលរូបភាពអាត្មានិយមចាស់របស់យើង បានត្រឡប់មកជាអ្នករារាំងដ៏មានកម្លាំងម្នាក់ គឺជាការរក្សាយើងឱ្យរួចពីការនៅ ការមាន និងការធ្វើគ្រប់ទាំងអស់ ដែលព្រះទ្រង់បានមានសម្រាប់យើងក្នុងការបង្កើតយើងឡើងជាថ្មីឱ្យមាននៅនោះឯង ។ យើងគួរគប្បីនិយាយដោយមានកម្លាំងរឹងប៉ឹង ទៅកាន់ភ្នំនៃកាលៈទេសៈនោះដោយពាក្យថា "ចូររើចេញពីទីនេះទៅកាន់សមុទ្រចុះ!"

ព្រះគម្ពីរម៉ាថាយ ២១:២១

សាស្ត្រាវុធនៃការធ្វើសង្គ្រាមរបស់យើង គឺជាឫទ្ធិអំណាចតាមរយៈព្រះ ដើម្បីរុញច្រានទីមាំមួនទាំងឡាយចេញ ។ ទីមាំមួនទាំងឡាយនោះ គឺជាការបង្ខាំងនូវរូបភាពអាត្មានិយមចាស់របស់យើង នោះនឹងត្រូវធ្វើឱ្យខ្ទេចខ្ទី និងត្រូវធ្វើឱ្យធ្លាក់ចុះទៅ ។ យើងនឹងបានត្រឡប់មកជាទាំងអស់ ដែលព្រះទ្រង់មានបន្ទូលថា យើងគឺជា ។ យើងជាអ្នកដែលបានបង្កើតមកជាថ្មីហើយ គ្រប់ទាំងរូបភាពអាត្មានិយមចាស់បានកន្លងបាត់ទៅ មើលគ្រប់ទាំងអស់រាប់បញ្ចូលទាំងរូបភាពអាត្មានិយមចាស់ដែលរុករកឃើញជាថ្មីឡើងវិញ នោះនឹងបានត្រឡប់មកជាថ្មីឡើងដែរ ។ ខ្ញុំអាចធ្វើគ្រប់ទាំងអស់បាន ដែលព្រះយេស៊ូវ

ទ្រង់បានធ្វើដែរ ។ ខ្ញុំអាចធ្វើគ្រប់ទាំងអស់បានដោយសារព្រះគ្រីស្ទទ្រង់រស់នៅក្នុងខ្ញុំ ។

ព្រះគម្ពីរ ២កូរិនថូស ៥:១៧

## ក្រុមពិភាក្សា

១. ចូរធ្វើការអធិស្ឋានថា ព្រះទ្រង់នឹងបង្ហាញលោកអ្នកម្នាក់ៗ ពីគំនិតដែលខូចទៅ ឬពីការស្រមើស្រមៃដែលត្រូវការ នូវការកែតម្រូវឱ្យបានល្អត្រឹមត្រូវឡើងវិញ ហើយទីមាំមួន ដែលត្រូវការរំលំដួលចុះនោះវិញ ។

២. ចូរធ្វើការចែកចាយនូវគំរូនៃពេលវេលា ចំនួនពីរបីដងដែលមានរូបភាពដូចជាសត្វកណ្ដូប ដែលមានវត្ថុមាន ហើយនឹងអ្វីដែលជាលទ្ធផល នៃស្ថានការណ៍ទាំងនោះដែលមាននៅ ។

៣. ចូរអធិស្ឋានថា ប្រព័ន្ធរូបភាពរបស់លោកអ្នកពេល ឥឡូវនេះនឹងក្លាយទៅជាកងកម្លាំងមួយ ដ៏មានអំណាចចេស្ដាសម្រាប់ព្រះ ។

## ការសិក្សាដោយខ្លួនឯង

១. វាងាយនឹងចាប់យកនូវពេលវេលាខ្លះៗ ដើម្បីធ្វើការបំបាក់បំបែកនូវទម្លាប់គំនិត ឬក៏ការនិយាយស្ដីចាស់ៗជាគំនិតអវិជ្ជមាន ។ នៅពេលដែលគំនិតទាំងនេះបានចូលមក គឺបានធ្វើឱ្យមានការខឹតខំប្រឹងប្រែង ដើម្បីបដិសេធនិងបណ្ដេញពួកវាជាប្រញាប់ប្រញាល់បំផុត ។ ចូរបន្តប្រកាស់ពីអ្វីដែលព្រះ បន្ទូលរបស់ព្រះបានចែងទុកមក ។

២. ប្រសិនបើលោកអ្នកបានកំពុងតែទទួល នូវអាការៈណាមួយ ដែលលោកអ្នកបានដឹងមកពីបណ្ដាសា ចំណង ឬក៏ជាការមានជម្ងឺរោគាជាដើម នោះត្រូវធ្វើការស្ដីបន្ទោសពួកវាជាប្រញាប់ប្រញាល់បំផុត ហើយធ្វើការចាប់ផ្ដើមប្រកាស់ពីអ្វី ដែលព្រះបន្ទូលរបស់ព្រះបានចែងទុកមកអំពីសេរីភាពរបស់លោកអ្នក ។

៣. តើលោកអ្នកកំពុងតែមានគម្រោងផែនការយ៉ាងណា ក្នុងការស្ដាប់បង្គាប់តាមព្រះគម្ពីរ ២កូរិនថូស ១០:៥ គឺជាការនាំមកនូវគំនិតគ្រប់យ៉ាង ចូលទៅក្នុងជាប់ទោសដើម្បីធ្វើឱ្យវាមានការស្ដាប់បង្គាប់ដល់ព្រះគ្រីស្ទវិញ?

# រូបភាពនៃការកើតជាថ្មី

## *មេរៀនទី ៥: រូបភាពរបស់យើងនៅក្នុងព្រះគ្រីស្ទ*

### I. រូបភាពរបស់យើងនៅក្នុងព្រះគ្រីស្ទ

#### ក. កំណើតថ្មី

នៅពេលដែលយើងបានទទួលព្រះយេស៊ូវគ្រីស្ទ ធ្វើជាព្រះអង្គសង្គ្រោះផ្ទាល់របស់យើងភ្លាម នោះយើង "បានកើត ជាថ្មី" ចូលទៅក្នុងក្រុមគ្រួសារថ្មីរបស់ព្រះហើយ ។

ព្រះយេស៊ូវទ្រង់មានបន្ទូលទៅលោកនីកូដេម នៅក្នុងព្រះគម្ពីរយ៉ូហាន ៣:៧ ។

ព្រះយេស៊ូវទ្រង់បានធ្វើការប្រកាសយ៉ាងច្បាស់ ទៅកាន់លោកនីកូដេមថា ទ្រង់មិនបានមានបន្ទូលអំពីការកើតខាងសាច់ឈាមទេ គឺមានបន្ទូលអំពី "ការកើតម្តងទៀត" វិញ មានន័យថា ការកើតខាងវិញ្ញាណវិញ ។

ព្រះគម្ពីរយ៉ូហាន ៣:៥-៦

មុនពេលដែលបានទទួលព្រះយេស៊ូវ មកធ្វើជាព្រះអង្គសង្គ្រោះរបស់យើង គឺដែលយើងបានរស់នៅជារូបកាយរបស់យើង (ការកើតមកខាងសាច់ឈាម) និងព្រលឹងរបស់យើង (ឆន្ទៈ ការសោយនូវអារម្មណ៍ និងបំណង) នោះហើយដែលយើងបានស្លាប់ខាងវិញ្ញាណ ។ នៅពេលដែលយើងបានទទួលសេចក្តីសង្គ្រោះភ្លាម នោះយើង "បានកើតម្តងទៀត" ខាងវិញ្ញាណ ។ វិញ្ញាណរបស់យើងបានត្រឡប់មកជាមានព្រលឹងរស់វិញ ។ យើងបានត្រឡប់មកជាមានកំណើតថ្មីនៅក្នុងព្រះយេស៊ូវគ្រីស្ទ ។ យើងបានកើតនៅក្នុងក្រុមគ្រួសារថ្មី គឺជាក្រុមគ្រួសាររបស់ព្រះ ។ ពេលដែលយើងបានកើតនៅក្នុងក្រុមគ្រួសាររបស់ព្រះ នោះយើងបានត្រឡប់មកជាកូនរបស់ព្រះអង្គហើយ ។

#### ខ. កូនរបស់ព្រះ

ព្រះគម្ពីរ ១យ៉ូហាន ៣:១ក

យើងត្រូវការយល់ដឹងថា យើងជាកូនប្រុស-ស្រីនៃព្រះវរបិតាដ៏មានពេញដោយអំណាចចេស្តាបំផុត ដ៏មានពេញដោយប្រាជ្ញាវៃឆ្លាតបំផុត នៅក្នុងចក្រវាឡទាំងមូលនេះ ។ យើងមិនអាចជួយខ្លួនយើងបានទេ តែយើងពិតប្រាកដថាជីវិតរបស់យើង តួនាទីរបស់យើង សិទ្ធិរបស់យើង ផលប្រយោជន៍របស់យើង និងអនាគតរបស់យើង មានការផ្លាស់ប្រែដ៏ពេញលេញបំផុត ។ ការយល់ដឹងពីទំនាក់ទំនងក្រុមគ្រួសារថ្មីរបស់យើង គឺជាកូនប្រុស កូនស្រី គឺអាចមានការផ្លាស់ប្រែដ៏ពេញលេញ ចំពោះមធ្យោបាយដែលយើងគិតអំពីខ្លួនយើងនេះ ។

ព្រះគម្ពីររ៉ូម ៨:១៤

នៅពេលដែលយើងបានទទួលព្រះយេស៊ូវគ្រីស្ទ ធ្វើជាព្រះអម្ចាស់ និងជាព្រះអង្គសង្គ្រោះរបស់យើង នោះយើងបានត្រឡប់ទៅជាកូនរបស់ព្រះ ។

ព្រះគម្ពីរយ៉ូហាន ១:១២

ពាក្យថា "សិទ្ធិ" មានន័យថា សិទ្ធិអំណាចពេញលក្ខណៈច្បាប់ គឺយើងបានត្រឡប់មកជាកូនប្រុស កូនស្រីរបស់ព្រះ ។

#### គ. ទាយាទ (អ្នកទទួលមរតក) របស់ព្រះ

ព្រះទ្រង់មិនមែនគ្រាន់តែបង្កើតយើងមក ឱ្យបានធ្វើជាកូនរបស់ទ្រង់ប៉ុណ្ណោះទេ គឺទ្រង់ក៏ប្រទានពរដល់យើងឱ្យបានទទួលនូវមរតក ដែលមានប្រយោជន៍ប្រហែល៧គ្នា ដូចជាព្រះ

យេស៊ូវដែរ ។ យើងបានត្រូវតភ្ជាប់ជាទាយាទជាមួយនឹងព្រះគ្រីស្ទ ។

ព្រះគម្ពីររ៉ូម ៨:១៧ក

ទ្រព្យសម្បត្តិនិងភាពជាម្ចាស់របស់ព្រះវរបិតា គឺបានធ្វើជារង្វាស់ទាំងអស់ ហើយគ្រប់ទាំងអស់នោះឯងដែលព្រះដ៏ជាព្រះវរបិតាទ្រង់បានជាកម្មសិទ្ធិ ដល់ព្រះរាជបុត្រារបស់ទ្រង់ ។ តើវាជាសេចក្តីពិតចំពោះយើងដ៏លើសលុបយ៉ាងណាហ្ន៎ ដែលយើងបានកើតមកក្នុងក្រុមគ្រួសាររបស់ព្រះនេះ ហើយក៏បានត្រឡប់មកភ្ជាប់ខ្លួនជាទាយាទ ជាមួយនឹងព្រះយេស៊ូវគ្រីស្ទយ៉ាងនេះ ។ មរតកទាំងអស់របស់ទ្រង់ត្រូវបានត្រឡប់មកជាមរតករបស់យើងដែរ ។

អ្នកមានទាំងអស់នៅឯនគរស្ថានសួគ៌ គឺជាកម្មសិទ្ធិរបស់ព្រះយេស៊ូវ ហើយដោយសារតែយើងបានភ្ជាប់ជាទាយាទជាមួយនឹងទ្រង់ នោះគ្រប់ទាំងអស់ដែលជាអ្នកមាននៅឯនគរស្ថានសួគ៌ ក៏ជាកម្មសិទ្ធិរបស់យើងដែរ ។

អេភេសូរ ១:៣

## ឃ. ភាពជាម្ចាស់នៃមរតករបស់យើង

តាមសេចក្តីជំនឿនៅក្នុងព្រះយេស៊ូវ នោះយើងបានកើតនៅក្នុងក្រុមគ្រួសាររបស់ព្រះ ហើយបានត្រឡប់មកជាកូនប្រុស កូនស្រីរបស់ព្រះ ។ យើងជាកូនរបស់ព្រះ គឺយើងបានទទួលនូវសេចក្តីសន្យាថានឹងបានទទួលនូវមរតកនោះ ។

ព្រះគម្ពីរកាឡាទី ៣:២៦

ព្រះគម្ពីរអេសេគាល៤៦:១៦

ពេលដែលយើងមានកំណើតថ្មី នោះយើងត្រូវតែបានកាន់កាប់នូវភាពជាម្ចាស់របស់យើង ។ យើងត្រូវតែបានកាន់កាប់នូវអ្វីដែលជាសិទ្ធិពេញលេញ មរតកទាំងអស់នោះហើយ គឺជារបស់យើង ។

## ង. ការបានទទួលនូវផលប្រយោជន៍របស់យើង

តើគួរឱ្យអស្ចារ្យយ៉ាងណាទៅហ្ន៎ ដែលធ្វើឱ្យយើងដឹងអំពីផលប្រយោជន៍របស់យើង ជាកូនប្រុសកូនស្រីរបស់ព្រះវរបិតានៃយើង ដែលគង់នៅស្ថានសួគ៌នោះ ។ តើគួរឱ្យរំភើបយ៉ាងណាទៅ ដែលវាបានបញ្ជាក់ថាយើងមិនបាច់រង់ចាំ រហូតដល់យើងបានទទួលនូវនគរស្ថានសួគ៌ ក្នុងការចាប់ផ្តើមនូវសេចក្តីអំណរ ជាមួយនឹងមរតករបស់យើងនោះ ។

ព្រះគម្ពីរភីលីព ៤:១៩

យើងបានចាប់ផ្តើមសេចក្តីអំណរ នឹងមរតករបស់យើងនៅពេលកតឡូវនេះ គឺជាពេលដែលយើងបានកើតជាថ្មី គឺបាន "កើតម្តងទៀត" ចូលទៅក្នុងក្រុមគ្រួសាររបស់ព្រះ ។

ពេលដែលយើងបានកើជាថ្មី គឺយើងបានជាកូនរបស់ព្រះ ហើយក៏បានភ្ជាប់ជាទាយាទជាមួយនឹងព្រះយេស៊ូវគ្រីស្ទ យើងមិនត្រូវមានការយំយែក និងទូលសូមឱ្យព្រះទ្រង់បានផ្គត់ផ្គង់នូវសេចក្តីត្រូវការរបស់យើង នៅលើផែនដីនេះទៀតទេ ។ គ្រប់ទាំងអស់ដែលព្រះទ្រង់មាន នោះគឺជារបស់យើងរួចទៅហើយ ។ គ្រប់ទាំងអស់ដែលយើងត្រូវការគឺមិនជាបញ្ហាអ្វីទេ ពីព្រោះយើងអាចនឹងបានទទួលមកពីព្រះ ដោយនូវសេចក្តីជំនឿ និងការស្តាប់បង្គាប់នោះវិញទេតើ ។

### ១. អំណាចនឹងទទួលទ្រព្យសម្បត្តិ

លោកម៉ូសេបានមានប្រសាសន៍ នូវពាក្យពេចន៍ទាំងនេះទៅដល់កូនចៅអ៊ីស្រាអែលៈ នៅក្នុងព្រះគម្ពីរចោទិយកថា ៨:១៨

២. **ធម្មជាតិក្នុងការប្រគល់ឱ្យ**

វាគឺជាធម្មជាតិ នៃការប្រទានឱ្យរបស់ព្រះវរបិតា ។

ព្រះគម្ពីរយ៉ូហាន ៣:១៦ក

ដោយសារតែយើង គឺជាកូនរបស់ព្រះវរបិតា នោះវាគួរតែបានទទួលនូវធម្មជាតិថ្មីរបស់យើង ធ្វើជាអ្នកប្រគល់ឱ្យផងដែរ ។

ព្រះយេស៊ូវទ្រង់មានបន្ទូលនៅក្នុងព្រះគម្ពីរលូកា ៦: ៣៨ ។

៣. **ឃ្លាំងនៃព្រះពរ**

នៅពេលដែលយើងថ្វាយទៅព្រះដោយសេចក្តីជំនឿនិងការស្តាប់បង្គាប់ នោះយើងនឹងមានដៃរបស់ព្រះ ធ្វើជារង្វាស់ដើម្បីប្រើប្រាស់នូវព្រះពរដល់ យើង ដូច្នេះ គ្រប់របស់ទាំងអស់ដែលយើងត្រូវការ គឺនឹងបានជាឃ្លាំងនៃមរតក ដ៏អស់កល្បរបស់យើងហើយ (ម៉ាឡាគី ៣:១០) ។

តើគួរឱ្យអស្ចារ្យយ៉ាងណាទៅហ្ន៎ ដែលយើងដឹងពីរបៀបទទួលនូវព្រះពររបស់យើង ដែលយើងកើតជាថ្មីធ្វើជាកូនប្រុស កូនស្រីរបស់ព្រះនោះ ។

## II. រូបកាយរបស់ព្រះគ្រីស្ទ

ពេលដែលយើងបានកើតជាថ្មី នោះយើងមិនត្រឹមតែបានត្រឡប់មកជាផ្នែកមួយនៃក្រុមគ្រួសាររបស់ព្រះប៉ុណ្ណោះទេ គឺតាមរយៈការធ្វើការអស្ចារ្យ ក្នុងការកើតជាថ្មីនោះថែមទៀតផង គឺយើងបានត្រឡប់មកជាផ្នែកមួយនៃរូបកាយរបស់ព្រះគ្រីស្ទ ។

ព្រះគម្ពីរ ១កូរិនថូស ១២:២៧

អ្នកជឿទាំងអស់គ្នា គឺត្រូវបានប្រមូលផ្តុំមកធ្វើជារូបកាយរបស់ព្រះគ្រីស្ទ ។ យើងគឺជាសមាជិកនៃរូបកាយនោះជាលក្ខណៈបុគ្គល ។

### ក. យើងម្នាក់ៗគឺបានជាផ្នែកមួយដ៏សំខាន់

ព្រះទ្រង់បានដាក់កន្លែងសម្រាប់អ្នកជឿគ្រប់រូប នៅក្នុងរូបកាយរបស់ព្រះអង្គ ។ ទ្រង់បានដាក់មុខងារដ៏មានន័យសម្រាប់យើងឱ្យបានពេញលេញ ។

ព្រះគម្ពីរ ១កូរិនថូស ១២:១៨

### ខ. យើងមានសេចក្តីត្រូវការសម្រាប់ម្នាក់ៗ និងអ្នកដទៃទៀតផងដែរ ។

អ្នកជឿគ្រប់រូបនៅក្នុងរូបកាយរបស់ព្រះគ្រីស្ទ គឺត្រូវការចំណែកអ្នកដទៃទៀតផងដែរ ។

ព្រះគម្ពីរ ១កូរិនថូស ១២:២១-២២,២៦

គ្រប់ផ្នែកនៃរូបកាយរបស់ព្រះគឺសុទ្ធតែសំខាន់ទាំងអស់!

គឺមានតែរូបកាយរបស់មនុស្សជាតិទេ ដែលត្រូវការមានលទ្ធភាព ដើម្បីរក្សាគ្នា ជួយគ្នា និងបង្កើតគ្នាតៗទៀត ដូច្នេះគឺត្រូវតែមានរូបកាយរបស់ព្រះគ្រីស្ទនេះ ។

## III. មុខងាររបស់យើងនៅក្នុងព្រះគ្រីស្ទ

នៅពេលដែលយើងបានទទួល នូវសេចក្តីសង្គ្រោះភ្លាមគឺជាព្រះវិញ្ញាណបរិសុទ្ធ ដែលបានជ្រមុជឱ្យយើងនៅក្នុងព្រះយេស៊ូវគ្រីស្ទ ។ តាមរយៈការធ្វើការអស្ចារ្យនូវកំណើតថ្មីនោះយើងបានត្រឡប់មកជាមានការរួបរួម ដ៏ស្និទ្ធស្នាល

ជាមួយនឹងព្រះយេស៊ូវ ។ យើងបានត្រឡប់មកជាតែមួយជាមួយនឹងព្រះអង្គ ។

ឥព្រះគម្ពីរ ១កូរិនថូស ១២:១៣

ពាក្យថា "ជ្រមុជ" គឺមានន័យថា ការប្រកាស់នូវការចុះចូលទាំងស្រុងជាមួយ នៅពេលដែលបានទទួលនូវសេចក្តីសង្គ្រោះភ្លាម យើងបានត្រឡប់មកជាអ្នកចុះចូលទាំងស្រុងជាមួយនឹងព្រះយេស៊ូវគ្រីស្ទហើយ ។

នៅពេលដែលក្រណាត់សមួយផ្ទាំង ដែលត្រូវបានដាក់ចូលទៅក្នុងធុងធំមួយ ដើម្បីជ្រលក់ឱ្យទៅជាពណ៌ក្រហម នោះក្រណាត់ដែលយកចេញមក ត្រូវបានជាពណ៌ដែលបានជ្រលក់រួចហើយនោះ ។ វាត្រឡប់មកជាការប្រកាស់ទៅជាមួយនឹងការជ្រលក់វានោះឯង គឺជា "ការជ្រមុជ" ចូលទៅខាងក្នុង ។ ក្នុងមធ្យោបាយដដែលនោះ វិញ្ញាណរបស់យើងក៏ត្រូវបានយកចេញមកជាធម្មជាតិនៃព្រះរាជបុត្រារបស់ព្រះ គឺនៅពេលដែលយើងបានទទួលជ្រមុជចូលទៅក្នុងព្រះអង្គ ដោយនូវព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងពេលដែលបានទទួលនូវសេចក្តីសង្គ្រោះក្នុងពេលភ្លាមៗនោះឯង ។ យើងបានត្រឡប់មកជាបានប្រកាស់ខ្លួនថាបានចុះចូលទាំងស្រុង ជាមួយនឹងទ្រង់នោះឯង គឺបានប្រកបយ៉ាងស្និទ្ធស្នាលជាមួយនឹងទ្រង់ ធ្វើជាផ្នែកនៃរូបកាយរបស់ទ្រង់ បានមកជាតែមួយជាមួយនឹងទ្រង់នោះឯង ។

## ក. សេចក្តីបង្រៀននៅក្នុងព្រះគម្ពីរអេភេសូរ

***គ្រប់ទាំងអស់ដែលព្រះយេស៊ូវមាន យើងក៏មានដែរ!***
***គ្រប់ទាំងអស់ដែលព្រះយេស៊ូវមាន គឺជារបស់ផងយើង!***
***គ្រប់ទាំងអស់ដែលយើងនៅយើងមាន***
***គឺដោយសារតែយើងនៅក្នុងព្រះអង្គនោះឯង ។***

លោកសាវ័កប៉ុលបានសម្តែងចំពោះតួនាទីរបស់យើង និងកម្មសិទ្ធិរបស់យើងគឺមាន "នៅក្នុងព្រះគ្រីស្ទ" ហើយក៏បានសម្តែងម្តងទៀតជាលើកទីមួយចំនួនបីជំពូក នៃគម្ពីរសំបុត្ររបស់គាត់ទៅកាន់ពួកអេភេសូរ ។

### ១. ព្រះពរដែលមានព្រះពរខាងឯវិញ្ញាណ

គាត់បានសរសេរថា យើងបានទទួលព្រះពរជាមួយនឹងព្រះពរគ្រប់បែបយ៉ាងខាងឯវិញ្ញាណ នៅក្នុងព្រះគ្រីស្ទ ។

ព្រះគម្ពីរអេភេសូរ ១:៣

គ្រប់ទាំងការមានបាន សិរីល្អ និងការចម្អែតព្រះពរ ខាងឯវិញ្ញាណដែលនៅស្ថានសួគ៌ គឺជាលទ្ធភាពសម្រាប់យើង ដើម្បីឱ្យបានទទួល និងបានសេចក្តីអំណរនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង ។

### ២. ការជ្រើសរើសនៅក្នុងព្រះអង្គ

ព្រះវរបិតាទ្រង់បានជ្រើសរើសព្រះយេស៊ូវ ។ ទ្រង់គឺជាមួយអង្គជាអ្នកជ្រើសរើស ។ ពីព្រោះយើងគឺជាអ្នកដែលនៅក្នុងទ្រង់ ឥឡូវនេះ យើងចែកចាយនៅក្នុងជម្រើសរបស់ទ្រង់ ។

ព្រះគម្ពីរអេភេសូរ ១:៤

ព្រះទ្រង់មិនបានជ្រើសរើសយើង ដោយសារតែការស្វែងរក តាមលទ្ធភាពរបស់យើង ឬក៏តាមតម្លៃផ្ទាល់ខ្លួនរបស់យើងនោះទេ ។ ទ្រង់បានជ្រើសរើសយើង គឺដោយសារតែទ្រង់គង់នៅតាំងពីអស់កល្បពីអតីតកាល គឺទ្រង់បានឃើញយើងនៅក្នុងព្រះគ្រីស្ទវិញ ។

## ៣. ការប្រុងប្រៀបទុកជាមុននៅក្នុងព្រះអង្គ

យើងធ្វើការចែកចាយ នូវការប្រុងប្រៀបរបស់ទ្រង់ ពីព្រោះយើងនៅក្នុងទ្រង់ ។

ព្រះគម្ពីរអេភេសូរ ១:៥

យើងមិនបានធ្វើការប្រុងប្រៀបទុកជាមុន ក្នុងការចំណាយពេលដ៏អស់កល្បនៅចំពោះព្រះ ពីព្រោះទ្រង់ពេញព្រះទ័យដល់យើង ជាជាងការដែលទ្រង់ពេញព្រះទ័យដល់អ្នកដទៃទៀត ។ ព្រះវរបិតាទ្រង់សព្វព្រះហឫទ័យរកមើល តាមរយៈអាយុកាលរបស់យើង និងឃើញយើងនៅក្នុងព្រះគ្រីស្ទ ។ ទ្រង់បានជ្រើសរើសយើង ពីព្រោះទ្រង់បានជ្រើសរើសព្រះយេស៊ូវ ហើយយើងគឺជាម្នាក់ដែលនៅជាមួយទ្រង់ ។

មរតករបស់យើង និងការរៀបចំទុកជាមុនរបស់យើង គឺដោយសារតែតួនាទីរបស់យើងនៅក្នុងព្រះយេស៊ូវគ្រីស្ទ ។

អេភេសូរ ១:១១

## ៤. ការទទួលនៅក្នុងព្រះអង្គ

យើងត្រូវបានទទួលទ្រង់ ដោយនូវភាពជាស្ងួនសំឡាញ់។ ការទទួលរបស់យើងដោយនូវព្រះវរបិតាគឺពីព្រោះតែយើងនៅក្នុងព្រះគ្រីស្ទ ។

ព្រះគម្ពីរអេភេសូរ ១:៦

ការប្រោសលោះ ការអត់ទោសបាប និងគ្រប់ទាំងអស់ដែលមានរបស់យើង គឺជាព្រះគុណរបស់ទ្រង់ គឺដោយព្រោះតែយើងនៅក្នុងព្រះអង្គ ។

ព្រះគម្ពីរអេភេសូរ ១:៧

## ៥. ខែលដែលនៅក្នុងព្រះអង្គ

យើងគឺត្រូវបានទទួលធ្វើជាខែល ដោយនូវព្រះវិញ្ញាណបរិសុទ្ធ គឺនៅពេលដែលទ្រង់បានរួបរួមយ៉ាងស្និទ្ធស្នាល ព្រមទាំងបានបង្កើតយើងដ៏នៅអស់កល្បគឺជាម្នាក់ជាមួយនឹងព្រះយេស៊ូវគ្រីស្ទ ។

ព្រះគម្ពីរអេភេសូរ ១:១៣

## ៦. កន្លែងអង្គុយជាមួយនឹងទ្រង់

ដោយសារតែយើងគឺជាម្នាក់ ជាមួយនឹងទ្រង់ យើងត្រូវបានអង្គុយរួមគ្នាជាមួយនឹងទ្រង់ នៅក្នុងនគរស្ថានសួគ៌ ។

ព្រះគម្ពីរអេភេសូរ ២:៦

សូម្បីតែយើងកំពុងតែបានរស់នៅ ក្នុងរូបកាយរបស់យើងនៅលើផែនដីនេះ អស់ពីលទ្ធភាពក៏ដោយក៏នៅក្នុងព្រះគ្រីស្ទយើងត្រូវបានអង្គុយ នៅក្នុងនគរស្ថានសួគ៌ដែរ ។ នៅពេលដែលព្រះយេស៊ូវទ្រង់បានបំពេញ នូវព្រះរាជកិច្ចប្រោសលោះរបស់ផងទ្រង់នោះទ្រង់បានអង្គុយនៅខាងស្តាំដៃនៃព្រះវរបិតា ។

ព្រះគម្ពីរទំនុកដំកើង ១១០:១

លោកសាវ័កប៉ុលបានបើកសម្តែងថា យើងក៏ត្រូវបានអង្គុយជាមួយនឹងទ្រង់ នៅក្នុងទួនាទីមួយដែរ ។ យើងមានសេចក្តីអំណរជាមួយនឹងផលប្រយោជន៍ទាំងអស់ នៃព្រះរាជកិច្ចបង្គ្រប់របស់ព្រះអង្គនៅលើផែនដីនេះ ។ យើងបាននៅ គឺដោយសេចក្តីជំនឿ សេចក្តីអំណរភ្លាមៗ គឺដោយការសម្រាកភ្លាមៗ ដែលមានលទ្ធភាពសម្រាប់អ្នកជឿ

គ្រប់រូប សូម្បីតែនៅក្នុងពាក់កណ្តាលព្យុះសង្ឃរានៃជីវិត ។

## ៧. ការងារល្អនៅក្នុងទ្រង់

យើងត្រូវបានបង្កើតមកនៅក្នុងព្រះគ្រីស្ទយេស៊ូវ គឺ សម្រាប់ការងារល្អនោះឯង ។

ព្រះគម្ពីរអេភេសូរ ២:១០

លោកអ័ដាមនិងនាងអេវ៉ា គឺត្រូវបានបង្កើតមក ដោយមានគោលបំណង ហើយនៅក្នុងព្រះគ្រីស្ទ យើងក៏ត្រូវបានបង្កើតមក សម្រាប់គោលបំណងតែមួយនោះឯង ។ យើងត្រូវបានបង្កើតមកឱ្យ គឺឱ្យបានធ្វើការងារព្រះអង្គនៅលើផែនដីនេះឯង យើងក៏ជារូបកាយរបស់ព្រះគ្រីស្ទ ដើម្បីអនុវត្តនៅលើផែនដីនេះ នៅកន្លែងរបស់ព្រះអង្គនោះឯង ។

នៅពេលដែលព្រះយេស៊ូវទ្រង់បានរស់នៅ និងបំពេញព្រះរាជកិច្ចនៅលើផែនដីនេះ នោះទ្រង់មានបន្ទូលទៅកាន់ពួកអ្នកជឿរបស់ទ្រង់ នៅក្នុងព្រះគម្ពីរយ៉ូហាន១៤:១២ ។

ពួកអ្នកជឿលើព្រះយេស៊ូវគ្រីស្ទ យើងក៏ជារូបកាយរបស់ព្រះយេស៊ូវដែរ ។ យើងរាល់គ្នា គឺជាដៃជាជើងរបស់ព្រះអង្គនៅលើផែនដីនេះ ។ ដែលយើងជារូបកាយរបស់ព្រះយេស៊ូវគឺយើង បាននៅតែបន្តធ្វើការងារថ្វាយព្រះអង្គ រហូតដល់សព្វថ្ងៃនេះ ។

## ៨. រូបកាយរបស់ព្រះគ្រីស្ទ

ក. ជាតំណាងឱ្យព្រះគ្រីស្ទចំពោះលោកិយ ។

ខ. នាំសេចក្តីស្រឡាញ់របស់ព្រះដល់លោកិយ ។

គ. នាំការប្រោសឱ្យជា និងការរំដោះរបស់ព្រះ ។

ឃ. នាំមនុស្សឱ្យមានចំណេះដឹង ខាងការសង្គ្រោះរបស់ព្រះ ។

## ៩. ធ្វើការនៅជិតកៀកនឹងព្រះ

យើង ដែលពីដើមជាខ្មាំងសត្រូវរបស់ព្រះអង្គ និងនៅឆ្ងាយពីព្រះអង្គគឺ "ត្រូវបានបង្កើតមកឱ្យ នៅជិតកៀកនឹងព្រះអង្គវិញ" គឺដោយសារឈាមរបស់ព្រះអង្គ ពីព្រោះតែយើងបាននៅក្នុងទ្រង់ ។

ព្រះគម្ពីរអេភេសូរ ២:១៣

ឥឡូវនេះយើងអាចមានសេចក្តីអំណរ ជាបន្តបន្ទាប់ មានការប្រកបជិតស្និទ្ធ និងមានការទំនាក់ទំនងជាមួយនឹងព្រះអង្គ ។

## ១០.បានត្រឡប់មកជាតែមួយជាមួយនឹងព្រះ

ពេលដែលយើងត្រូវបានបង្កើតនៅក្នុងទ្រង់ នោះគ្រប់ទាំងអស់ដែលជាខ្មាំងសត្រូវរវាងយើង និងព្រះនោះ គឺត្រូវបានលុបចោលទាំងស្រុងហើយ ។ យើងទាំងពីរនាក់ គឺត្រូវបានត្រឡប់មកជាតែមួយជាមួយនឹងព្រះវិញ ។

ព្រះគម្ពីរអេភេសូរ ២:១៥

មនុស្សដែលបានត្រូវបង្កើតឡើងជាថ្មី គឺមិនអាចត្រូវបានញែកចេញ ពីព្រះយេស៊ូវនិងពីកន្លែងរបស់ព្រះអង្គនោះបានឡើយ ទាំងគាត់ទាំងនាង គឺត្រូវបានរួមមកតែមួយជាមួយនឹងទ្រង់ ។

## ១១.ព្រះវិហារបរិសុទ្ធ

នៅក្នុងទ្រង់ យើងត្រូវបានសង់ឡើងនៅរួមគ្នានៅក្នុងព្រះវិហារបរិសុទ្ធ គឺបាននៅក្នុងកន្លែងរបស់ព្រះអង្គទ្រង់ផ្ទាល់នោះឯង ។

ព្រះគម្ពីរអេភេសូរ ២:២០-២២

តើគួរឱ្យរំភើបយ៉ាងណាហ្ន៎ ចំពោះការរាវរក ដែលព្រះ ទ្រង់បានជ្រើសរើសក្នុងការគង់នៅជាមួយ នឹងយើងរាល់គ្នានៅលើផែនដីនេះ ។ ទ្រង់បានជ្រើសរើសគង់នៅក្នុងយើងរាល់គ្នា ជាលក្ខណៈបុគ្គល ព្រមទាំងរស់នៅនិងសហការណ៍ជាមួយ យើងធ្វើជាពួកជំនុំរបស់ព្រះអង្គ ។

### ១២. ភាពអង់អាច/ការបញ្ជាក់នៅក្នុងទ្រង់

ដោយសារតែយើងបាននៅក្នុងព្រះអង្គ គឺបានមកជាតែមួយជាមួយនឹងទ្រង់ គឺត្រូវបានរួបរួមគ្នាទាំងស្រុងជាមួយនឹងទ្រង់ ជាកំណើតថ្មី នោះយើងបានចែកចាយពីគ្រប់យ៉ាង ដែលទ្រង់បានគង់នៅ និងពីគ្រប់យ៉ាងដែលទ្រង់មាន ។

សេចក្ដីសុចរិតរបស់ទ្រង់ បានត្រឡប់មកជាសេចក្ដីសុចរិតរបស់យើង ។ ភ័ព្វវាសនារបស់ទ្រង់ បានត្រឡប់មកជាភ័ព្វវាសនារបស់យើង ។ ជីវិតរបស់ទ្រង់បានត្រឡប់មកជាជីវិតរបស់យើង ។

នៅពេលដែលយើងបានទទួល នូវការបើកសម្ដែងពីការកើតជាថ្មី នោះយើងក៏បាននិយាយដោយរឹងប៉ឹងនៅក្នុងព្រះគម្ពីរអេភេសូរ ៣:១២ ថា :

***ខ្ញុំស្គាល់អ្នកដែលខ្ញុំបាននៅក្នុងព្រះយេស៊ូវគ្រីស្ទហើយខ្ញុំក៏បានត្រឡប់មកជាតែមួយជាមួយនឹងទ្រង់! ឥឡូវនេះខ្ញុំបានចែកចាយ ពីសេចក្ដីសុចរិតរបស់ទ្រង់ ពីភ័ព្វវាសនារបស់ទ្រង់ និងពីជីវិតរបស់ទ្រង់ហើយ!***

***ខ្ញុំត្រូវបានកើតជាថ្មីហើយ!***
***គ្រប់ទាំងសេចក្ដីចាស់បានកន្លងបាត់ទៅហើយ!***

***មើលគ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញ!***

យើងអាចចូលមកឯព្រះវត្តមានរបស់ព្រះអង្គ យ៉ាងក្លាហាន ដែលមានពេញដោយសេចក្ដីជឿជាក់ដោយ ព្រោះតែយើងបាននៅក្នុងព្រះអង្គ យើងមិននៅក្រោមបាពមានទោស និងការផ្ដន្ទាទោសតទៅទៀតឡើយ ។ យើងបានកើតជាថ្មីហើយ ។ យើងមានសេចក្ដីសុចរិតរបស់ផងព្រះ នៅក្នុងព្រះយេស៊ូវគ្រីស្ទហើយ ។

### ខ. កូននៃពន្លឺ

ព្រះយេស៊ូវទ្រង់គឺជាព្រះ ដែលទ្រង់បានសម្ដែងមកក្នុងសាច់ឈាម។ ព្រះយេស៊ូវទ្រង់ត្រូវបានបញ្ជូនមកក្នុងលោកិយដែលមានវិញ្ញាណងងឹតនេះ ដែលទ្រង់ដ៏ជាពន្លឺគឺទ្រង់បានបើកសម្ដែងនូវសេចក្ដីស្រឡាញ់ និងអំណាចចេស្ដារបស់ព្រះមកដល់អស់អ្នកដែលជឿដល់ព្រះអង្គ ។

ព្រះគម្ពីរយ៉ូហាន ៨:១២

ព្រះគម្ពីរ ១ថែស្សាឡូនិច ៥:៥

ពួកអ្នកជឿត្រូវតែរស់នៅជាកូននៃពន្លឺ ។ ពួកគេត្រូវតែរស់នៅជាជីវិតដែលមានជ័យជម្នះ តាមរយៈពន្លឺនៃការបើកសម្ដែងមកពីព្រះបនញ្ជូលរបស់ព្រះ ។ លោកសាវ័កប៉ុលបានបង្រៀនយើង ដោយការចែងមកនៅក្នុងព្រះគម្ពីរអេភេសូរ ៥:៨ ។

### គ. ការលាង ការឧទ្ទិស អំពើយុត្តិធមិ

យើងបានកើតជាថ្មីហើយ យើងត្រូវបានជ្រើសរើសមកចេញពីអំពើបាប ។ យើងត្រូវបានលាងសម្អាត ឧទ្ទិស និងត្រូវបានទទួលនូវយុត្តិធមិហើយ ។

ព្រះគម្ពីរ ១កូរិនថូស ៦:១០-១១

ដើម្បីឱ្យបានទទួលនូវការលាងសម្អាត គឺត្រូវតែបានទទួលនូវការស្អាត ។ ព្រះទ្រង់មិនអាចអនុញ្ញាតឱ្យភាពមិនស្អាតបាននៅក្នុងព្រះវត្តមានរបស់ព្រះអង្គនោះឡើយ ។ សេចក្តីយុត្តិធមិពេញលេញ និងសេចក្តីសុចរិតដ៏ពេញលេញ គឺមិនអាចចូលគ្នាជាមួយនឹងអំពើបាបបានឡើយ ។

ព្រះគម្ពីរ ១យ៉ូហាន ១:៧

"ការឧទ្ទិស" គឺបានពណ៌នាពីការប្រកបទាក់ទង ដែលមនុស្សអាចនឹងមានជាមួយនឹងព្រះ តាមរយៈសេចក្តីជំនឿលើព្រះគ្រីស្ទ ។ មានន័យថា យើងត្រូវបានជ្រើសចេញមកពីពួកវិញ្ញាណអាក្រក់ និងបានជាផ្នែករបស់ព្រះគ្រីស្ទវិញ ។ យើងត្រូវបានជ្រើសចេញមកពីចំណែកនៃលោកិយ ហើយបានទទួលនូវការប្រកបទាក់ទងជាមួយព្រះវិញ ដែលមានមូលដ្ឋានលើសេចក្តីសុចរិតរបស់ផងព្រះអង្គ ដែលត្រូវតែទម្លាក់ទោសមកលើយើងវិញនោះ ។

យើងបានទទួលនូវការលាងសម្អាត និងបានទទួលនូវការឧទ្ទិស ហើយយើងក៏ត្រូវបានទទួលនូវការយុត្តិធមិផងដែរ ។ ការបានទទួលសេចក្តីយុត្តិធមិ មានន័យថា បានទទួលនូវយុត្តិធមិដែលបានរាប់ជាសុចរិតដោយសារព្រះ ។ យើងបានរាប់ជាសុចរិត គឺវិញ្ញាណរបស់យើងបានគ្រប់លក្ខណ៍នៅចំពោះព្រះ ។ នៅក្នុងព្រះយេស៊ូវគ្រីស្ទ យើងបានកើតជាថ្មីហើយ ។ សេចក្តីចាស់បានកន្លងបាត់ទៅ គឺបានលាងស្អាតដោយសារព្រះលោហិតរបស់ព្រះយេស៊ូវ ។

ព្រះគម្ពីររ៉ូម ៣:២៨

ព្រះគម្ពីររ៉ូម ៨:៣១ខ,៣៣

ពេលដែលសាតាំងនិងបក្សពួករបស់វា បានចូលមករំឭកយើងពីរឿងអតីតកាល នោះយើងត្រូវនិយាយថា :

***សាតាំង អញបំភ្លេចឯងហើយ អញត្រូវបានលាងសម្អាតរួចហើយ អញបានទទួលនូវការឧទ្ទិសហើយ***
***ហើយអញក៏បាននូវភាពយុត្តិធមិហើយដែរ!***
***អញបានកើតជាថ្មីហើយ!***
***គ្រប់ទាំងសេចក្តីចាស់បានកន្លងបាត់ទៅហើយ!***
***មើល គ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញហើយដែរ!***

## IV. សញ្ជាតិថ្មីរបស់យើង

### ក. សេចក្តីសុចរិតរបស់យើង

យើងបានកើតជាថ្មីហើយ គឺយើអមានសញ្ជាតិជាថ្មី ។

សញ្ជាតិនៃស្រុកមួយដែលត្រូវបានកំណត់ជាសិទ្ធិ ដែលមិនអាចប្តូរបាន គឺដែលនៅក្រោមលក្ខន្តិកៈនៃជនជាតិនោះឯង ។ លក្ខន្តិកៈគឺជាច្បាប់ដ៏ធំសំខាន់បំផុតនៅលើទឹកដីនោះ ។ គ្រប់ទាំងច្បាប់ដទៃទៀតនៃជនជាតិនោះ គឺជាសិទ្ធិដើមដំបូងបំផុតដែលត្រូវបានផ្តល់ឱ្យ តាមលក្ខន្តិកៈនោះ ។ ប្រសិនបើយើងមិនដឹងពីអ្វីដែលជាសិទ្ធិរបស់យើងមានទេនោះ យើងអាចត្រូវបានដកហូតយកសិទ្ធិចេញ ដោយមនុស្សមិនហ្មត់ចត់ខ្លះៗ។

### ខ.សាករសកតាវុធរបស់យើង

នៅក្នុងពិភពលោកយើងនេះ សាតាំងបានដណ្តើមសិទ្ធិដែលបានកើតជាថ្មីរបស់យើង ។ ទោះជាយ៉ាងណាក៏ដោយ ក៏ព្រះទ្រង់បានប្រទានឱ្យយើងនូវសាស្ត្រាវុធខាងឯវិញ្ញាណ ដែលយើងត្រូវការទាមទារយកពីពួកវាមកវិញ ។

លោកសាវ័កប៉ុលបានសរសេរថែងមកថា សាស្ត្រាវុធរបស់យើង គឺមិនមែនជារបស់លោកិយនេះទេ ហើយដែលពួកគេមានអំណាចចេស្តាទេវភាពនេះ គឺមានកម្លាំងគ្រប់គ្រាន់នឹង

រុញច្រានទីមាំមួននោះបាន ។

ព្រះគម្ពីរ ២កូរិនថូស ១០:៤

ទីមាំមួនគឺដូចជាបន្ទាយមួយអញ្ចឹង ។ វាបានចងច្បាមមកលើសភាពការណ៍ មកលើចិត្តគំនិត មកលើមនុស្សម្នាក់ៗ ឬក៏មកលើអង្គការទាំងឡាយជាដើម ។ វាអាចបានធ្វើជាទីមាំមួនដែលសាតាំងបានធ្វើសម្រេចមកលើសុខភាពរបស់យើង ឬមកលើខាងផ្នែកថវិការបស់យើង ។ ទោះជាយ៉ាងណា ក៏ទីមាំមួននៅតែមានដែរ តែយើងមានសាស្ត្រាវុធដើម្បីរុញច្រានវាចុះ!

**១. ត្រូវមានការខិតខំប្រឹងប្រែង**

បើគ្មានសាស្ត្រាវុធនេះទេ គឺមិនអាចនឹងធ្វើការខិតខំប្រឹងប្រែងបានឡើង យ៉ាងហោចណាស់ក៏ត្រូវតែប្រើប្រាស់វាដែរ ។

ប្រសិនបើខ្មាំងសត្រូវ បានចូលមកប្រយុទ្ធប្រឆាំង ក៏យើងអាចនឹងធ្វើការប្រយុទ្ធតបតវិញបាន តែយើងមិនអាចប្រយុទ្ធឈ្នះបានទេ បើមិនបានប្រើសាស្ត្រាវុធរបស់គេនោះ ។ មនុស្សដែលនៅក្នុងការប្រយុទ្ធ គឺត្រូវតែមានប្រដាប់អាវុធ ចាប់ពីក្បាលដល់ចុងជើង គឺយ៉ាងហោចណាស់ ក៏គាត់ត្រូវតែប្រើសាស្ត្រាវុធរបស់គាត់ដែរ ទើបគាត់អាចប្រយុទ្ធឈ្នះខ្មាំងបាន ។

ដូចគ្នាដែរ សេចក្តីពិតសម្រាប់យើង គឺដែលយើងត្រូវតែបានកើតជាថ្មី ។ យើងត្រូវហ៊ានចំណាយនូវគ្រឿងសាស្ត្រាវុធរបស់យើងទាំងអស់ នោះយើងអាចធ្វើឱ្យខ្មាំងសត្រូវចុះចាញ់បាន គឺយើងត្រូវតែរៀនសូត្រ ពីអ្វីដែលពួកគេត្រូវតែរៀនសូត្រពីរបៀបប្រើប្រាស់ពួកវា ។

**២. ការពណ៌នា**

លោកសាវ័កប៉ុលបានពណ៌នាពីទាហាន និងពីសាស្ត្រាវុធនៃការកើតជាថ្មី នៅក្នុងព្រះគម្ពីរអេភេសូរ ។ ព្រះគម្ពីរអេភេសូរ ៦:១១-១៧ ។

៣. គ្រឿងសាស្ត្រាវុធសម្រាប់វាយលុក

មានគ្រឿងសាស្ត្រាវុធជាទូទៅពីរប្រភេទ គឺសម្រាប់ការពារ និងសម្រាប់វាយលុក ។ គ្រឿងសាស្ត្រាវុធ ខ្លះគឺសម្រាប់ការពារ នៅពេលដែលយើងចូលប្រយុទ្ធ ហើយមួយទៀត គឺសម្រាប់ប្រយុទ្ធតបតជាមួយនឹងខ្មាំងសត្រូវវិញ ។

ដាវរបស់ព្រះវិញ្ញាណ គឺជាព្រះបន្ទូលរបស់ព្រះជាអាវុធសម្រាប់ចូលប្រយុទ្ធ គឺជាការសម្តែងប្រកាសព្រះរាជសារ ។ នៅពេលដែលយើងនិយាយពីព្រះបន្ទូលរបស់ព្រះដោយសេចក្តីជំនឿ នោះអារក្សត្រូវតែចេញទៅ។ វាគ្មានអ្វីការពារប្រឆាំងទាស់នឹងគ្រឿងសាស្ត្រាវុធនេះបានឡើយ ។

ព្រះទ្រង់បានប្រទានឱ្យយើង នូវសាស្ត្រាវុធនេះ គឺយើងត្រូវតែរៀនប្រើវា ។ យើងបានកើតជាថ្មីហើយ គឺយើងត្រូវតែនិយាយពីព្រះបន្ទូលរបស់ព្រះទៅគ្រប់កាលៈទេសៈ ដែលចង់រុញច្រានយើងចុះនោះឯង ។

## គ. ការសរុបសេចក្តី

យើងមានរូបភាពថ្មីនៅក្នុងព្រះគ្រីស្ទហើយ ។ តាមរយៈការអស្ចារ្យពីកំណើតថ្មី ដែលយើងបានកើតចូលទៅក្នុងក្រុមគ្រួសាររបស់ព្រះ ។ យើងជាកូនប្រុសកូនស្រីរបស់ព្រះយើងបានត្រឡប់មកជាទាយាទរួមជាមួយនឹងព្រះយេស៊ូវ ។ គ្រប់

ទាំងអស់គឺជារបស់ផងទ្រង់ គឺរបស់យើងទាំងអស់ ត្រូវបានចែកចាយហើយ ។ យើងនៅក្នុងទ្រង់គឺដោយសារតែយើងមានតួនាទីថ្មី នោះយើងត្រូវតែឈរលើមូលដ្ឋានដែលមានព្រះពរ មានការជ្រើសរើស មានការប្រុងប្រៀបទុកជា មុនមានការទទួល មានការបិតត្រា និងមានការអង្គុយខាងឯវិញ្ញាណជាមួយនឹងព្រះអង្គរួចហើយ ។

យើងបានកើតជាថ្មីនៅក្នុងព្រះគ្រីស្ទ ដើម្បីធ្វើការងារល្អរបស់ផងទ្រង់នៅលើផែនដីនេះ ។ យើងគឺជាម្នាក់ដែលធ្លាប់ជាខ្មាំងសត្រូវរបស់ព្រះអង្គ គឺត្រូវបានអនុញ្ញាតឱ្យមានការប្រកបជិតស្និទ្ធជាមួយនឹងព្រះអង្គវិញហើយ ។ យើងគឺជាព្រះវិហារបរិសុទ្ធរបស់ផងទ្រង់ ។ យើងមានការអង់អាច និងការជឿជាក់ដ៏ថ្មីស្រឡាង គឺដោយព្រោះតែសេចក្តីជំនឿរបស់យើងនៅក្នុងទ្រង់នោះឯង ។

យើងដែលធ្លាប់បាននៅក្នុងសេចក្តីងងឹត ម្តងរួចមកហើយ តែឥឡូវនេះគឺត្រូវបានរាប់ជាកូននៃពន្លឺវិញ ។ យើងបានទទួលនូវការលាងសម្អាត ការឧទ្ទិស និងមានយុត្តិធម៌ហើយ ។ យើងមានសិទ្ធិជាពលរដ្ឋរបស់ព្រះ គឺដែលបានកើតជាថ្មី នោះយើងត្រូវតែដាក់ដៃទាំងអស់របស់យើងថ្វាយទៅព្រះ ហើយដោយមានដាវរបស់ព្រះវិញ្ញាណគឺជាព្រះបន្ទូលព្រះ ក៏ត្រូវបានរាប់ឡើងវិញជាមរតករបស់យើង ជាកម្រៃរបស់យើង ព្រមទាំងជាសិទ្ធិរបស់យើង គឺដែលយើងបានកើតជាថ្មីនៅក្នុងព្រះយេស៊ូវគ្រីស្ទនោះឯង ។

## V. យើងជាពូជរបស់លោកអ័ប្រាហាំ

លោកសាវ័កប៉ុលបានសរសេរថែងទុកមកថា ប្រសិនបើយើងមានសេចក្តីសេចក្តីជំនឿ នោះយើងជាពូជរបស់លោកអ័ប្រាហាំហើយ ។ នេះគឺជាការសំខាន់ ពីព្រោះយើងបានជាពូជរបស់លោកអ័ប្រាហាំ យើងមានសិទ្ធិ និងមានឯកសិទ្ធិជាច្រើន ។

ព្រះគម្ពីរកាឡាទី ៣:៦-៧

### ក. សេចក្តីសន្យារបស់ព្រះចំពោះលោកអ័ប្រាហាំ

នៅពេលដែលព្រះ ទ្រង់បានត្រាស់ហៅលោកអាប់រ៉ាម (ក្រោយមកត្រូវហៅថា អ័ប្រាហាំវិញ) ឱ្យចេញពីស្រុកខារ៉ានមក នោះទ្រង់បានប្រទានឱ្យគាត់នូវសេចក្តីសន្យាជាច្រើន និងចាប់តាំងពីយើង បាននៅក្នុងក្រុមគ្រួសាររបស់លោកអ័ប្រាហាំមក នោះយើងអាចដេកចាយនូវសេចក្តីសន្យាទាំងនេះផងដែរ ។

ព្រះគម្ពីរលោកិប្បត្តិ ១២:១-៣

យើងត្រូវបានមានសិទ្ធិទទួល ចំពោះព្រះពររបស់លោកអ័ប្រាហាំនោះដែរ! យើងអាចទាមទារនូវសេចក្តីសន្យាទាំងនេះ សម្រាប់ជាកម្មសិទ្ធិរបស់យើងផ្ទាល់ផងដែរ ។

### ខ. កូនចៅរបស់គាត់

ព្រះទ្រង់បានសន្យាជាមួយនឹងលោកអ័ប្រាហាំថា នឹងប្រទានពរឱ្យមានពូជដ៏ធំសម្បើម ។ ពូជរបស់គាត់គឺត្រូវតែមានជាច្រើនលើសលុប ដូចជាធូលីដីនៅលើផែនដីនេះ គឺសំដៅទៅលើពូជខាងសាច់ឈាមដែលនៅលើផែនដីនេះ ។

ព្រះគម្ពីរលោកុប្បត្តិ ១៣:១៦

ព្រះទ្រង់ក៏បានមានបន្ទូលទៅកាន់លោកអ័ប្រាហាំថា ពូជនេះនឹងបានជាចំនួនដូចជាផ្កាយនៅលើមេឃ គឺសំដៅទៅលើពូជខាងឯវិញ្ញាណរបស់គាត់ តាមរយៈសេចក្តីជំនឿនោះឯង ។

ព្រះគម្ពីរលោកុប្បត្តិ ១៥:៥

### គ. ការតាំងសញ្ញាដ៏អស់កល្ប

ព្រះទ្រង់បានធ្វើសម្រេចជាមួយនឹងលោកអ័ប្រាហាំ ព្រម ទាំងពូជរបស់គាត់ នូវការតាំងសញ្ញាដ៏អស់កល្បនេះ ។ តាម រយៈសេចក្តីជំនឿ នោះយើងគឺជាពូជរបស់គាត់ ហើយយើង ក៏បានជាចំណែក នៃសេចក្តីសញ្ញាដ៏អស់កល្បនេះដែរ ។

ព្រះគម្ពីរលោកុប្បត្តិ ១៧:៧

ព្រះគម្ពីរលោកុប្បត្តិ ២២:១៦-១៨

### ឃ. ព្រះយេស៊ូវជាពូជរបស់លោកអ័ប្រាហាំ

ប្រសិនបើយើងនៅក្នុងព្រះយេស៊ូវ នោះយើងគឺបានជា ទាយាទនៃសេចក្តីសន្យា ចំពោះព្រះពររបស់ព្រះដល់លោក អ័ប្រាហាំ ។ យើងគឺជាទាយាទចំពោះសេចក្តីសញ្ញារបស់លោក អ័ប្រាហាំហើយ ។

ព្រះគម្ពីរកាឡាទី ៣:១៦,២៩

## VI. ព្រះពររបស់យើងគឺនៅក្នុងលោកអ័ប្រាហាំ

យើងជាពូជរបស់លោកអ័ប្រាហាំ: គឺជាពូជខាងឯវិញ្ញាណ របស់គាត់ ហើយដោយសារសេចក្តីជំនឿនោះ យើងត្រូវតែ អាចទទួលបាននូវព្រះពររបស់គាត់ ។ ប្រសិនបើយើងត្រូវតែ បានទទួលនូវព្រះពរទាំងនេះ ដោយសេចក្តីជំនឿ នោះយើង ត្រូវតែដឹងពីអ្វីដែលពួកគេមាននោះដែរ ។

### ក. បញ្ជីឈ្មោះព្រះពរ

គឺមាននៅក្នុងព្រះគម្ពីរចោទិយកថា ២៨:១-១៤

### ខ. ការប្រទានពរមកដល់យើង

សេចក្តីសន្យាទាំងនេះ គឺត្រូវបានប្រទានពរមកលោក អ័ប្រាហាំជាដំបូង បន្ទាប់មក គឺដល់ពូជខាងសាច់ឈាមរបស់ គាត់ ហើយបន្ទាប់មកទៀត ព្រះពរទាំងនោះក៏បានធ្លាក់មក លើពូជខាងឯវិញ្ញាណរបស់គាត់: គឺជាអស់អ្នកដែលមានសេច ក្តីជំនឿនោះឯង ។

ព្រះគម្ពីរកាឡាទី៣:៦-៧,១៤

ព្រះគម្ពីររ៉ូម ៦:១៤

ព្រះគម្ពីរអេភេសូរ ២:៨

តើយើងត្រូវបានរំដោះចេញពីណាមក? គឺយើងបានទទួល នូវការប្រោសលោះចេញពីបណ្តាសាក្រឹត្យវិន័យមក ។ នៅក្នុង ព្រះគ្រីស្ទ នោះយើងបានទទួលមរតកពីព្រះពរទាំងអស់នៅ ក្នុងព្រះគម្ពីរចោទិយកថាជំពូកទី២៨ ដែលយើងទើបតែ នឹងបានអានមកនេះ ។ យើងបានទទួលការរំដោះចេញពី បណ្តាសា ហើយបានត្រឡប់មកជាកូនរបស់លោកអ័ប្រាហាំ តាមសេចក្តីជំនឿ ។ យើងបានកើតជាថ្មីនៅក្នុងព្រះគ្រីស្ទ យេស៊ូវហើយ ។

### គ. សម្រាប់សម័យសព្វថ្ងៃនេះ

ចូរកត់ចំណាំថា សេចក្តីសន្យាដែលបានប្រទានមកលោក អ័ប្រាហាំ គឺសម្រាប់ពេលវេលាឥឡូវនេះ មិនមែនសម្រាប់ដល់ ពេលដែលយើងត្រូវទៅស្ថានសួគ៌នោះទេ ។ សេចក្តីសន្យាទាំង នោះហើយ គឺសម្រាប់នៅសម័យសព្វថ្ងៃនេះ ។ ចូរយើងធ្វើ ការចំណាយពេលអរព្រះគុណដល់ព្រះអម្ចាស់ សម្រាប់ព្រះពរ ខ្លះៗ ដែលបានកើតឡើងថ្មីៗរបស់យើង ។

***ឱព្រះវរបិតាអើយ! ទូលបង្គំសូមអរព្រះគុណដល់ព្រះអង្គ***
***ដែលទូលបង្គំបានទទួលព្រះពរ នៅក្នុងទីក្រុងនេះ***
***និងបានទទួលព្រះពរនៅក្នុងស្រុកទេសផងដែរ ។***
***ទូលបង្គំនឹងបានទទួលព្រះពរ***
***នៅកន្លែងណាដែលទូលបង្គំបានរស់នៅ ។***

*ទូលបង្គំអរព្រះគុណដល់ព្រះអង្គ*
*ដែលបានបង្កើតផលពីផ្ទៃម្ដាយ គឺដែលបានទទួលនូវព្រះពរ*
*ទាំងកូនចៅរបស់ទូលបង្គំក៏បានទទួលនូវព្រះពរផងដែរ ។*
*ទូលបង្គំអរព្រះគុណព្រះអង្គ ឱព្រះអម្ចាស់អើយ!*
*គឺដែលទូលបង្គំបានទទួលព្រះពរ*
*មកពីសត្វពាហនៈរបស់ទូលបង្គំ តាមរយៈទ្រង់ ។*
*ទូលបង្គំអរព្រះគុណព្រះអង្គ ឱព្រះអម្ចាស់អើយ!*
*ដែលធុងរបស់ទូលបង្គបានពេញ*
*គឺដែលទូលបង្គំមានអាហារជារៀងរាល់ថ្ងៃ ។*
*ទូលបង្គំអរព្រះគុណព្រះអង្គ ឱព្រះអម្ចាស់អើយ!*
*ដែលព្រះពររបស់ ទ្រង់បានកាន់តែហូរមក*
*ទោះជាទូលបង្គំចេញទៅទីណា ។*
*ទូលបង្គំដឹងថានៅពេលដែលខ្មាំងសត្រូវព្យាយាមចូលមក*
*ទាស់ទទឹងនឹងទូលបង្គំ   នោះទ្រង់បានធ្វើឱ្យពួកវាត្រូវបរាជ័យ ។*
*វានឹងចូលមកទាស់ទទឹងជាមួយនឹងទូលបង្គំផ្ទាល់*
*តែទ្រង់នឹងបញ្ចៀសពីពួកវា៧ដងទៅទៀត ។*
*ឱព្រះអម្ចាស់អើយ! ទូលបង្គំអរព្រះគុណព្រះអង្គ*
*ដែលគ្រប់យ៉ាងទូលបង្គំធ្វើ នោះនឹងបានសម្រេច ។ នៅថ្ងៃនេះ*
*ទូលបង្គំនឹងដើរតាមផ្លូវរបស់ទ្រង់ ទាំងថ្ងៃស្អែក*
*និងជារៀងរាល់ថ្ងៃ នៅក្នុងជីវិតរបស់ទូលបង្គំ ។*
*ទូលបង្គំអរព្រះគុណព្រះអង្គ ឱព្រះអម្ចាស់អើយ!*
*ដែលមនុស្សនឹងបានមើលឃើញនូវរបៀបដ៏អស្ចារ្យ*
*ដែលទ្រង់គង់នៅក្នុងជីវិតរបស់ទូលបង្គំ ។*
*ទូលបង្គំអរព្រះគុណព្រះអង្គឱព្រះអម្ចាស់អើយ!*
*ដែលទ្រង់នឹងបានប្រទានព្រះពរនូវទ្រព្យសម្បត្តិ*
*ដ៏ច្រើនក្រៃលែងនេះ ។ ទូលបង្គំអរព្រះគុណព្រះអង្គ*
*ឱព្រះអម្ចាស់អើយ!*
*ដែលទ្រង់បានបើកឃ្លាំងដ៏សម្បូរសប្បាយនៃនគរស្ថានសួគ៌*
*ហើយដែលទូលបង្គំអាចបានទទួលទ្រព្យសម្បត្តិនោះ*
*នៅលើផែនដីនេះ ។ ទូលបង្គំអរព្រះគុណព្រះអង្គ*
*ឱព្រះអម្ចាស់អើយ! ដែលទ្រង់បានបង្កើតទូលបង្គំមក*
*ឱ្យធ្វើជាក្បាលមិនមែនធ្វើជាកន្ទុយឡើយ*
*គឺទ្រង់បានដាក់ទូលបង្គំឱ្យនៅលើកំពូល*
*មិនមែនឱ្យនៅផ្នែកខាងក្រោមឡើយ ។*
*ឱព្រះវរបិតាអើយ! ទូលបង្គំអរព្រះគុណព្រះអង្គសម្រាប់*
*ព្រះពរទាំងអស់របស់ទ្រង់! ទូលបង្គំនឹងមិនថយទៅខាងណា*
*ចេញពីការដើរតាមទ្រង់ឡើយ ព្រះអម្ចាស់អើយ ។*
*ទូលបង្គំនឹងមិនបម្រើព្រះដទៃណាទៀតឡើយ ។*
*ទូលបង្គំនឹងនៅតែ កាន់ខ្ជាប់តាមព្រះរាជបញ្ញត្តិរបស់ទ្រង់ ។*
*នៅក្នុងព្រះនាមព្រះយេស៊ូវ ។ អាម៉ែន ។*

## ក្រុមពិភាក្សា

១. ចូរធ្វើការពិភាក្សាពីអត្ថន័យ នៃប្រយោគជាបន្តបន្ទាប់ (នៅខាងចុងប្រយោគជាពិសេស)៖ "ព្រះវរបិតាទ្រង់បានជ្រើសរើសព្រះយេស៊ូវ ។ ទ្រង់គឺជាមួយអង្គ ដែលត្រូវបានទទួលការជ្រើសរើស ។ ពីព្រោះយើងគឺជាអ្នកនៅក្នុងព្រះអង្គ ដែលឥឡូវនេះ យើងបានចែកចាយនៅក្នុងការជ្រើស រើសរបស់ផងព្រះអង្គនោះឯង" ។

២. តើយើងអាចត្រូវបានដកយកនូវសិទ្ធិ ដែលមិនអាចប្តូរបានទាំងបួនយ៉ាង គឺជាសិទ្ធិដែលបានកើតជាថ្មីដោយសាតាំង ដែលគ្មានភាពហ្មត់ចត់បាន ដោយរបៀបណា?

៣. ចំពោះអារក្សដែលគ្មានការការពារប្រឆាំងទាស់ នឹងគ្រឿងសាស្ត្រាវុធនៃព្រះបន្ទូលរបស់ព្រះនោះទេ ។ តើយើង អាចប្រើប្រាស់នូវចំណេះដឹងនេះ ដើម្បីផ្លាស់ប្តូរនូវការរស់នៅរបស់យើង ដោយរបៀបណា?

## ការសិក្សាផ្ទាល់ខ្លួន

១. ព្រះគម្ពីរអេភេសូរ ២:១៣ បានប្រាប់យើងថា នៅពេលឥឡូវនេះ យើងអាចមានសេចក្តីអំណរជាបន្តទៀត គឺជាការប្រកបជិតស្និទ្ធ និងការទាក់ទងជាមួយនឹងព្រះយេស៊ូវ ។ តើលោកអ្នកកំពុងតែរស់នៅក្នុងភាពទំនាក់ទំនងជិតស្និទ្ធ ជាមួយនឹងព្រះអង្គបានឬទេ?

   ក. ប្រសិនបើលោកអ្នកស្ថិតនៅ ដោយការអធិស្ឋានអរព្រះគុណព្រះសម្រាប់សេចក្តីស្រឡាញ់ និងសម្រាប់ភាពស្មោះត្រង់របស់ព្រះអង្គ ។

   ខ. ប្រសិនបើលោកអ្នកមិនបានស្ថិតនៅ ក្នុងការអធិស្ឋានទូលសូមដល់ព្រះ ឱ្យលោកអ្នកបានចូលមកកាន់តែជិតព្រះទេនោះ ហើយបង្ហាញដល់លោកអ្នក ដូចជាប្រសិនបើមានឧបស័គ្រណាមួយ ដែលត្រូវការរើចេញ ឬបណ្តេញចេញនោះ ។

២. គ្រប់ទាំងអស់ដែលព្រះទ្រង់មាន គឺជារបស់យើងរួចទៅហើយ ។ យើងគ្រាន់តែត្រូវការរកឱ្យឃើញ នូវរបៀបនៃការទទួលវាតែប៉ុណ្ណោះ ។

   ក. តើអ្វីទៅជាកូនសោរពីរយ៉ាង ដែលលោកអ្នកត្រូវការទទួលនូវការប្រទានពររបស់ទ្រង់នោះ?

   ខ. តើលោកអ្នកអាចប្រើប្រាស់ នូវកូនសោរទាំងពីរយ៉ាងនេះ ដោយមានការខឹតខំប្រឹងប្រែង ទទួលព្រះពរនេះ ដោយរបៀបណា?

៣. តើលោកអ្នកបានទទួល "ពិធីជ្រមុជទឹក" ហើយឬនៅ? ប្រសិនបើលោកអ្នកបានទទួលហើយ ចូរដឹងថា លោកអ្នកត្រូវប្រកាសទាំងស្រុងថា លោកអ្នកពិតជានៅជាមួយព្រះយេស៊ូវមែន។ ប្រសិនបើលោកអ្នកមិនទាន់បានទទួលពិធីជ្រមុជទឹកទេ នោះកុំឱ្យមានការបាក់ទឹកចិត្តឡើយ ។ ចូរទៅកាន់លោកគ្រូគង្វាល ឬអ្នកដឹកនាំរបស់លោកអ្នក ហើយជម្រាបប្រាប់គាត់/នាងថា លោកអ្នកពេញចិត្តនឹងទទួលពិធីជ្រមុជទឹកជាពិសេស គឺចាប់តាំងពីការរួបរួមដ៏ស្និទ្ធស្នាលរវាងលោកអ្នក ជាមួយនឹងព្រះយេស៊ូវនោះឯង ។

# រូបភាពនៃការកើតជាថ្មី

## *មេរៀនទី ៦: ប្រយោជន៍នៃការកើតជាថ្មី*

ការបើកសម្តែងពីការកើតជាថ្មី និងពីសេចក្តីសុចរិតរបស់យើងនៅក្នុងព្រះយេស៊ូវ គឺនាំមកនូវប្រយោជន៍ជាច្រើនដល់អ្នកជឿលើព្រះយេស៊ូវគ្រីស្ទ ។

ព្រះគម្ពីរទំនុកដំកើង ៦៨:១៩ក

### I. ការប្រកបទាក់ទងជាមួយនឹងព្រះ

ផលប្រយោជន៍បណ្តាផលប្រយោជន៍ដ៏ធំបំផុត នៃការកើតជាថ្មី គឺដែលយើងអាចដើរដោយជឿជាក់ និងយល់ដឹងជាមួយនឹងព្រះនៅក្នុងពន្លឺនៃព្រះវត្តមាន ដ៏មានសិរីល្អរបស់ផងទ្រង់នោះឯង ។ យើងអាចជជែកជាមួយនឹងទ្រង់បាន ។ យើងអាចមានការប្រកបជិតស្និទ្ធ និងមានការប្រកបស្និទ្ធស្នាលជាមួយនឹងទ្រង់បាន ។ ព្រះគម្ពីរលោកុប្បត្តិបានថែងប្រាប់យើងថា ព្រះទ្រង់បានដើរជាមួយនឹងលោកអ័ដាម និងនាងអេវ៉ានៅក្នុងថ្ងៃល្ងើយ ។

ព្រះគម្ពីរ ១យ៉ូហាន ១:៣-៧

ភាពជាគ្រីស្ទបរិស័ទគឺផ្សេងពីសាសនាដទៃទៀត ក្នុងពេលដែលយើងបានទទួលជឿព្រះគ្រីស្ទហើយ គឺយើងអាចមានការប្រកបទាក់ទងជាលក្ខណៈបុគ្គល (គឺបានជាផ្នែកមួយនៃក្រុមគ្រួសារដ៏អស់កល្បរបស់ព្រះ) ហើយនិងមានការប្រកប (ការទាក់ទងគ្នាជាប្រចាំថ្ងៃ) ជាមួយនឹងព្រះ ។ គោលបំណងរបស់ព្រះក្នុងការប្រោសលោះ គឺត្រូវតែកែភាពទំនាក់ទំនងរបស់ទ្រង់ជាមួយមនុស្សជាតិ និងកែនូវការប្រកបទាក់ទងរបស់យើងជាមួយនឹងព្រះអង្គសារជាថ្មីឡើងវិញ ។

#### ក. និយមន័យ

តាមរយៈវចនានុក្រមដ៏ពិស្តាររបស់លោកវិបស្ទើរ គឺមាននិយមន័យខ្លះៗចំពោះការប្រកបដូចខាងក្រោមនេះ:

១. ល័ក្ខខ័ណ្ឌដែលត្រូវធ្វើជាសមាគម
២. សមាគម ដែលមានការទាក់ទងពីម្នាក់ទៅម្នាក់ ដោយមានភាពស្មើគ្នា និងជាទម្រង់មិត្តភាព ។
៣. ការទំនាក់ទំនង
៤. ភាពជាមិត្តសំឡាញ់
៥. ភាពជាក្រុមគ្រួសារដ៏ស្និទ្ធស្នាល
៦. ការចែកចាយពីម្នាក់ទៅម្នាក់

#### ខ. ការត្រាស់ហៅ

យើងរាល់គ្នាបានទទួលការត្រាស់ហៅ ឱ្យមានការប្រកបជាមួយនឹងព្រះ ។

ព្រះគម្ពីរ ១កូរិនថូស ១:៩

គឺជាគំនិតអ្វីមួយដែលគួរឱ្យភ័យខ្លាច ។ ព្រះទ្រង់បានត្រាស់ហៅយើងរាល់គ្នាមក ឱ្យចូលទៅក្នុងការប្រកបជាមួយនឹងព្រះអង្គទ្រង់នោះឯង ។ ព្រះទ្រង់សព្វព្រះហឫទ័យចង់ប្រកបទាក់ទងជាមួយយើង! ការប្រកបទាក់ទងដ៏ស្និទ្ធស្នាលរបស់យើងជាមួយព្រះនោះហើយ ដែលអាចដឹកនាំឱ្យមានកម្រិតនៃការប្រកបដូចៗគ្នា ជាមួយនឹងបងប្អូនប្រុសស្រីរបស់យើងនៅក្នុងក្រុមគ្រួសាររបស់ព្រះ ។

ព្រះគម្ពីរ ១យ៉ូហាន ១:៣-៤

#### គ. ការនាំមកនូវសេចក្តីអំណរ

សេចក្តីអំណរគឺជាលទ្ធផលនៃការប្រកបស្និទ្ធស្នាល ដែលមិនចេះប្រែប្រួលជាមួយនឹងព្រះ ហើយជាមួយអ្នកជឿលើ

ព្រះយេស៊ូវគ្រីស្ទនោះឯង ។

ព្រះគម្ពីរទំនុកដំកើង ១៦:១១

គ្មានសេចក្តីអំណរណាធំជាងសេចក្តីអំណរ ដែលមានការពិសោធន៏ក្នុងការប្រកបស្និទ្ធស្នាលជាមួយនឹងព្រះអង្គទ្រង់តាមព្រះបន្ទូលរបស់ទ្រង់នោះឡើយ ។

ព្រះគម្ពីរយេរេមា ១៥:១៦

អ្នកជឿដែលបានរកឃើញនូវការបើកសម្តែង នូវការបានកើតជាថ្មីនៅក្នុងព្រះយេស៊ូវ
គឺជាការបានទទួលនូវសេចក្តីអំណរនោះឯង ។

ម្យ៉ាងទៀត អស់អ្នកដែលត្រូវបានទទួលនូវការសង្កត់សង្កិន ដោយគំនិតជាប់មានទោស ជាប់មានការផ្តន្ទាទោស និងជាប់ការគ្មានតម្លៃ នោះពួកគេដែលត្រូវបានបើកសម្តែងពីការជាប់ចំណង ឱ្យទៅជាមានសេចក្តីអំណរ និងសេចក្តីសប្បាយរីករាយដ៏លើសលុប ។ គឺសម្រាប់តែអស់អ្នកដែលមានការពិសោធន៏នូវការបើកសម្តែង ពីការកើតជាថ្មីនោះឯងដែលអាចមានការពិសោធន៏ នូវសេចក្តីអំណរដ៏លើសលុបពីការប្រកបយ៉ាងស្និទ្ធស្នាលជាមួយព្រះ ដោយគ្មានការភ័យខ្លាចចំពោះការផ្តន្ទាទោសនោះឡើយ ។

ស្តេចដាវីឌបានសរសេរចែងទុកមកអំពីសេចក្តីអំណរនេះនៅក្នុងព្រះគម្ពីរទំនុកដំកើង ៣២:១-២ ។

## ឃ. ការប្រកបដែលមានចិត្តខ្មេចខ្ទាំ

១. **ការមានបណ្តាសា គឺដោយសារការមិនស្តាប់បង្គាប់ និង ឬមកពីការធ្វើបាប ។** ប្រសិនបើយើងធ្វើបាប នោះការប្រកបទាក់ទងរបស់យើងជាមួយព្រះ នោះមិនមានការខ្មេចខ្ទាំឡើយ ។ យើងនៅតែជាកូនរបស់ព្រះអង្គដដែល ។

តាមរយៈការធ្វើបាប នោះការប្រកបទាក់ទងរបស់យើងជាមួយនឹងទ្រង់ ត្រូវបាក់បែកហើយ ។ ម្យ៉ាងវិញទៀត អំពើបាបបានត្រឡប់មកជាគ្រឿងរារាំងរវាងយើង និងព្រះហើយ ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងសេចក្តីមេត្តាករុណាដ៏ធំឧត្តមរបស់ផងទ្រង់ ដែលព្រះទ្រង់បានបង្កើតព្រះពរសម្រាប់ការប្រកបរបស់យើងជាមួយនឹងទ្រង់ នឹងត្រូវបានកែប្រែជាថ្មីដោយភ្លាមៗហើយ ។

## ២. ការកែជាថ្មីឡើងវិញ

ព្រះគម្ពីរ ១យ៉ូហាន ១:៨-១០

"ការសារភាពបាប" មានន័យថា ប្រាប់ពីឈ្មោះអំពើបាបនោះ ។ យើងត្រូវតែប្រាប់ពីឈ្មោះអំពើបាបរបស់យើង ហើយមិនត្រូវទទួលវាមកទៀតទេ ហើយក៏មិនត្រូវមានការលាក់លាបវាទៀត គឺត្រូវបដិសេធយើងបានធ្វើបាបហើយ ។ ជំនួសឱ្យនូវការនេះ យើងត្រូវតែប្រញាប់ប្រញាល់ធ្វើការចុះចូលចំពោះ នូវអ្វីដែលយើងបានធ្វើកន្លងផុតមកហើយ នោះគឺសុទ្ធតែជាអំពើបាបនៅក្នុងព្រះនេត្ររបស់ទ្រង់ និងនៅក្នុងភ្នែករបស់យើងផ្ទាល់ផងដែរ ។

ពាក្យថា "អំពើបាប" មានន័យថា "ការបាត់បង់នូវសញ្ញាណាមួយ" ដែលយើងត្រូវតែលន់តួនូវអំពើបាបរបស់យើងក្នុងពេលភ្លាមៗនោះ ហើយទទួលនូវការអត់ទោស និងការលាងសម្អាតរបស់ព្រះមកពីអំពើទុច្ចរិតនោះឯង ។

## ៣. ការឆបោកនូវព្រះគុណរបស់ព្រះ

មានមនុស្សជាច្រើន ដែលមិនមានការប្រកប

ទាក់ទងនូវសេចក្ដីសុចរិត គឺបែរជាមានការឆបោកដល់ព្រះទៅវិញ ។ ពួកគេមានគំនិតបាត់បង់ដែលការនេះធ្វើ ឱ្យមានន័យថា ពួកគេអាចមានឆន្ទៈធ្វើនូវអំពើបាបជាយូរមកហើយ ដែលពួកគេត្រូវតែលន់តួនូវអំពើបាបនោះ ក្រោយមកគេនឹងបានទទួលនូវការអត់ទោសមកពីព្រះ ។

លោកសាវ័កយ៉ូហាន បានប្រកាស់ពីការនោះថា គាត់បានបន្ដមកដល់ខជាបន្តបន្ទាប់មកទៀត ដែលយើងមិនត្រូវអនុញ្ញាតឱ្យឆន្ទៈរបស់យើង មានបង្កប់ទុកនូវអំពើបាបនោះ ចូលមកក្នុងជីវិតរបស់យើងបានទៀតឡើយ ។

ព្រះគម្ពីរ ១យ៉ូហាន ២:១

ការត្រាស់ហៅរបស់យើងឱ្យមកឯព្រះ គឺជាការត្រាស់ហៅចេញពីអំពើបាប ឱ្យបានចូលមកប្រកបជិតស្និទ្ធជាមួយនឹងព្រះអង្គវិញនោះឯង ។

## II. ភាពចុំថ្កើងរុងរឿង

ចំពោះផលប្រយោជន៍ដទៃទៀត នៃអ្នកជឿដែលបានកើតជាថ្មីនោះគឺ:

ជាការកើតជាថ្មីដែលធ្វើឱ្យយើងមានភាពចុំថ្កើងរុងរឿងដ៏ពិតប្រាកដ ។ មានការចុំថ្កើងរុងរឿងចំនួនពីរប្រភេទៈ ខាងព្រលឹង គឺនៅក្នុងតំបន់ថវិកា ។ តាមរយៈលោកសាវ័កយ៉ូហាន ដែលព្រះទ្រង់បានសរសេរចែងទុកមកថា ទ្រង់បានសព្វព្រះហឫទ័យចង់ឱ្យយើងមានភាពចុំថ្កើង និងមានសុខភាពល្អសូម្បីតែខាងព្រលឹងរបស់យើងក៏មានភាពចុំថ្កើងផងដែរ ។

ព្រះគម្ពីរ ៣យ៉ូហាន ខ.២

តើព្រះទ្រង់សព្វព្រះហឫទ័យអ្វីខ្លះ ចំពោះការនៅខាងលើទាំងអស់នេះដទៃទៀតដែរឬទេ? ដែលយើងនឹងបានចុំថ្កើង និងមានសុខភាពល្អ នោះសូម្បីតែព្រលឹងយើងក៏បានចុំថ្កើងដែរ

### ក.ភាពចុំថ្កើងរុងរឿងខាងឯព្រលឹង

តើ "ជាភាពចុំថ្កើងរុងរឿងខាងឯព្រលឹងរបស់លោកអ្នកមានន័យ" យ៉ាងដូចម្ដេច? ស្ដេចដាវីឌបានចែងទុកនៅក្នុងព្រះគម្ពីរទំនុកដំកើង ២៣:៣ ។

ព្រលឹងរបស់យើងគឺជាវេទយិតរបស់យើង ជាអារម្មណ៍របស់យើង និងជាឆន្ទៈរបស់យើង ។ រីឯភាពរុងរឿងខាងឯព្រលឹង គឺជាភាពរុងរឿងខាងឯវេទយិត និងភាពរុងរឿងខាងឯអារម្មណ៍ គឺបានចូលមកតាមរយៈការប្ដេជ្ញាទាំងស្រុងនៃការរស់នៅជាយញ្ញបូជារស់ថ្វាយព្រះយេស៊ូវ ហើយការរំឭកសារជាថ្មីនៃគំនិតរបស់យើង ក៏តាមរយៈព្រះបន្ទូលព្រះដែរ ។ រីឯភាពរុងរឿងខាងឯព្រលឹងគឺជាតម្រូវការជាមុន សព្រមាប់ភាពរុងរឿង និងសុខភាពខាងឯរូបកាយ ។ ព្រះទ្រង់សព្វព្រះហឫទ័យចង់កែយើងជាថ្មី និងប្រោសយើងឱ្យជាពីគ្រប់ទាំងរបួសខាងឯអារម្មណ៍ និងការឈឺចាប់នៅក្នុងជីវិតរបស់យើង។

ព្រះគម្ពីររ៉ូម ១២:១-២

ព្រះទ្រង់សព្វព្រះហឫទ័យចង់ឱ្យបណ្ដាជនរបស់ព្រះអង្គបានកើតជាថ្មី ឱ្យមានរុងរឿងនៅក្នុងព្រលឹង និងនៅក្នុងរូបកាយ គឺជាការកើតជាថ្មី ដែលមិនមានការសម្របទៅតាមប្រព័ន្ធនៃលោកិយនេះតទៅទៀតឡើយ ។ ពួកគេត្រូវតែសម្របទៅតាមព្រះបន្ទូលរបស់ព្រះវិញ ។

#### ១. អំពីរបៀបរបប

ការកើតជាថ្មី គឺជាការដែលនៅក្នុងរបៀបរបប នៃការប្រែជាថ្មី ហើយការកែប្រែជាថ្មីនេះ បានចូល

មកក្នុងគំនិត គឺជាការរំឮកដោយនូវការអាន ការស្តាប់ ការពិចារណា ការជឿ និងការធ្វើសកម្មភាពតាមព្រះបន្ទូលរបស់ព្រះជាបន្តបន្ទាប់ ។

ជំហានដ៏សំខាន់ទីមួយ ចំពោះការពេញដោយសុខភាព និងភាពរុងរឿង គឺត្រូវតែចូលមកក្នុងការបើកសម្តែងនូវការកើតជាថ្មី ។ ការបើកសម្តែងនេះនឹងធ្វើឱ្យអ្នកជឿមានសេរីភាពពីគំនិតថោកទាប ពីការមានទោស ពីការផ្តន្ទាទោស និងពីភាពគ្មានតម្លៃ ដើម្បីឱ្យគាត់ ឬនាង មានលទ្ធភាពនឹងទទួលនូវគ្រប់ទាំងផលប្រយោជន៍នៃការកើតជាថ្មី ព្រមទាំងនៅក្នុងភាពចម្រុងចម្រើន និងមានសុខភាពពេញលេញ។ របៀបរបបនេះ គឺដោះយើងឱ្យបានរួចពីភាពអសន្តិសុខ និងពីភាពថោកទាបនោះ ។

## ២. ការពិពណ៌នា

"ភាពចម្រុងចម្រើន" ដ៏ពិតដែលពួកកូនរបស់ព្រះ ត្រូវបានពណ៌នានៅក្នុងព្រះគម្ពីរទំនុកដំកើងនោះឯង ។ ព្រះគម្ពីរទំនុកដំកើង ១:៣ ។

មនុស្សដែលមានភាពចម្រុងចម្រើនដ៏ពិត គឺជាម្នាក់ដែល:

ក. ដើរដោយសេចក្តីជំនឿ និងស្តាប់បង្គាប់តាមការបើកសម្តែងមកពីព្រះបន្ទូលរបស់ព្រះ ។

ខ. ដើរដោយសេចក្តីស្រឡាញ់ និងមានការពិសោធន៍ ដ៏មានជម្រៅជ្រៅ ព្រមទាំងមានការប្រកបស្និទ្ធស្នាលជាមួយនឹងព្រះ និងមានការប្រកបជាមួយនឹងអ្នកជឿដទៃទៀត ។

គ. ជាការដើរដោយសុខសន្តិភាព និងការសប្បាយចិត្តរបស់ព្រះ នៅគ្រប់ទាំងអស់ដែលគេមាន ។

ឃ. ជាការនៅតែបន្តការបំពេញការងារ នៅក្នុងព្រះអម្ចាស់ និងសេចក្តីត្រូវការរបស់អ្នកដទៃទៀត ។

ង. មានសេចក្តីត្រូវការរបស់ខាងផ្នែកថវិការបស់គេ ហើយដែលបានទទួលនូវការផ្គត់ផ្គង់ដើម្បីឱ្យគេបាន "មានគ្រឿងបរិក្ខាល្អៗសម្រាប់រាល់ការងារល្អៗ" ។

ច. ជាលទ្ធភាពក្នុងការថ្វាយជាទូទៅដល់ព្រះអម្ចាស់ ព្រមទាំងដល់សេចក្តីត្រូវការ សម្រាប់អ្នកដទៃទៀត ។

## ខ. ភាពរុងរឿងខាងផ្នែកថវិកា

### ១. ការថ្លឹងថ្លែងនូវភាពរុងរឿង

ការផ្ទុយទៅនឹងអ្វី ដែលយើងអាចបានទទួលយកនូវការបង្រៀនថា លុយ គឺមិនមែនជាសេចក្តីអាក្រក់ទេ ។ គឺជាការស្រឡាញ់លុយទេ ដែលជាឫសគល់នៃសេចក្តីអាក្រក់នោះ ។ លុយគឺជាការសំខាន់សម្រាប់សេចក្តីត្រូវការ នៅក្នុងការសម្រេចតាមមហាព្រះរាជបញ្ជានោះ ។ យើងត្រូវតែដឹងពីរបៀបទទួលនូវភាពរុងរឿងខាងផ្នែកថវិការបស់ព្រះ ដើម្បីឱ្យយើងអាចធ្វើការឈោងចាប់ដល់ពួកអ្នកបាត់បង់ ពីលោកិយនេះ ដោយនូវដំណឹងល្អពីព្រះយេស៊ូវគ្រីស្ទ ។

លោកសាវ័កយ៉ូហានបានធ្វើការទូន្មាន ដល់ពួកយើងថា យើងត្រូវតែប្រុងប្រយ័ត្ន គឺដែលយើងមិនត្រូវជ្រើសរើស នូវការខឹតខំប្រឹងប្រែងទៅលើរបស់

ដែលនៅលើ លោកិយនេះនោះឡើយ ។ យើងត្រូវតែបន្តនូវការចាំយាម ប្រឆាំងទាស់នឹងការបោកបញ្ឆោតនៃទ្រព្យសម្បត្តិ ឬក៏មានសេចក្ដីអំនួតនៃជីវិត ដែលដឹកនាំនូវសេចក្ដីប៉ងប្រាថ្នាខាងឯសម្ភារៈ ឬក៏ជាកិត្តិយស របមនុស្សនោះឡើយ ។

ព្រះគម្ពីរម៉ាថាយ ៦:៣៣

មនុស្សដែលបានកើតជាថ្មី គឺដែលមានការបើកសម្ដែង ខាងឯសេចក្ដីសុចរិត នោះនឹងតែងតែបានដាក់ចុះនូវការចំណាយពីនគររបស់ព្រះ និងពីសេចក្ដីសុចរិតនៃព្រះនៅខាងលើ ដែលជាសេចក្ដីត្រូវការផ្ទាល់របស់គាត់នោះហើយ ។ គាត់នឹងស្វែងរកព្រះ និងសេចក្ដីសុចរិតរបស់ទ្រង់ នោះព្រះទ្រង់នឹងសព្វហឫទ័យប្រទាន "គ្រប់របស់ទាំងអស់" ដល់គាត់ហើយ ។

## ២. ការថ្វាយទៅព្រះ

ព្រះទ្រង់មិនបានស្វែងរកឃ្លាំង ដាក់របស់បម្រុងនៅកន្លែងដែលសម្រាប់ចាក់ព្រះពរ ខាងផ្នែកថវិការបស់ទ្រង់នោះទេ ។ ជំនួសឱ្យនូវការនេះ ទ្រង់កំពុងតែស្វែងរកទន្លេ គឺជាអស់អ្នកណាដែលនឹងត្រូវបានប្រទានពរ ឱ្យចូលទៅក្នុងនគររបស់ព្រះអង្គ ។

ព្រះយេស៊ូវទ្រង់មានបន្ទូលថា ពេលដែលយើងថ្វាយ ដោយមានសេចក្ដីជំនឿ និងមានការស្ដាប់បង្គាប់ដល់ព្រះ នោះទ្រង់នឹងបន្ថែមឱ្យទៀតកាន់តែច្រើនឡើង ដូច្នេះ យើងត្រូវកាន់ខ្ជាប់នូវការថ្វាយទៅព្រះអង្គវិញនេះជានិច្ច ។

ភាពរុងរឿង គឺជាប្រយោជន៍នៃសេចក្ដីត្រូវការមួយនៃការបានកើតជាថ្មីនេះ ។ ព្រះទ្រង់បានតាំងសញ្ញាថា នឹងប្រទានពរខាងផ្នែកថវិកានេះ ដល់ប្រជារាស្ត្ររបស់ទ្រង់ ដែលជាអ្នកស្ដាប់បង្គាប់ដល់ព្រះអង្គនោះឯង ។

ព្រះគម្ពីរលូកា ៦:៣៨

## III. សុខភាពនិងការប្រោសឱ្យជា

ផលប្រយោជន៍ដ៏អស្ចារ្យផ្សេងទៀតនៃការកើតជាថ្មី គឺជាការប្រទានពររបស់ព្រះ សម្រាប់ការប្រោសឱ្យជាដល់រូបកាយរបស់គាត់ ឬរបស់នាងនោះឯង ។ រីឯការបើកសម្ដែងពីសេចក្ដីសុចរិតរបស់កំណើតថ្មី នឹងដោះឱ្យមានសេរីភាព ដល់អស់អ្នកដែលបានចងដោយអារម្មណ៍ នៃភាពដែលមានទោស នៃការផ្ដន្ទាទោស និងភាពគ្មានតម្លៃ ដើម្បីឱ្យពួកគេមានលទ្ធភាពនឹងទទួលយ៉ាងអង់អាច ក្នុងការប្រោសឱ្យជារបស់ពួកគេ ដែលមកពីព្រះ ។

នៅក្នុងការងារប្រោសលោះសារជាថ្មីឡើងវិញ របស់ព្រះយេស៊ូវ ទៅលើផលប្រយោជន៍របស់យើង នោះទ្រង់បានប្រទានសម្រាប់សេចក្ដីសង្គ្រោះរបស់យើង សម្រាប់គ្រប់អស់ទាំងកល្ប ហើយទ្រង់ក៏បានប្រទានពរនូវការប្រោសឱ្យជា ដល់រូបកាយរបស់យើងផងដែរ ។

### ក.ការប្រោសឱ្យជាដោយសារស្នាំជាំរបស់ទ្រង់

នៅក្នុងព្រះគម្ពីរហោរាអេសាយ ដែលបានបញ្ជាក់ពីការយាងមកវិញរបស់ព្រះមែស៊ី នោះគាត់បាននិយាយយ៉ាងច្បាស់ពីការប្រោសឱ្យជាដល់យើង ។ ព្រះគម្ពីរអេសាយ ៥៣:៥ ។

លោកសាវ៏កពេត្រុសក៏បានបញ្ជាក់ថា ការថ្លែងព្រះបន្ទូលរបស់លោកអេសាយ គឺនៅពេលដែលគាត់បានសរសេរអំពីការងារប្រោសលោះរបស់ព្រះយេស៊ូវ ដោយការប្រើពាក្យដូចគ្នា ។

ព្រះគម្ពីរ ១ពេត្រុស ២:២៤

## ខ.យេហូវ៉ារ៉ាហ្វា

គ្រាន់តែពួកកូនចៅអ៊ីស្រាអែល បានធ្វើដំណើរចាកចេញពីស្រុកអេស៊ីព្ទមក ព្រះទ្រង់បានបើកសម្តែងអង្គទ្រង់ ជាព្រះយេហូវ៉ារ៉ាហ្វា គឺជាព្រះដ៏ប្រោសឱ្យជាដល់ពួកគេនោះឯង ។

ព្រះគម្ពីរនិក្ខមនំ ១៥:២៦

ព្រះទ្រង់មិនចេះផ្លាស់ប្រែឡើយ ការប្រោសឱ្យជាគឺមានរហូតមកដល់សព្វថ្ងៃនេះ! តើអ្វីទៅដែលជាព្រះពរនោះ!

## គ.ព្រះបន្ទូលរបស់ព្រះនាំមកនូវការប្រោសឱ្យជា

ស្តេចសាឡូម៉ូនបានប្រាប់យើងថា ជីវិតនិងការប្រោសឱ្យជាដល់រូបកាយមនុស្ស គឺមកតាមរយៈព្រះបន្ទូលរបស់ព្រះ ។

ព្រះគម្ពីរសុភាសិត ៤:២០-២២

ប្រសិនបើយើងថ្វាយការប្រុងប្រយ័ត្ន ទៅលើព្រះបន្ទូលរបស់ព្រះ ហើយពិចារណាទៅលើអ្វីដែលទ្រង់មានបន្ទូលអំពីការរស់នៅដោយមានសុខភាព នោះវានឹងត្រឡប់មកជាការពិតនៅក្នុងជីវិតរបស់យើងជាមិនខាន ។ ពេលដែលគំនិតរបស់យើងបានទទួលនូវការកើតជាថ្មី នោះរូបកាយរបស់យើងក៏នឹងបានយ៉ាងដូច្នោះដែរ ។

ពេលដែលការបើកសម្តែងនេះ បានរើចេញពីវិញ្ញាណរបស់យើង ចូលទៅក្នុងព្រលឹងរបស់យើង នោះយើងនឹងនិយាយយ៉ាងអង់អាចពីព្រះបន្ទូលព្រះ ដោយសេចក្តីជំនឿ និងការប្រោសឱ្យជា នោះការប្រោសឱ្យជានឹងត្រូវចូលមកដោយពិតប្រាកដ ។

កំណត់ចំណាំៈ បើយើងបានសិក្សាឱ្យកាន់តែជ្រៅទៅទៀត ពីការប្រោសឱ្យជា ចូរអានពីសៀវភៅមេរៀនអំពី **ការប្រទានអំណាចរបស់ព្រះ ក្នុងការប្រោសឱ្យជា** ដោយលោក **អេ.អែល** និង **ចយហ្គីល** ។

## IV. អំណាចចេស្តារបស់ព្រះ

ប្រយោជន៍នៃកាកើតជាថ្មីដ៏អស្ចារ្យដទៃៗទៀត គឺជាសមត្ថភាព ក្នុងការបញ្ចេញនូវអំណាចចេស្តារបស់ព្រះវិញ្ញាណបរិសុទ្ធ ដែលចេញពីក្នុងយើងមក ។

ព្រះគម្ពីរអេភេសូរ ៣:២០

## ក.ការបើកសម្តែងពីសេចក្តីសុចរិត

ពួកអ្នកជឿដែលបានទទួលនូវការបើកសម្តែង ពីការកើតជាថ្មី នោះនឹងមើលឃើញដោយខ្លួនគេជាសុចរិតនោះឯង ។ ពួកគេនឹងមើលឃើញដោយខ្លួនគេថា ពួកគេបានកើតជាថ្មី ឱ្យមាននៅនោះឯង ។ ពួកគេនឹងមើលឃើញដោយខ្លួនឯងនូវទង្វើ ដែលជាការងាររបស់ព្រះយេស៊ូវ ។ ពួកគេនឹងមើលឃើញដោយខ្លួននូវសេចក្តីសុចរិត ដែលមានការប្រកបជាមួយនឹងព្រះ ព្រមទាំងបានប្រើប្រាស់ដោយព្រះអង្គទ្រង់ក្នុងការបំពេញការងារដល់អ្នកដទៃទៀត ។

ពួកគេនឹងមើលឃើញដោយខ្លួនឯង គឺជាការអនុវត្តន៍ដោយការចាក់ប្រេងតាំងរបស់ព្រះ គឺជាការបើកសម្តែងតាមរយៈជីវិត និងការបំពេញការងាររបស់ពួកគេ ។

ព្រះគម្ពីរយ៉ូហាន ៧:៣៨

**ខ.អំណាចចេស្តាក្នុងធ្វើទីបន្ទាល់**

ព្រះយេស៊ូវទ្រង់មានបន្ទូលថា គោលបំណងនៃអំណាចចេស្តា ដែលបានមកនៅពេលដែលយើងបានទទួលជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ គឺត្រូវតែធ្វើឱ្យយើងមានការខឹតខំធ្វើទីបន្ទាល់ថ្វាយព្រះយេស៊ូវគ្រីស្ទ ។

ព្រះគម្ពីរកិច្ចការ ១:៨

**១. ទីសម្គាល់ និងការអស្ចារ្យ**

ផែនការរបស់ព្រះ សម្រាប់ឈោងចាប់អស់អ្នកដែលបាត់បង់ នោះគឺជាការផ្សាយដំណឹងល្អ ប្រកបដោយការអស្ចារ្យនោះឯង ។ ទីសម្គាល់ ការអស្ចារ្យ និងការធ្វើការអស្ចារ្យ គឺនឹងតែងតែបញ្ជាក់ពីព្រះបន្ទូលរបស់ព្រះចំពោះដំណឹងល្អ ដែលត្រូវបានចែកចាយ និងត្រូវបានផ្សាយដំណឹងល្អនោះឯង ។

ព្រះបន្ទូលចុងក្រោយរបស់ព្រះយេស៊ូវ ដល់ពួកសិស្សរបស់ទ្រង់ គឺមិនពេលដែលទ្រង់បានយាងចេញពីផែនដីនេះ គឺមាននៅក្នុងព្រះគម្ពីរ ម៉ាកុស ១៦:១៥-២០។

តាមរយៈការបើកសម្តែងពីការកើតជាថ្មី អ្នកជឿគ្រប់រូប នឹងមានលទ្ធភាពក្នុងការធ្វើជាទីបន្ទាល់យ៉ាងអង់អាច ថ្វាយព្រះយេស៊ូវគ្រីស្ទ ដោយនូវអំណាចចេស្តានៃព្រះ វិញ្ញាណបរិសុទ្ធ ។

**២. ការមានិរីភាពរួចពីការភ័យខ្លាច**

ពួកគេនឹងមិនត្រូវបានទទួល នូវការលាក់លាមដោយការភ័យខ្លាចដល់មនុស្សតទៅទៀតឡើយ ។ គឺពួកគេនឹងអាចនិយាយដោយក្លាហានថា: ព្រះគម្ពីរ ២ធីម៉ូថេ ១:៧-៨ក

ពួកអ្នកជឿ ដែលមានការបើកសម្តែងពីការកើតជាថ្មី នោះនឹងគ្មានការភ័យខ្លាច និងគ្មានសេចក្តីខ្មាសក្នុងការធ្វើជាទីបន្ទាល់ពីព្រះយេស៊ូវឡើយ ។

ពួកគេក៏នឹងអាចនិយាយដោយអង់អាច នៅក្នុងព្រះគម្ពីរ ភិលីព ៤:១៣ ផងដែរ ។

**៣. អំណាចចេស្តាដែលគ្មានការលាក់លាម**

អ្នកជឿដែលមានការបើកសម្តែងពីការកើតជាថ្មីនឹងបើកឱ្យអំណាចចេស្តា ដែលគ្មានការលាក់លាមរបស់ព្រះ ដោយបញ្ជាក់ពីទីសម្គាល់ ការអស្ចារ្យ និងការធ្វើការអស្ចារ្យនៃការប្រោសឱ្យជា ។

ភាពមានទោស និងការផ្តន្ទាទោសនឹងមិនធ្វើឱ្យគេត្រូវថយចេញពីការបណ្តេញវិញ្ញាណអាក្រក់ ដ៏អង់អាច ឬក៏បណ្តេញចេញពីការអធិស្ឋានដាក់ដៃលើអ្នកជម្ងឺ និងបញ្ចេញនូវអំណាចចេស្តារបស់ព្រះ ដែលបង្ហូរចូលក្នុងរូបកាយរបស់ពួកគេនោះបានឡើយ ។

មនុស្សដែលមានការបើកសម្តែង ពីការកើតជាថ្មី នឹងមានការពិសោធន៍នូវផលប្រយោជន៍ ដែលបានមកពីព្រះជាបន្តបន្ទាប់ដូចជា: សេចក្តីអំណរ ការប្រោសឱ្យជា និងសុខភាព ភាពចម្រុងចម្រើន និងអំណាចចេស្តារបស់ព្រះ ដែលមិនមានការលាក់លាមជាដើម ។ ផលប្រយោជន៍ទាំងនេះ គឺមិនមែនបានទទួលសេចក្តីតែត្រឹមអ្នកជឿប៉ុណ្ណោះទេ ។ ពួកគេនឹងបង្ហូរទៅដល់អស់អ្នកដែលបានបាត់បង់ និងមានការសោះកក្រោះ នៅលោកិយនេះទៀតផង ។

**V. ធម្មជាតិរបស់ព្រះ**

នៅពេលដែលយើងបានទទួលព្រះយេស៊ូវ ធ្វើជាព្រះអង្គ

សង្គ្រោះផ្ទាល់របស់យើង នោះយើងបានត្រឡប់មកជាបានកើតជាថ្មីហើយ ។ យើងបានទទួលជាមែនមែនកផាងនៃធម្មជាតិថ្មីហើយ ។ វាគឺជាធម្មជាតិរបស់ព្រះអង្គទ្រង់នោះឯង ។ ឱគួរឱ្យរំភើបញាប់ញ័រយ៉ាងណាទៅហ្ន៎ ដែលយើងបានទៅជាចំណែកដ៏ពិតប្រាកដជាទេវភាព នៃធម្មជាតិរបស់ព្រះនោះ ។

ព្រះគម្ពីរ ២ពេត្រុស ១:២-៤

## ក.ការចោទប្រកាន់ចំពោះយើង

មានចំណែកជាច្រើននៃធម្មជាតិរបស់ព្រះ ដែលត្រូវបានទទួលនូវការចោទប្រកាន់ចំពោះយើង ក្នុងពេលរំពេចដែលយើងបានទទួលនូវសេចក្តីសង្គ្រោះ ។ ពួកគេបានត្រឡប់មកជាចំណែកនៃការកើតជាថ្មី របស់យើងដែលមាននៅនោះ ។ យើងត្រូវបានទទួលនូវការប្រទានពរៈ

១. សេចក្តីសុចរិត

២. ភាពបរិសុទ្ធ

៣. សេចក្តីស្រឡាញ់

សេចក្តីសប្បុរស ព្រះគុណ និងសេចក្តីមេត្តាករុណា

ចំណែកនៃធម្មជាតិរបស់ព្រះទាំងនេះ គឺជាការទម្លាក់ទោស ចំពោះវិញ្ញាណដែលបានកើតជាថ្មីបំផុតរបស់យើង ពេលដែលយើងបានទទួលសេចក្តីសង្គ្រោះភ្លាមៗនោះឯង ។

## ខ.ការបញ្ចេញដោយនូវសេចក្តីសន្យារបស់ទ្រង់

លោកសាវ័កពេត្រុសបានសរសេរថែងទកមកថា ដោយនូវអំណាចចេស្តារបស់ព្រះ នោះយើងត្រូវបានទទួលនូវការប្រទានពរពីគ្រប់យ៉ាង ដែលជាប់ទាក់ទងទៅនឹងជីវិត និងភាពជាព្រះ ។ យើងបានត្រឡប់មកជាចំណែកនៃទេវភាពជាធម្មជាតិរបស់ព្រះ ដោយនូវការបើកសម្តែងពីព្រះបន្ទូលរបស់ព្រះ ។ ទាំងនេះហើយ ដែលត្រូវបានទទួលនូវការប្រទានពរដល់យើង ដោយនូវសេចក្តីសន្យាដ៏ធំ និងដោយមានតម្លៃ ។

ព្រះគម្ពីរ ២ពេត្រុស ១:២-៤

## VI. ការបានត្រឡប់ឱ្យដូចជាទ្រង់

យើងត្រូវបានទទួលនូវការប្រុងប្រៀបទុកជាមុន នៅក្នុងព្រះគ្រីស្ទ ដើម្បីឱ្យបានអនុលោមទៅតាមរូបភាពរបស់ព្រះអង្គនោះ ។

ព្រះគម្ពីររ៉ូម ៨:២៩ក

វិញ្ញាណដែលបានកើតជាថ្មី គឺត្រូវបានបង្កើតឡើងនៅក្នុងរូបភាពរបស់ព្រះ ហើយគ្រីស្ទានទាំងឡាយគឺបាននៅក្នុងរបៀបនៃការអនុលោមទៅតាមរូបភាពរបស់ទ្រង់ គឺនៅតំបន់ផ្នែករូបកាយ និងព្រលឹងរបស់ពួកគេនោះឯង ។

## ក.របៀបនៃការបំផ្លាស់បំប្រែ

លោកសាវ័កប៉ុលបានសរសេរថែងទុកមកនៅក្នុងព្រះគម្ពីររ៉ូម ១២:១-២ ថា :

នៅពេលដែលយើងបាមកើតជាថ្មី នោះយើងនឹងមិនបានអនុលោមទៅតាមលោកិយនេះតទៅទៀតឡើយ ។ យើងត្រូវតែរស់នៅជារបៀបផ្លាស់ប្រែជាបន្តទៅទៀត គឺយើងបានអនុលោមទៅតាមរូបភាពរបស់ព្រះរាជបុត្រានៃព្រះវិញ ។

### ១. ការចុះចូលទីមួយ

យើងបានជារបៀបបំផ្លាស់បំប្រែ ដោយការប្រគល់រូបកាយរបស់យើងទាំងស្រុងទៅព្រះ ។ រូបកាយរបស់យើង គឺជាព្រះវិហារនៃព្រះវិញ្ញាណ

បរិសុទ្ធ ហើយយើងត្រូវតែជាអ្នក "ថ្វាយយញ្ញបូជារស់ទៅព្រះ" ។

ដើម្បីឱ្យបានត្រឡប់ទៅជាចំណែកមួយ នៃធម្មជាតិជាទេវភាព គឺដែលយើងបាននៅក្នុងព្រះយេស៊ូវរួចហើយ នោះយើងត្រូវតែថ្វាយជីវិតរបស់យើងទាំងស្រុង ទៅក្នុងភាពនៃព្រះអម្ចាស់របស់ព្រះយេស៊ូវគ្រីស្ទ ជារៀងរាល់ថ្ងៃ ។

**២. គំនិតដែលត្រូវបានបង្កើតឡើងសារជាថ្មី**

សូម្បីតែរូបកាយរបស់យើង ក៏ត្រូវបានទទួលនូវការកែជាថ្មី នោះព្រលឹងរបស់យើងក៏ត្រូវតែបានទទួលនូវការកែជាថ្មី ដោយមានជារបៀបបន្តពីការត្រាស់ហៅមក ឱ្យបានកើតជាថ្មីខាងផ្នែកគំនិតផងដែរ ។ របៀបនៃការបំផ្លាស់បំប្រែនេះ គឺត្រូវចាប់យកកន្លែង ក្នុងពេលដែលយើងបន្តនូវការអាន ស្តាប់ ពួពិចារណា ហើយជឿ និងប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះ ។ វាគឺជាការងារអធិធម្មជាតិនៃព្រះវិញ្ញាណបរិសុទ្ធ ។

តាមរបៀបជាអធិធម្មជាតិនេះ រូបកាយ និងព្រលឹងរបស់យើង បានត្រឡប់មកជាផ្នែកធម្មជាតិជាទេវភាព ។

**ខ.ព្រះទ្រង់បានធ្វើការងារនៅក្នុងយើង**

លោកសាវ័កប៉ុល បានអធិស្ឋានដោយមានកម្លាំងទៅលើស្ត្រីម្នាក់ដែលកំពុងតែឆ្លងទន្លេ ចំពោះពួកអ្នកជឿនៅក្នុងស្រុកកាឡាទី ដែលគ្រីស្ទានត្រូវតែបង្កើតនៅក្នុងពួកគេ។

ព្រះគម្ពីរកាឡាទី ៤:១៩

គាត់បានប្រាប់ទៅពួកអ្នកជឿនៅទីក្រុងភីលីពថា ព្រះទ្រង់បានកំពុងតែធ្វើការនៅក្នុងពួកគេហើយ ។

ព្រះគម្ពីរភីលីព ២:១៣ ចែងថា ត្បិតគឺជាព្រះហើយដែលធ្វើការនៅក្នុងអ្នកទាំងពីរ ដែលមានបំណងនឹងធ្វើសម្រាប់ការងារល្អដែលគាប់ព្រះហឫទ័យរបស់ទ្រង់ ។

ព្រះទ្រង់នៅតែបន្តធ្វើការងារ នៅក្នុងជីវិតរបស់អ្នកដែលបង្កើតឡើងជាថ្មីរបស់ទ្រង់ រហូតដល់ពួកគេបានអនុលោមទៅតាមរូបភាព នៃព្រះរាជបុត្រារបស់ព្រះនោះឯង ។

បើយើងចេះតែបើកឱកាសឱ្យទ្រង់បានធ្វើការ គឺជាការងាររបស់ទ្រង់ ដែលមានជាចំណែកនៅក្នុងយើង នោះយើងនឹងរឹតតែបានត្រឡប់មក ដូចជាព្រះគ្រីស្ទនោះដែរ ។

## VII. ការយកចំណែកនៃភាពបរិសុទ្ធរបស់ទ្រង់

វិញ្ញាណដែលបានកើតជាថ្មីរបស់យើង គឺជាបរិសុទ្ធ ត្បិតទ្រង់បរិសុទ្ធ ។

ព្រះគម្ពីរអេភេសូរ ១:៤

ចូរចងចាំថា រូបកាយនិងព្រលឹងរបស់យើង គឺនៅក្នុងរបៀបដែលត្រូវបានអនុលោមទៅតាមរូបភាពរបស់ព្រះគ្រីស្ទ ។ យើងត្រូវតែធ្វើការជ្រើសរើស យកភាពបរិសុទ្ធក្នុងជីវិតជាប្រចាំថ្ងៃរបស់យើង ។ នេះគឺជាភាពបរិសុទ្ធដែលប្រកបដោយការពិសោធន៍ ។

ព្រះគម្ពីរលេវីវិន័យ ១៩:២២

យើងត្រូវតែជ្រើសរើសឱ្យបានត្រឡប់មកជាបរិសុទ្ធ នៅក្នុងការប្រព្រឹត្តរបស់យើង ។ យើងត្រូវតែថ្វាយជីវិតរបស់យើងឱ្យបានជាភាជនៈបរិសុទ្ធ ទៅចំពោះព្រះ ។ យើងត្រូវតែប្រឹក្សាដោយខ្លួនឯង ចំពោះការស្លាប់ខាងឯអំពើបាប ហើយរស់ជាមួយនឹងព្រះយេស៊ូវវិញ ។

នេះគឺជាការឧទ្ទិសថ្វាយដោយមានការពិសោធន៍ គឺជារបៀបនៃការជ្រើសរើសផ្ទែកមួយ ចេញពីប្រព័ន្ធលោកិយនេះ ហើយទៅព្រះយេស៊ូវគ្រីស្ទអង្គទ្រង់វិញ ។ វាគឺជាការត្រឡប់មកឱ្យដូចជាព្រះយេស៊ូវ ក្នុងការរស់នៅ និងការប្រព្រឹត្តជាប្រចាំថ្ងៃរបស់យើង ។

ព្រះគម្ពីរ ១ពេត្រុស ១:១៥-១៦

យើងត្រូវបានទទួលព្រះរាជបញ្ជា ឱ្យមានភាពបរិសុទ្ធ ហើយយើងអាចធ្វើដូច្នេះ តាមចំណែកនៃធម្មជាតិរបស់ព្រះដែលបរិសុទ្ធនោះឯង ។ ប៉ុន្តែ យើងនាំមកនូវកញ្ចប់ខ្លះៗនៅក្នុងព្រលឹងនិងរូបកាយរបស់យើង ។ ប៉ុន្តែ យើងនាំមកនូវកញ្ចប់ខ្លះៗនៅក្នុងព្រលឹងនិងរូបកាយរបស់ ។ សេចក្តីតម្រូវការឱ្យធ្វើការងារ បញ្ចេញនូវសេចក្តីសង្គ្រោះរបស់យើង ទាំងនៅក្នុងព្រលឹង និងក្នុងរូបកាយរបស់យើងនោះឯង ។ ព្រះទ្រង់សម្រេចព្រះទ័យនឹងបង្កើតភាពបរិសុទ្ធយ៉ាងពិតប្រាកដ ។ ទ្រង់កំពុងតែបានកែព្រលឹងរបស់យើងឡើងវិញ ហើយក៏បានប្រោសរូបកាយរបស់យើងឱ្យបានជាផងដែរ ។

## VIII. ចំណែកនៃសេចក្តីស្រឡាញ់របស់ទ្រង់

### ក.ព្រះទ្រង់ជាសេចក្តីស្រឡាញ់

ព្រះដែលទ្រង់មានធម្មជាតិជាសេចក្តីស្រឡាញ់នោះឯង ។ ទ្រង់គឺជាប្រភពនៃសេចក្តីស្រឡាញ់ទាំងអស់ ។ ដើម្បីធ្វើការអនុលោមទៅតាមរូបភាពរបស់ព្រះអង្គនោះយើងក៏ត្រូវតែបានទទួលនូវសេចក្តីបញ្ញត្តិឱ្យមានសេចក្តីស្រឡាញ់នោះឯង។

ព្រះគម្ពីររ៉ូម ៥:៨ ១៣:៨ យ៉ូហាន១៣:៣៤ ម៉ាថាយ ៥:៤៤

យើងគឺជាអ្នកមានចំណែកនៃធម្មជាតិជាទេវភាព ដោយនូវព្រះវិញ្ញាណបរិសុទ្ធ នោះយើងអាចនិងត្រូវតែមានសេចក្តីស្រឡាញ់ជាអធិធម្មជាតិយ៉ាងដូច្នេះ គឺសម្រាប់អ្នកដទៃទៀត សូម្បីតែអស់អ្នកដែលជាខ្មាំងសត្រូវរបស់យើងក៏ដោយ។ ព្រះយេស៊ូវទ្រង់មិនដែលបានបញ្ជាឱ្យយើងធ្វើការណា ដែលយើងគ្មានលទ្ធភាពនឹងធ្វើនោះឡើយ ។ យើងក៏អាចនិងត្រូវតែស្រឡាញ់ដល់ខ្មាំងសត្រូវរបស់យើង ជាសេចក្តីស្រឡាញ់អាកាប៉េរបស់ព្រះ ។

**១. គំរូនៃសេចក្តីស្រឡាញ់**

លោកស្ទេផាន គឺជាគំរូដ៏សំខាន់នៃសេចក្តីស្រឡាញ់ អាកាប៉េ ជាអធិធម្មជាតិដែលគាត់អាចទទួលរងនូវការចោលសម្លាប់នឹងដុំថ្ម មកពីខ្មាំងសត្រូវរបស់គាត់ ។

ព្រះគម្ពីរកិច្ចការ ៧:៥៩-៦០

**២. ការជ្រើសរើសសេចក្តីស្រឡាញ់**

ចាប់តាំងពីសេចក្តីស្រឡាញ់ ក្នុងពេលដែលខ្មាំងសត្រូវរបស់យើងមានការចោទប្រកាន់ ដល់អារម្មណ៍យើង និងធម្មជាតិអាត្មនិយមរបស់យើងមក នោះយើងមានការបើកសម្តែង ចំពោះធម្មជាតិសេចក្តីស្រឡាញ់របស់ព្រះ គឺយើងត្រូវតែជ្រើសរើសយកសេចក្តីស្រឡាញ់ ដែលព្រះទ្រង់ជាសេចក្តីស្រឡាញ់នោះឯង ។

ព្រះគម្ពីរ ១ពេត្រុស ១:២២

### ខ.អ្នកស្រឡាញ់ដល់ព្រះ

ចំពោះអស់អ្នកដែលមានការបើកសម្តែង ពីការកើតជាថ្មីៈ គឺដែលពួកគេបាននៅក្នុងព្រះគ្រីស្ទ ហើយក៏បានត្រឡប់មកជា

ចំណែកនៃធម្មជាតិទេវភាព បំណងព្រះហឫទ័យរបស់ទ្រង់ នោះគ្រប់ទាំងអស់នៅខាងលើ ត្រូវបានមកជាអ្នកស្រឡាញ់ដល់ព្រះហើយ ។

ពួកគេនឹងធ្វើគ្រប់យ៉ាងដែលគាប់ដល់ព្រះទ័យព្រះ ដោយការស្ដាប់បង្គាប់ដល់ព្រះបន្ទូលរបស់ព្រះអង្គនោះឯង ។ ពួកគេនឹងបានជាអ្នកថ្វាយបង្គំដល់ព្រះ ។

ការកើតជាថ្មីដែលមាននៅ នោះនឹងសរសើរតម្កើងដល់ព្រះ ឱ្យបានទទួលនូវព្រះពរដ៏អស្ចារ្យគ្រប់ទាំងអស់របស់ព្រះ ។ ពួកគេនឹងថ្វាយបង្គំដល់ព្រះ សម្រាប់អាអ្នកណាដែលព្រះគង់នៅជាមួយ ។ ការសរសើរតម្កើងរបស់ព្រះនឹងនៅតែបន្ត ក្នុងបបូរមាត់របស់ពួកគេ ។

ការកើតជាថ្មីដែលមាននៅ នឹងមានសេចក្ដីស្រឡាញ់ដ៏មានជម្រៅជ្រៅ និងមានភាពស្និទ្ធស្នាលក្នុងការប្រកបទាក់ទងជាមួយនឹងព្រះ ។

ព្រះគម្ពីរទំនុកដំកើង ៤២:១-២

ការកើតជាថ្មីនឹងដើរដោយសេចក្ដីស្រឡាញ់អាកាប៉េរបស់ព្រះគ្រីស្ទ ចំពោះអ្នកជឿទាំងឡាយណា ដែលដើរតាមព្រះអង្គ ខ្មាំងសត្រូវរបស់ព្រះអង្គ និងចំពោះអង្គទ្រង់នោះឯង ។

## IX. ការយកចំណែកនៃសេចក្ដីសប្បុរស និងមេត្តាករុណា

### ក.ព្រះទ្រង់ល្អ

ព្រះដ៏ជាព្រះគឺមានធម្មជាតិរបស់ទ្រង់សុទ្ធតែល្អ ព្រះគម្ពីរទំនុកដំកើង ៥២:១ខ ។

សេចក្ដីសប្បុរសរបស់ព្រះ គឺជាការគ្រប់លក្ខណ៍ពេញលេញបំផុត ។ សេចក្ដីសប្បុរសរបស់ទ្រង់ គឺត្រូវបានចង្អុលបង្ហាញទៅលើការបង្កើតគ្រប់ទាំងអស់របស់ទ្រង់ ដោយសេចក្ដីមេត្តាករុណា និងព្រះគុណរបស់ទ្រង់នោះឯង ។

### ខ. សេចក្ដីមេត្តាករុណា និងព្រះគុណរបស់ព្រះ

ចំពោះពួកមនុស្សជាតិដែលមានពេញដោយអំពើបាប គឺត្រូវបានបង្ហាញឱ្យឃើញយ៉ាងច្បាស់ និងពេញលេញស្ទើរតែទាំងអស់ នោះគឺនៅពេលដែលទ្រង់បានប្រទានព្រះរាជបុត្រាទ្រង់ ឱ្យមកសុគតជំនួសយើងរាល់គ្នា ។ អត្ថន័យមួយបណ្ដាអត្ថន័យនៃសេចក្ដីមេត្តាករុណានោះគឺ ជាការអត់ធនពីការដែលគេធ្វើទារុណ្ណកម្ម ដោយសារក្រឹត្យវិន័យ ។

សេចក្ដីមេត្តាករុណារបស់ព្រះ គឺជាសេចក្ដីសប្បុរសរបស់ព្រះ ដែលបានទទួលការអនុវត្តន៍ជាផលប្រយោជន៍នៃសេចក្ដីត្រូវការរបស់យើង ។ ព្រះទ្រង់ជាអ្នកមានគឺមានសេចក្ដីមេត្តាករុណានោះឯង!

ព្រះគម្ពីរអេភេសូរ ២:៤

ការបានសង្គ្រោះដោយព្រះគុណ!

ព្រះគម្ពីរអេភេសូរ ២:៨

ឥឡូវនេះ ដែលយើងបានកើតជាថ្មីហើយ យើងអាចបានចូលមកក្នុងបល្ល័ង្កនៃព្រះគុណរបស់ទ្រង់នោះឯង ។

ព្រះគម្ពីរ ហេព្រើរ ៤:១៦

## X. ការបានចំណែកនៃការអត់ទោស

### ក.ជម្រើសចំពោះការអត់ទោស

ដែលយើងបានជាចំណែកនៃធម្មជាតិជាទេវភាពរបស់ព្រះនោះយើងបានកើតជាថ្មីហើយមាននៅផង ក៏នឹងដើរនៅក្នុងសេចក្ដីមេត្តាករុណារបស់ផងព្រះ ទៅដល់អ្នកដទៃទៀត ។

យើងនឹងអត់ទោស ដូចជាព្រះទ្រង់អត់ទោសដែរ ។

ព្រះគម្ពីរអេភេសូរ ៤:៣២, ព្រះគម្ពីរលូកា ២៣:៣៤ក

ព្រះយេស៊ូវទ្រង់គំរូបរបស់យើង ពីព្រោះទ្រង់បានអត់ទោសដល់យើង គឺទ្រង់បានជំនួសយើងរាល់គ្នាពីគ្រប់អំពើបាប

ទាំងអស់នោះ គឺយើងក៏អាចអត់ទោសបាបដល់អ្នកដទៃទៀតដែរ ។

## ខ.ការអត់ទោសដល់អ្នកដែលត្រូវអត់ទោស

ការកើតជាថ្មីនៅក្នុងព្រះយេស៊ូវគ្រីស្ទ គឺជាការកាន់កាប់នូវធម្មជាតិនៃសេចក្ដីស្រឡាញ់ មេត្តាករុណា ព្រមទាំងព្រះគុណដែលជាទេវភាពរបស់ព្រះ នោះយើងក៏ត្រូវតែមានលទ្ធភាពនឹងអត់ទោស ដល់អ្នកទាំងអស់ដែលបានធ្វើបាបប្រឆាំងទាស់នឹងយើង ឬក៏ប្រឆាំងទាស់នឹងអ្នកជាទីស្រឡាញ់របស់យើង ។ យើងបានទទួលនូវការបញ្ជា ឱ្យមានការអត់ទោស ដើម្បីឱ្យយើងអាចបានទទួលនូវការអត់ទោសផងដែរ ។

## គ.សេចក្ដីសរុបបញ្ចប់

ពេលដែលយើងបានកើតជាថ្មីហើយ នោះយើងមានជីវិត និងមានធម្មជាតិរបស់ព្រះនៅក្នុងវិញ្ញាណរបស់យើង។ ព្រលឹង និងរូបកាយរបស់យើងបានត្រឡប់មកជាផ្នែកនៃធម្មជាតិ ជាទេវភាពរបស់ព្រះ គឺដែលយើងបានអនុលោមទៅតាមរូបភាពនៃព្រះរាជបុត្រារបស់ព្រះនោះឯង ។

ចំណែករបស់យើងគឺត្រូវតែបានថ្វាយរូបកាយ ទុកជាយញ្ញបូជារស់ដល់ព្រះ ក្នុងការចំណាយពេលនៅក្នុងព្រះបន្ទូលរបស់ព្រះ ហើយត្រូវតែស្ដាប់តាមសេចក្ដីបង្រៀនរបស់ផងព្រះអង្គ ដើម្បីឱ្យព្រលឹងរបស់យើងនឹងបានទទួលនូវការផ្លាស់ប្រែ ដោយនូវការបើកសម្ដែងពីព្រះបន្ទូលរបស់ព្រះ ។

យើងត្រូវតែបានត្រឡប់មកជាសេចក្ដីសុចរិត ភាពបរិសុទ្ធ សេចក្ដីស្រឡាញ់ និងសេចក្ដីសប្បុរសរបស់ផងព្រះ ។ យើងត្រូវតែបានជាចំណែកនៃសេចក្ដីមេត្តាករុណា និងជាព្រះគុណរបស់ផងព្រះរហូតដល់យើងបានដូចជាព្រះអង្គបានត្រឡប់មកជាអ្នកអត់ទោសដល់អ្នកដទៃទៀត ។

ពេលដែលសលយើងបានកើតជាថ្មីហើយ នោះវិញ្ញាណរបស់យើងបានទទួលនូវការចែករំលែក នូវទេវភាពរបស់ព្រះផងដែរ ។ ព្រលឹង និងរូបកាយរបស់យើង គឺនឹងបានត្រឡប់មកជាចំណែកនៃទេវភាព ដោយនូវអំណាចចេស្ដានៃការបំផ្លាស់បំប្រែ មកពីព្រះបន្ទូលរបស់ព្រះ នៅក្នុងជីវិតរបស់យើង ។

# XI. ការពិចារណាទៅលើព្រះបន្ទូលរបស់ព្រះ

## ក.ការសំខាន់នៃការជញ្ជឹងគិត

វាគឺជាការសំខាន់ដែលយើងបានជញ្ជឹងគិត ទៅលើព្រះបន្ទូលរបស់ព្រះ មិនមែនទៅលើសាវតា ភាពទន់ខ្សោយ ការខ្វះខាតសមត្ថភាព ស្ថានការណ៍ ឬជាបញ្ហារបស់យើងនោះទេ ។ ប្រសិនបើយើងនៅតែបន្ដដាក់គំនិតរបស់យើង ទៅលើរឿងរ៉ាវអវិជ្ជមានទាំងនេះ នោះគំនិតរបស់យើងនឹងមិនអាចទទួលនូវការកើតឡើងជាថ្មីម្ដងទៀតបានឡើយ ។

ព្រះគម្ពីរភីលីព ៤:៨-៩

ការជញ្ជឹងគិតទៅលើព្រះបន្ទូលរបស់ព្រះ គឺជាកូនសោរនៅក្នុងការបំផ្លាស់បំប្រែ ដោយការបង្កើតឡើងជាថ្មីម្ដងទៀតនៃគំនិតរបស់យើងនោះវិញ ។ ការប្រមើលមើលនូវសេចក្ដីពិតទាំងនេះ គឺជាការពិតដែលមាននៅក្នុងជីវិតរបស់យើង ។

ព្រះគម្ពីរទំនុកដំកើង ១:១-៣

មនុស្សដែលបានកើតឡើងជាថ្មី គឺត្រូវជញ្ជឹងគិតទៅលើព្រះបន្ទូលព្រះទាំងយប់ទាំងថ្ងៃ នូវការបំផ្លាស់បំប្រែពីក្នុងជីវិតរបស់គាត់ឬនាងនោះ ។

ខ.៣ បានផ្ដល់ឱ្យយើងនូវលទ្ធផល៤យ៉ាង ដែលនឹងប្រាកដ

ឡើងជាមនុស្សដែលបន្តនូវការជញ្ជឹងគិតទៅលើព្រះបន្ទូលព្រះ នោះ ។

## ខ.ការរំឭកគំនិតរបស់យើងសារជាថ្មី

ពេលដែលយើងបានជញ្ជឹងគិតទៅលើព្រះបន្ទូលព្រះ នោះយើងនឹង "បានទទួលនូវការបំផ្លាស់បំប្រែដោយការរំឭកគំនិតរបស់យើងសារជាថ្មី" ។

ព្រះគម្ពីររ៉ូម ១២:២ក

តាមការជញ្ជឹងគិតទៅលើព្រះបន្ទូលរបស់ព្រះ នោះការបំផ្លាស់បំប្រែនឹងកើតមានឡើង ។ ព្រលឹងរបស់យើង (ឆន្ទៈ អារម្មណ៍ និងបំណង) បានត្រឡប់ជាមានការបំផ្លាស់បំប្រែទៅជាអ្វី ដែលវិញ្ញាណរបស់យើងបានត្រឡប់ជាមានសេចក្ដីសង្គ្រោះក្នុងមួយរំពេចភ្លាមនោះឯង ។

ព្រះគម្ពីរសុភាសិត ២៣:៧ក

ពេលដែលយើងជញ្ជឹងគិតព្រះបន្ទូលរបស់ព្រះ នោះការប្រែប្រួលនឹងមានការកើតឡើង ។ ដង្កូវដែលមាននៅក្នុងធម្មជាតិព្រលឹងចាស់របស់យើងក៏ត្រូវបានទទួលនូវការបំផ្លាស់បំប្រែ ឱ្យទៅជាមេអំបៅដ៏ស្រស់ស្អាត ដែលបានអនុលោមទៅតាមរូបភាពរបស់ព្រះគ្រីស្ទអង្គទ្រង់នោះឯង ។

## គ.អត្ថន័យនៃការជញ្ជឹងគិត

### ១. ការផ្ចង់ចិត្តទៅលើ

ពេលដែលយើងជញ្ជឹងគិត លើព្រះបន្ទូលរបស់ព្រះ នោះយើងផ្ចង់ចិត្តទៅដោយការប្រុងប្រយ័ត្នយ៉ាងពេញលេញទៅលើព្រះបន្ទូល ដែលព្រះទ្រង់បាននិយាយ ។ យើងបានព្យាយាមសារចុះសារឡើង ទៅលើព្រះបន្ទូលនោះដោយខ្លួនឯង ។

ព្រះគម្ពីរ ១ធីម៉ូថេ ៤:១៥

### ២. ការប្រមើលមើល

ពេលដែលយើងនៅតែបន្តជញ្ជឹងគិត ទៅលើព្រះបន្ទូលព្រះ នោះយើងក៏ចាប់ផ្ដើមប្រមើលមើលទៅលើការកើតជាថ្មីនោះ ។ យើងក៏ចាប់ផ្ដើមមើលឃើញ ដូចជាព្រះទ្រង់បានមើលឃើញយើងដែរ គឺយើងបានធ្វើនូវអ្វីដែលព្រះទ្រង់មានបន្ទូលថា យើងអាចធ្វើបាននោះ ហើយមានអ្វីដែលទ្រង់មានបន្ទូលថា យើងមាននោះដែរ ។

លោកសាវ័កប៉ុលបានសរសេរ ទៅកាន់លោកធីម៉ូថេថា នៅពេលដែលគាត់ជញ្ជឹងគិតទៅលើព្រះបន្ទូល នោះភាពជឿនរបស់គាត់ នឹងត្រូវបានបញ្ជាក់ពីគ្រប់ទាំងអស់ ។ លោកយ៉ូស្វេក៏បានសរសេរថែងទុកមកដែរ ថា ទីមួយយើងត្រូវតែជញ្ជឹងគិតទៅលើព្រះបន្ទូលទាំងថ្ងៃទាំងយប់ បន្ទាប់មក យើងត្រូវតែបានទទួលនូវការចម្រុងចម្រើន ហើយយើងក៏ត្រូវតែបានទទួល ជោគជ័យដ៏ល្អត្រចះត្រចង់ ។

ព្រះគម្ពីរយ៉ូស្វេ ១:៨

### ៣. អំពីគោលដៅ

ពេលដែលយើងចាប់ផ្ដើមប្រមើលមើល ទៅព្រះយេស៊ូវ ដូចជាទ្រង់ក៏ប្រមើលមើលមកយើងដែរ នោះការយល់ដឹងដែលយើងបានកើតជាថ្មី នៅក្នុងទ្រង់ នោះយើងនឹងចាប់ផ្ដើមមើលឃើញដោយខ្លួនយើង ដូចជាទ្រង់បានមើលឃើញយើងនោះដែរ ។ លោកសាវ័កយ៉ូហាន ក៏បានសរសេរថែងទុកមកដែរថា យើងត្រូវតែឱ្យបានដូចជាព្រះអង្គ ។ ឱសេចក្ដី

សន្យាដ៏គួរ ឱ្យអស្ចារ្យអ្វីម្ល៉េះហ្ន៎! ព្រះគម្ពីរ ១យ៉ូហាន ៣:២ ។

នៅពេលដែលយើងជញ្ជឹងគិត នោះយើងនឹងចាប់ផ្ដើមនិយាយពីអ្វី ដែលព្រះបន្ទូលព្រះទ្រង់បានចែងទុកមកអំពីយើងកាន់តែច្រើនឡើង១ រហូតទាល់តែវាបានត្រឡប់មកជាការពិត នៅក្នុងជីវិតរបស់យើង ។

## ៤. ការនិយាយហ៊ឹម១

ព្រះគម្ពីរអេសាយ ៥៩:២១

ពាក្យជាភាសាហេព្រើរ សម្រាប់ការជញ្ជឹងគិតគឺមានន័យថា "ការនិយាយហ៊ឹម១" ។ ពេលដែលយើងនិយាយហ៊ឹម១ ឬនិយាយប្រកាសនូវព្រះបន្ទូលព្រះឱ្យកាន់តែច្រើនឡើង១ដោយខ្លួនឯងនោះ វានឹងបញ្ចេញនូវអំណាចចេស្ដានៃព្រះបន្ទូលរបស់ព្រះ ចូលទៅក្នុងសកម្មភាពដែលមាននៅក្នុងជីវិតរបស់យើង ។

នៅពេលដែលយើងនិយាយហ៊ឹម១ ឬនិយាយប្រកាសនូវព្រះបន្ទូលរបស់ព្រះ មកកាន់ខ្លួនយើងនោះ យើងនឹងរុករកឃើញថា វាបានត្រឡប់មកជាការដក់ជាប់ដោយមិនរលប់ ទៅលើគំនិតរបស់យើងដែលយើងបានចងចាំរួចមកហើយនោះ ។

## ៥. ការស្រមើស្រមៃ

ពេលដែលយើងបន្តការជញ្ជឹងគិត ទៅលើការកើតជាថ្មី នោះសេចក្ដីពិតនៃព្រះបន្ទូលរបស់ព្រះនោះនឹងបានបញ្ចេញនូវការស្រមើស្រមៃ ទៅកាន់ទម្រង់នៃរូបភាពដូចជាព្រះនោះ ។ យើងចាប់ផ្ដើមគិតនូវគំនិតរបស់ព្រះ ហើយមើលឃើញដោយខ្លួនយើងនូវការកើតជាថ្មីតាមរយៈព្រះនេត្ររបស់ព្រះ ។ ព្រះគម្ពីរអេសាយ ៥៥:៨-៩ ។

## ៦. ការយល់បាន

យើងនឹងចាប់ផ្ដើមយល់បាន ឬយល់ដឹងនូវប្រាជ្ញា និងការបើកសម្ដែងរបស់ផងព្រះ ។

ព្រះគម្ពីរអេភេសូរ ១:១៧-១៨

## XII. អំណាចចេស្ដានៃការប្រកាសព្រះបន្ទូល

លោកសាវ័កប៉ុលបានសរសេរចែងទុកមកថា សេចក្ដីជំនឿបានមកដោយសារការឮ ហើយការឮនោះគឺឮព្រះបន្ទូលរបស់ព្រះ ។ យើងបានស្ដាប់ឮព្រះបន្ទូលរបស់ព្រះនោះឯង ។ យើងស្ដាប់ឮបន្ទូលរបស់ព្រះគឺដោយការអានហើយអានទៀតតាមរយៈសេចក្ដីបង្រៀនដ៏ល្អនោះ ។

ព្រះគម្ពីររ៉ូម ១០:១៧

ប្រសិនបើមានសេចក្ដីត្រូវការពិសេស នៅក្នុងជីវិតរបស់យើង នោះយើងត្រូវតែរកឱ្យឃើញនូវខព្រះបន្ទូលរបស់ព្រះដែលជាចម្លើយជាសេចក្ដីត្រូវការ ហើយត្រូវអានម្ដងហើយម្ដងទៀត ។ សេចក្ដីជំនឿនឹងចូលមកតាមការស្ដាប់ឮ នូវព្រះបន្ទូលរបស់ព្រះរ៉េម៉ា ។ ពេលដែលយើងអាន ឬបញ្ជាក់នូវខគម្ពីរទាំងនេះកាន់តែច្រើនឡើង ខគម្ពីរទាំងនោះក៏បានត្រឡប់មកជាសេចក្ដីពិតបន្ថែមទៀតដល់យើង ជាជាងស្ថានការណ៍ដែលយើងនៅក្នុងនោះទៅទៀត ។ សេចក្ដីជំនឿក៏បានចូលមក ។ ព្រះបន្ទូលរ៉ាម៉ារបស់ព្រះអង្គទ្រង់ផ្ទាល់ក៏បានចូលមក គឺជាការបើកសម្ដែង និងការមានព្រះបន្ទូលមកកាន់វិញ្ញាណរបស់យើង ដោយព្រះវិញ្ញាណបរិសុទ្ធ ។ ក្នុងខណៈដែលយើងទទួលនូវការបើកសម្ដែងនោះ សេចក្ដីជំនឿក៏បាន

ជ្រាបចូលមកក្នុងវិញ្ញាណរបស់យើង ។ ដូចជាការយល់ដឹងរបស់យើង គឺត្រូវបានចាំងជះមកដោយពាក្យរ៉េម៉ារបស់ព្រះ គឺដែលយើងនឹងចូលមកក្នុងចំណេះដឹង របស់អ្នកដែលយើងពិតប្រាកដថាជាអ្នកនៅក្នុងព្រះយេស៊ូវនោះឯង ។ យើងនឹងបានទទួលនូវការផ្លាស់ប្រែចូលទៅក្នុងការកើតជាថ្មី ហើយមាននៅនោះ ។

## ក.ការប្រកាសព្រះបន្ទូលរបស់ព្រះ

សកម្មភាពនៃការប្រកាសព្រះបន្ទូលរ៉េម៉ារបស់ព្រះ គឺជាការត្រាស់ហៅមកឱ្យមានការថ្លែងប្រាប់ នូវព្រះបន្ទូលរបស់ព្រះនោះ ។ ពាក្យថ្លែងប្រាប់ដែលបានបកប្រែជាភាសាក្រិក គឺ "ហូម៉ូឡូកេអូ" ។ ការថ្លែងប្រាប់ពីព្រះបន្ទូលរបស់ព្រះ នោះមានន័យថា:

១. ការនិយាយពីរឿងដូចគ្នា ។

២. ការឯព្រមព្រៀងជាមួយគ្នា ។

៣. ការរស់នៅដែលស្របគ្នា ។

នេះគឺជាអ្វីដែលបានកើតឡើងចំពោះយើងម្នាក់ៗ គឺនៅពេលដែលយើងបានទទួលពាក្យរ៉ាម៉ា ជាការបើកសម្តែងរបស់ដំណឹងល្អ ។ យើងបានជឿនិងបានថ្លែងប្រាប់ថា ព្រះយេស៊ូវគឺជាព្រះរាជបុត្រានៃព្រះ ដែលទ្រង់បានសុគតជំនួសយើង ហើយដែលទ្រង់បានរស់ពីសុគតឡើងវិញនោះ ។

ព្រះគម្ពីររ៉ូម ១០:៩-១០

ខ្ញុំជឿ-ខ្ញុំត្រូវតែនិយាយប្រាប់...

ក្នុងពេលមួយរំពេចដែលយើងជឿ នោះយើងត្រូវតែនិយាយប្រាប់ ត្រូវថ្លែងប្រាប់ពីអ្វីដែលបានទទួលនូវការបើកសម្តែងដល់យើង ។ មានវិញ្ញាណនៃសេចក្តីជំនឿ ហើយថ្លែងប្រាប់ថា "ខ្ញុំបានជឿ ដូច្នេះ ខ្ញុំត្រូវតែនិយាយប្រាប់!" ពាក្យសម្តីដែលបាននិយាយបានត្រឡប់មកជាពិតប្រាកដ ។

ព្រះគម្ពីរ ២កូរិនថូស ៤:១៣

## ខ.ព្រះទ្រង់បានបង្កើតរបស់មកដោយមានព្រះបន្ទូល

យើងត្រូវបានបង្កើតមកឱ្យមានរូបភាពរបស់ព្រះ ។ ព្រះទ្រង់ជាអ្នកបង្កើត ហើយទ្រង់បានបង្កើតដោយមានព្រះបន្ទូលនោះឯង ។

ព្រះគម្ពីរហេព្រើរ ១១:៣

យើងបានឃើញនូវអំណាចចេស្តានៃការបង្កើតរបស់ព្រះគឺនៅក្នុងសកម្មភាពជំពូកទីមួយនៃព្រះគម្ពីរលោកុប្បត្តិ ដែលនៅក្នុងឃ្លានិយាយថា "ហើយព្រះទ្រង់មានបន្ទូល" គឺជាពាក្យដែលនិយាយសារចុះសារឡើងជាច្រើនដង ។

## គ.យើងត្រូវបានបង្កើតមកដោយទ្រង់មានបន្ទូល

យើងគឺជាអ្នកបានកើតជាថ្មី ក៏ត្រូវបានបង្កើតដោយការមានព្រះបន្ទូល ដែលយើងត្រូវតែនិយាយនេះដែរ ។ ពាក្យសម្តីរបស់យើងអាចបានជាពាក្យសម្តីដែលនាំមកនូវបណ្តាសាផង និងអាចនាំមកនូវជីវិតផង ។

ព្រះគម្ពីរសុភាសិត ១៨:២១

ដែលយើងបានកើតជាថ្មីហើយ គឺត្រូវបានបង្កើតឱ្យចំនឹងរូបអង្គរបស់ព្រះ យើងត្រូវបានបង្កើតមកដោយសារព្រះបន្ទូលនោះឯង ។ ដោយនូវអំណាចចេស្តានៃការនិយាយភាសាដទៃនោះយើងបានបញ្ចេញ ទាំងពាក្យសម្តីនៃជីវិត ទាំងពាក្យសម្តីនៃសេចក្តីស្លាប់ ។

ពេលដែលយើងបានកើតជាថ្មី យើងត្រូវតែរវាងនូវបបូរមាត់របស់យើង និងមានការប្រុងប្រយ័ត្នពីអ្វីដែលយើងត្រូវតែ

និយាយនោះ ។ យើងអាចត្រូវការការផ្លាស់ប្រែនូវផ្លូវរបស់យើងដែលត្រូវនិយាយ ។ យើងមិនត្រូវបើកឱ្យពាក្យសម្ដីជាអវិជ្ជមាននៃសេចក្ដីស្លាប់ ឬក៏បើកឱ្យវិញ្ញាណអាក្រក់ចេញពីបបូរមាត់របស់យើងតទៅទៀតនោះឡើយ ។

## ឃ.ការប្រកាសពីព្រះបន្ទូល

ពេលដែលយើងបានជញ្ជឹងគិតនូវព្រះបនញ្ទូលព្រះ នោះសេចក្ដីជំនឿនឹងជ្រាបចូលទៅក្នុងវិញ្ញាណរបស់យើង ហើយព្រះទ្រង់នឹងបើកសម្ដែងនូវព្រះបន្ទូលរបស់ទ្រង់មកដល់យើងរាល់គ្នា ។ បន្ទាប់មក យើងនឹងប្រកាសដោយមានសេចក្ដីក្លាហាន ពីអ្វីដែលព្រះទ្រង់មានបន្ទូលក្នុងបន្ទូលរបស់ទ្រង់នោះ ។

ព្រះគម្ពីរ ១ពេត្រុស ៤:១១ក

**១. ការនិយាយទៅកាន់ភ្នំ**

ព្រះយេស៊ូវទ្រង់បានបើកសម្ដែង នូវការសំខាន់ដោយនូវ សេចក្ដីជំនឿដោយមានបន្ទូល និងការប្រកាសប្រាប់ តាមព្រះបន្ទូលរបស់ផងព្រះអង្គ ។

ព្រះគម្ពីរម៉ាកុស ១១:២២-២៤

**២. ចូរជឿថាយើងនឹងបានទទួល**

ពេលដែលយើងបានទទួលនូវការបើកសម្ដែងនូវព្រះបន្ទូលរេម៉ារបស់ផងព្រះ ចូលទៅក្នុងវិញ្ញាណដែលបានកើតជាថ្មីរបស់យើង នោះយើងនឹងជឿថាយើងបានទទួលនូវអ្វីដែល ព្រះទ្រង់បានមានបន្ទូលមកកាន់យើងហើយ ។ យើងនឹងចាប់ផ្ដើមនិយាយទៅកាន់ភ្នំនៃកាលៈទេសៈ ដែលនៅក្នុងជីវិតរបស់យើងបាន ។ មនុស្សដែលបានកើតជាថ្មីនឹងបានអ្វីតាមការដែលគាត់បាននិយាយនោះ ។

## ង.គំរូ

អស់អ្នកដែលបានទទួលនូវការបើកសម្ដែង ពីការកើតជាថ្មី នឹងចាប់ផ្ដើមប្រកាសនូវសិទ្ធិនៃការកើតជាថ្មី និងឯកសិទ្ធិរបស់ពួកគេហើយ ។

## ច.ប្រកាសដោយអង់អាច

ខ្ញុំស្គាល់អ្នកដែលខ្ញុំបានរស់នៅក្នុងព្រះគ្រីស្ទហើយ! ខ្ញុំគឺជាអ្នកដែលបានកើតជាថ្មីហើយ!

សេចក្ដីចាស់ទាំងប៉ុន្មានបានកន្លងបាត់ទៅហើយ! មើលគ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញហើយ!

ខ្ញុំមានសេចក្ដីសុចរិតរបស់ផងព្រះ នៅក្នុងព្រះយេស៊ូវគ្រីស្ទហើយ! ដូច្នេះ ក្នុងពេលឥឡូវនេះ ខ្ញុំគ្មានការផ្ដន្ទាទោសតទៅទៀតហើយ ពីព្រោះខ្ញុំបាននៅក្នុងព្រះគ្រីស្ទយេស៊ូវហើយ!

ខ្ញុំមានសេចក្ដីជំនឿ គឺជាពូជរបស់លោកអ័ប្រាហាំហើយ ។ គ្រប់ទាំងសេចក្ដីសន្យាដែលជាព្រះពររបស់លោកអ័ប្រាហាំ គឺជាព្រះពររបស់ខ្ញុំដែរ !

ព្រះទ្រង់មិនបានប្រទានពរឱ្យខ្ញុំ នូវវិញ្ញាណដែលតែងតែខ្លាចឡើយ គឺទ្រង់ប្រទានវិញ្ញាណដែលមានអំណាច សេចក្ដីស្រឡាញ់ និងប្រាជ្ញានឹងធឹងវិញ ។

ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន ពីព្រោះព្រះគ្រីស្ទទ្រង់នឹងចម្រើនកម្លាំងដល់ខ្ញុំ!

ការងារដែលព្រះយេស៊ូវទ្រង់បានធ្វើ ខ្ញុំក៏អាចធ្វើបានដែរ!

សេចក្ដីអំណររបស់ព្រះអម្ចាស់ គឺជាកម្លាំងរបស់ខ្ញុំហើយ!

ព្រះបន្ទូលបានចែងមកថា "ចូរឱ្យខ្សោយពោលថា ខ្ញុំខ្លាំង" ដូច្នេះហើយ ខ្ញុំគឺមានកម្លាំងដ៏ពិត! ព្រះយេស៊ូវទ្រង់បានត្រូវរបួសជំនួសជម្ងឺ ជម្ងឺរោគា និងការឈឺចាប់របស់ខ្ញុំដែលខ្ញុំនឹងមិនខ្លាចវាតទៅទៀតហើយ!

តាមរយៈស្នាមជាំរបស់ព្រះយេស៊ូវ នោះខ្ញុំបានទទួលនូវការប្រោសឱ្យជាហើយ! គ្មានជម្ងឺរោគាណានឹងចូលមកឯខ្ញុំបានទៀតឡើយ!

ព្រះនៃខ្ញុំទ្រង់នឹងបំពេញគ្រប់ទាំងអស់ដែលខ្ញុំត្រូវការតាមភោគសម្បត្តិនៃទ្រង់ដ៏ឧត្តម ដោយនូវសេរីល្អ!

គឺជាព្រះហើយដែលប្រទានពរឱ្យខ្ញុំ ដោយអំណាចចេស្តាឱ្យបានទទួលនូវភោគសម្បត្តិនោះឯង!

ខ្ញុំបានថ្វាយទៅព្រះ ហើយទ្រង់ក៏បានបំពេញនូវភោគសម្បត្តិរបស់ទ្រង់ត្រឡប់មកខ្ញុំវិញ ឱ្យបានពោរពេញ និងជារង្វាស់ដ៏លើសលុប! អ្វីក៏ដោយ ដែលខ្ញុំបានមើលឃើញ នោះខ្ញុំនឹងត្រូវបានទទួល!

ខ្ញុំបានទទួលនូវព្រះពរ គឺទាំងការដែលខ្ញុំបានចូលមកក្នុងទាំងការដែលខ្ញុំបានចេញទៅខាងក្រៅ!

អ្វីក៏ដោយដែលខ្ញុំបានជ្រើសរើសដោយដៃរបស់ខ្ញុំ ដើម្បីធ្វើ នោះនឹងបានទទួលព្រះពរ ដោយសារព្រះ!

ខ្ញុំនឹងមិនត្រូវបរាជ័យឡើយ! ខ្ញុំបានកើតជាថ្មីនៅក្នុងព្រះយេស៊ូវគ្រីស្ទហើយ!

យើងមានសេចក្ដីសុចរិតរបស់ព្រះ នៅក្នុងព្រះគ្រីស្ទយេស៊ូវហើយ!

## XIII. ការសរុបចប់

ពេលដែលយើងបានអាន ស្ដាប់ឮ សិក្សា និងជញ្ជឹងគិតនូវព្រះបន្ទូលរបស់ព្រះ នោះសេចក្ដីជំនឿនឹងសង់ឡើងនៅក្នុងចិត្តរបស់យើង ។ ពេលដែលយើងបានកើតជាថ្មី នោះយើងចាប់ផ្ដើម បញ្ចេញនូវអំណាចចេស្ដានៃព្រះបន្ទូលរបស់ព្រះដែលបានបង្កើតមកនោះឯង ។ ដោយនូវសេចក្ដីជំនឿ នោះយើងប្រកាសនូវព្រះបនញ្ទូលនោះឯង ។

ព្រះបន្ទូលរបស់ព្រះទ្រង់គឺរស់នៅ ហើយមានពេញដោយអំណាចចេស្ដា ។ អំណាចចេស្ដានោះគឺមានជីវិតរបស់ព្រះ ។ នៅពេលដែលយើងប្រកាសប្រាប់ពីការបើកសម្ដែង នូវការកើតជាថ្មី នោះយើងបានត្រឡប់មកជាចំណែកនៃធម្មជាតិរបស់ព្រះ ។ ពេលដែលយើងបានកាន់ខ្ជាប់នូវការប្រកាសប្រាប់ពីការបើកសម្ដែងនូវព្រះបន្ទូលរបស់ព្រះ នោះយើងនឹងរកឃើញដោយខ្លួននូវការកើតជាថ្មីនោះឯង ។

១. គ្រប់ការទាំងអស់ដែលព្រះទ្រង់មានបន្ទូល យើងក៏មានដែរ ។
២. ការធ្វើគ្រប់ទាំងអស់ដែលព្រះទ្រង់មានបន្ទូល នោះយើងក៏អាចធ្វើបានដែរ ។
៣. ការមានគ្រប់ទាំងអស់ដែលព្រះទ្រង់មានបន្ទូល នោះយើងក៏អាចមានដែរ ។
៤. ការបើកសម្ដែងចំពោះការកើតជាថ្មី នោះនឹងបានត្រឡប់មកជាមាននៅក្នុងជីវិតរបស់យើង ដ៏ជាក់ពិតប្រាកដមែន ។

## ក្រុមពិភាក្សា

១. តើអារម្មណ៍នៃការគិតថាមានទោស ថាមានការផ្តន្ទាទោស និងថាគ្មានតម្លៃ នឹងដក់ជាប់នៅក្នុងអ្នកជឿពីការទទួលនូវការប្រោសឱ្យជារបស់គាត់/នាង ដោយរបៀបណា?

២. តើអ្នកជឿនឹងមានកម្រៃយ៉ាងដូចម្តេចខ្លះ ដែលគេបានទទួលនូវការបើកសម្តែង ទៅលើការពិសោធន៍ខាងឯការកើតជាថ្មីនោះ?

៣. តើយើងអាចជ្រើសរើសធ្វើយ៉ាងដូចម្តេច ឱ្យមានជីវិតបរិសុទ្ធ នៅក្នុងការរស់នៅប្រចាំថ្ងៃរបស់យើងនោះ? តើការពិសោធន៍នៅក្នុងភាពបរិសុទ្ធយ៉ាងដូចម្តេចដែរ?

## ការសិក្សាដោយខ្លួនឯង

១. ចូរអធិស្ឋានសូមឱ្យព្រះទ្រង់នឹងជួយដល់លោកអ្នក ឱ្យបានជញ្ជឹងគិតនូវព្រះបន្ទូលរបស់ព្រះអង្គ សូមកុំឱ្យមានរឿងរ៉ាវជាអវិជ្ជមានឡើយ (ដូចជាស្ថានការណ៍ ឬជាបញ្ហា) ដើម្បីឱ្យគំនិតរបស់លោកអ្នកអាចបានរំឭកសារជាថ្មី និងមានការបំផ្លាស់បំប្រែ ។

ក. ចូរធ្វើឱ្យមានការខឹតខំប្រឹងប្រែង ដើម្បីបណ្តេញនូវគំនិតអវិជ្ជមាន ហើយយកការទាំងនោះចេញ ឱ្យបានរកឃើញនូវសេចក្តីពិត ដែលមាននៅក្នុងព្រះបន្ទូលរបស់ព្រះ ។

ខ. ចូរធ្វើការអនុវត្តន៍នូវអត្ថន័យ នៃពាក្យជាភាសាហេព្រើរៈ ការជីញ្ជឹងគិត ការនិយាយហ៊ឹមៗ/ ការប្រកាសព្រះបន្ទូលរបស់ព្រះ បន្ថែមហើយបន្ថែមទៀតដោយខ្លួនឯងផ្ទាល់ ។

២. ហេតុអ្វីបានជាវិញ្ញាណរបស់លោកអ្នក បានត្រឡប់មកជាមានការបំផ្លាស់បំប្រែ នៅក្នុងពេលមានសេចក្តីសង្គ្រោះភ្លាមៗ ប៉ុន្តែមិនបានបំផ្លាស់បំប្រែដល់ព្រលឹង និងរូបកាយរបស់លោកអ្នកក្នុងពេលភ្លាមៗដូចគ្នា?

៣. លោកអ្នកបានទទួលពាក្យរ៉េម៉ាដ៏ពិត នៅពេលដែលលោកអ្នកបានស្តាប់ឮនូវដំណឹងល្អ ហើយទទួលជឿ ព្រមទាំងបានទទួលថ្លែងប្រាប់ថា ព្រះយេស៊ូវគឺជាព្រះអម្ចាស់របស់លោកអ្នក ហើយដែលទ្រង់នោះឯង គឺជាព្រះរាជបុត្រារបស់ ព្រះ ។

ក. ចូរសរសេរចុះនូវពេលវេលាដ៏សំខាន់ដទៃទៀត ចំនួនពីរ-បីដង គឺជាពេលដែលលោកអ្នកបានទទួលនូវពាក្យរ៉េម៉ាដែលមកពីព្រះនោះ ។

ខ. តើអ្វីទៅជាលទ្ធផលនៃពាក្យរ៉េម៉ាទាំងនេះ?